**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

កញ្ញា **យ៉េង សុផាវ៉ា**

កញ្ញា **យន ពិសី**

សាស្ត្រាចារ្យណែនាំ

**លោក ខាត់ ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២២**

ឆ្នាំចូលសិក្សា **២០១៨**

ឆ្នាំសរសេរសារណា **២០២២**

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យ៉េង សុផារ៉ា** និងនាងខ្ញុំ **យន ពិសី** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់២២ ក្នុងឆ្នាំសិក្សា២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមសម្តែងនូវកតញ្ញូ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះគុណូបការៈរបស់លោកអ្នកមានគុណដ៏ធំធេងមិនអាចកាត់ថ្លៃបានចំពោះ ៖

- លោកឪពុក **យ៉េត យ៉េង** អ្នកម្តាយ **ទូច គៀង**
- លោកឪពុក **អ៊ុំ ធឿន** អ្នកម្តាយ **ផេន ជី**

ដែលលោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មានល្អៗ ការលើកទឹកចិត្ត និងឧបត្ថម្ភដល់ការសិក្សា រៀនសូត្រតាំងពីថ្នាក់មត្តេយ្យ រហូតមកដល់ថ្នាក់បរិញ្ញាបត្រ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និង លោក-លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក លោកស្រី បានធ្វើការផ្តល់នូវចំណេះដឹង ការអប់រំ និងសីលធម៌ដល់យើងខ្ញុំ ក្នុងរយៈពេល៤ឆ្នាំមកនេះ។

ពិសេសបំផុតនោះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់**សាស្ត្រាចារ្យ ខាត់ ធី** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបាន ខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំ ចាប់តាំងពីថ្ងៃដែលក្រុមយើងខ្ញុំផ្តើមសរសេរ រហូត ដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបាន ចំពោះយើងខ្ញុំ។

ជាចុងក្រោយ យើងខ្ញុំសូមសម្តែងនូវអំណរគុណដល់ប្រធានថ្នាក់ មិត្តល្អ និងសិស្សច្បងទាំងអស់ ដែលបានរួមចំណែកក្នុងការជួយសម្របសម្រួលផ្សេងៗ ការផ្តល់នូវកម្លាំងចិត្ត ពិសេសគឺភាពជឿជាក់មកលើ រូបយើងខ្ញុំដែលសកម្មភាពទាំងនោះគឺជាចំណែកយ៉ាងធំមួយ ក្នុងដំណើរការសរសេរសារណាមួយនេះរហូត បានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។ ហើយជាកិច្ចបញ្ចប់ យើងខ្ញុំសូមឱនកាយលើកដៃសំពះ ប្រណមបួងសួងជូនដល់ មាតាបិតា ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក-លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់រូប ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃាតឃ្លាឡើយ ។

# អារម្ភកថា

នៅក្នុងប្រទេសកម្ពុជា ចំណងអាពាហ៍ពិពាហ៍គឺមានសារៈសំខាន់ខ្លាំងណាស់ ហើយវាក៏ជាដំណាក់កាលមួយមុននឹងឈានទៅដល់ការបង្កើតគ្រួសារមួយដោយស្របច្បាប់។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋខ្មែរមួយចំនួន តែងតែមានការយល់ច្រឡំថា អាពាហ៍ពិពាហ៍តាមបែបប្រពៃណីគឺជាអាពាហ៍ពិពាហ៍មួយដែលស្របច្បាប់ ប៉ុន្តែជាក់ស្តែង វាគ្រាន់តែជាការអនុវត្តន៍ទៅតាមទំនៀមទម្លាប់ប្រពៃណីតែប៉ុណ្ណោះ ហើយការរៀប អាពាហ៍ពិពាហ៍ទៅតាមទំនៀមទម្លាប់ប្រពៃណីនេះ ក៏មិនមានអានុភាពទៅតាមផ្លូវច្បាប់នោះដែរ។

យើងខ្ញុំទាំងពីរនាក់មើលឃើញនូវទិដ្ឋភាពជាក់ស្តែង នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ហេតុនេះហើយទើបធ្វើឲ្យយើងខ្ញុំទាំងពីរនាក់ ចង់ចងក្រងនូវឯកសារមួយចំនួនដែលពាក់ព័ន្ធទៅនឹង អាពាហ៍ពិពាហ៍ ដើម្បីចែករំលែកនូវលក្ខខណ្ឌ និងបែបបទនីតិវិធីផ្សេងៗដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ឲ្យប្រជាពលរដ្ឋខ្មែរមួយចំនួនមានការយល់ដឹងអំពី **នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ពលរដ្ឋខ្មែរ** ជាពិសេសនីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស និងការរៀបអាពាហ៍ពិពាហ៍រវាង ជនអន្តោប្រវេសន៍ ជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា។ ដោយសារតែប្រជាពលរដ្ឋខ្មែរ មួយចំនួនពុំមានការយល់ដឹងទូលំទូលាយអំពីនីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស និងការរៀបអាពាហ៍ពិពាហ៍រវាងជនអន្តោប្រវេសន៍ ឬ ជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ហេតុដូចនេះហើយទើបយើងខ្ញុំពីរនាក់បានសម្រេចចិត្តស្រាវជ្រាវនូវឯកសារសារណាបញ្ចប់ការសិក្សាមួយ(**អំពីអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា**)។ យើងខ្ញុំទាំងពីរនាក់មានជំនឿយ៉ាងមុតមាំថាសារណា បញ្ចប់ការសិក្សាមួយនេះនឹងអាចជួយដល់ប្រជាពលរដ្ឋខ្មែរដែលមានគម្រោងនឹង រៀបអាពាហ៍ពិពាហ៍ ឲ្យមានការយល់ដឹងអំពីលក្ខខណ្ឌមួយចំនួនដែលច្បាប់បានកំណត់ ដើម្បីឲ្យពិធីរៀបអាពាហ៍ពិពាហ៍ ព្រមទាំងចំណងអាពាហ៍ពិពាហ៍របស់ពួកគេស្ថិតនៅបានយូរអង្វែង។ ម្យ៉ាងវិញទៀត សារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំនេះ នឹងអាចជួយពន្យល់បន្ថែមដល់និស្សិតជំនាន់ក្រោយឲ្យយល់ដឹងកាន់តែច្បាស់នូវអាពាហ៍ពិពាហ៍ នៅក្នុងប្រទេសកម្ពុជា។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅមានចំណុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និង អត្ថន័យខ្លឹមសារ អាស្រ័យហេតុនេះសូម លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តា ខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ផង ហើយយើងទាំងពីរនាក់មានភាពរីករាយ យ៉ាងខ្លាំងក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះឲ្យមានភាពល្អប្រសើរ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហា ........ ១

២.ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ១

៣. គោលបំណងនៃការសិក្សា ........ ២

៤.ដែនកំណត់ និងវិសាលភាពនៃការសិក្សា ........ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៦. វិធីសាស្រ្តស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍**

**១.១. ប្រវត្តិនៃអាពាហ៍ពិពាហ៍** ........ ៤

**១.២. លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍** ........ ៦

១.២.១. កំជាប់ពាក្យ ........ ៥

១.២.២. អាយុរបស់បុគ្គលដែលអាចភ្ជាប់ពាក្យ ........ ៦

១.២.៣. លក្ខខណ្ឌទ្វេពន្ធភាព ........ ៦

**១.៣. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍** ........ ៦

១.៣.១. គោលការណ៍ស្ម័គ្រចិត្ត ........ ៦

១.៣.២. ភេទរបស់គូភាគី ........ ៧

១.៣.៣.លក្ខខណ្ឌអាយុសម្រាប់រៀបអាពាហ៍ពិពាហ៍ ........ ៧

១.៣.៤. ការរៀបអាពាហ៏អាពាហ៏របស់អនីតិជន ........ ៨

១.៣.៤.១. អនីតិជន និងនីតិជន ........ ៨

១.៣.៤.២. ជនដែលទទួលបានអត្តាធិនភាព ........ ៨

១.៣.៤.៣.ជននៅក្រោមអាណាព្យាបាលទូទៅ ........ ៩

១.៣.៥. ឧបសគ្គក្នុងការរៀបអាពាហ៍ពិពាហ៍ ... ៩
១.៣.៥.១. ការបាត់ខ្លួនលើសពី៥ឆ្នាំ ... ១០
១.៣.៥.២. ការបាត់ខ្លួនលើសពី១ឆ្នាំ ដោយឧបទ្ទវហេតុ ... ១០
**១.៤. អានុភាពនៃអាពាហ៍ពិពាហ៍** ... ១០
១.៤.១. ការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ ... ១០
១.៤.២. ករណីយកិច្ចរបស់សហព័ន្ធ ... ១១
១.៤.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវនឹងសិទ្ធចូលរួមសកម្មភាពសង្គម ... ១១
១.៤.៤. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា ... ១១
១.៤.៥. ទំនាក់ទំនងសហព័ទ្ធ និងញាតិ ... ១១
១.៤.៦. ប្រព័ន្ធទ្រព្យសម្បិត្តប្តីប្រពន្ធ ... ១២
១.៤.៦.១. ប្រព័ន្ធទ្រព្យប្តីប្រពន្ធតាមកិច្ចសន្យា ... ១២
១.៤.៦.២. ប្រព័ន្ធព្រទ្យសម្បិត្តដែលកំណត់ដោយច្បាប់ ... ១៣

## ជំពូកទី២

## នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍

**២.១. នីតិវិធីសម្រាប់រៀបអាពាហ៍អាពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ** ... ១៤
២.១.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ... ១៤
២.១.២. ការប្រកាសជាសាធារណៈ ... ១៥
២.១.៣. ជនដែលអាចធ្វើបណ្តឹងជំទាស់អំឡុងពេលធ្វើការប្រកាសជាសាធារណៈ ... ១៥
២.១.៤ មូលហេតុជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍ ... ១៦
២.១.៥. ការសម្រេចលើបណ្តឹង ... ១៦
២.១.៦. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ... ១៧
២.១.៧.ការសុំចុះសំបុត្រអាពាហ៍ពិពាហ៍ ... ១៨
២.១.៨. ការចេញសំបុត្រអាពាហ៍ពិពាហ៍ ... ១៨
**២.២.នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស** ... ១៩

២.២.១. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍......................................................................................១៩
២.២.១.១. នីតិវិធីសម្រាប់ជនបរទេស....................................................................................១៩
២.២.១.២. នីតិវិធីសម្រាប់ពលរដ្ឋខ្មែរ.......................................................................................២០
២.២.២. នីតិវិធីសម្រាប់មេឃុំ ចៅសង្កាត់ .......................................................................................... ២១
២.២.៣. រយៈពេលរង់ចាំ ............................................................................................................ ២១
២.២.៤. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន ............................................... ២១
២.២.៤.១. ការពិនិត្យរបស់ថ្នាក់ក្រសួង.................................................................................. ២២
២.២.៤.២. ការពិនិត្យរបស់ថ្នាក់រាជធានី/ខេត្ត........................................................................... ២២
២.២.៤.៣. ការពិនិត្យរបស់ ថ្នាក់ក្រុង ស្រុក ខណ្ឌ ....................................................................... ២២
២.២.៤.៤. ការពិនិត្យរបស់ ថ្នាក់ឃុំ សង្កាត់...............................................................................២៣
២.២.៥. ការចុះសំបុត្រអាពាហ៍ពិពាហ៍ ............................................................................................២៣
**២.៣. អាពាហ៍ពិពាហ៍រវាងជនអន្តោប្រវេសន៍ ឬជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា** ...........................................................................................................២៣

## ជំពូកទី៣

## លក្ខខណ្ឌនៃការហាមឃាត់ និងការបញ្ចប់នៃការរៀបអាពាហ៍ពិពាហ៍

៣.១. លក្ខខណ្ឌហាមឃាត់ការរៀបអាពាហ៍ពិពាហ៍......................................................................២៥
៣.១.១. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព ...................................................................................២៥
៣.១.២. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ................................................. ២៥
៣.១.៣. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត............................................ ២៦
៣.១.៣.១.ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែរផ្ទាល់ ............................. ២៧
៣.១.៣.២. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត............................... ២៧
៣.១.៣.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្ដាយបង្កើតជាមួយអតីតកូនបង្កើត...២៧
៣.១.៣.៤. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬម្ដាយចិញ្ចឹមជាមួយកូនសុំ .............. ២៧
៣.១.៤. ការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ................................................ ២៧

៣.១.៤.១. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ ........ ២៨
៣.១.៤.២. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិពន្ធ ........ ២៩
៣.១.៤.៣. ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិពន្ធ ........ ២៩
៣.១.៥. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ........ ២៩
**៣.២. ការបញ្ចប់អាពាហ៍ពិពាហ៍** ........ ២៩
៣.២.១. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ........ ២៩
៣.២.២. មរណភាពរបស់សហព័ទ្ធ ........ ៣០
៣.២.៣. មោឃភាពនៃអាពាហ៏ពិពាហ៏ ........ ៣០
៣.២.៣.១. មោឃភាពដាច់ខាត ........ ៣០
៣.២.៣.២. មោឃភាពមិនដាច់ខាត ........ ៣១
៣.២.៤. ការលុបចោលអាពាហ៍ពិពាហ៍ ........ ៣២
៣.២.៤.១. អាពាហ៍ពិពាហ៍មិនទាន់គ្រប់អាយុ ........ ៣២
៣.២.៤.២. ឯកពន្ធភាព ........ ៣៣
៣.២.៤.៣. អំឡុងពេលរៀបអាពាហ៍ពិពាហ៍ថ្មី ........ ៣៣
៣.២.៤.៤. ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត ........ ៣៣
៣.២.៤.៥. ការឆបោក ........ ៣៤
៣.២.៤.៦. ការគំរាមកំហែង ........ ៣៤
៣.២.៥. ការអវត្តមាននិងការប្រកាសបាត់ខ្លួន ........ ៣៤
៣.២.៦. ការលែងលះ ........ ៣៥
៣.២.៦.១. មូលហេតុនៃការលែងលះ ........ ៣៥
៣.២.៦.២.លក្ខខណ្ឌនៃការលែងលះ ........ ៣៨
**សេចក្ដីសន្និដ្ឋាន** ........ ៤០
**អនុសាសន៍** ........ ៤១
**គន្ថនិទ្ទេស**

# ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

នៅពេលដែលពេញវ័យ មនុស្សគ្រប់រូបតែងតែស្វែងរកគូស្រករ ឬ ក៏មានការផ្សំផ្គុំពីឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ ដើម្បីរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍គឺមានគោលបំណងបង្កើតជាគ្រួសារមួយ និងរស់នៅដោយសុភមង្គល ហើយអាពាហ៍ពិពាហ៍ គឺជាចំណងផ្លូវច្បាប់មួយរវាងបុរស និង ស្រ្តី ដែលរស់នៅពឹងពាក់គ្នាទៅវិញទៅមក។ បើក្រឡេកមើលទៅសកលលោកវិញ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈផ្សេងៗពីគ្នា ទៅតាមប្រពៃណី ទំនៀមទំលាប់ សាសនា និងច្បាប់របស់ពួកគេ ដែលជាហេតុនាំឲ្យមានប្រទេសនីមួយៗ មានការប្រព្រឹត្តទៅនៃការរៀបអាពាហ៍ពិពាហ៍មានភាពខុសៗគ្នា។ចំពោះប្រទេសកម្ពុជាវិញគឺមានការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណី និងការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី គឺទំនៀមទម្លាប់មួយដែលមានតាំងពីបុរាណមក ដែលប្រជាជនខ្មែរទទួលស្គាល់ និងជាសីលធម៌ សង្គមផងដែរ ហើយក៏ជាសារប្រកាសជាសាធារណៈថា បុរស និងនារីនោះគឺជាស្វាមីភរិយានឹងគ្នាដោយមានការដឹងឮពីសាធារណជន និងសាច់ញាតិ បងប្អូនជាដើម ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីបែបនេះ មិនមានអានុភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចងភាគីទាំងពីរនោះទេ។ ការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គឺបង្កើតជាចំណងគតិយុត្តិ ចងភ្ជាប់នីតិបុគ្គលឲ្យក្លាយជាសហព័ទ្ធ តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍ នាំឲ្យមានអានុភាពតាមផ្លូវច្បាប់ដែលច្បាប់ប្រទេសកម្ពុជាទទួលស្គាល់ និងការពារ។

ការរៀបអាពាហ៍ពិពាហ៍មានច្រើនប្រភេទដូចជាៈ ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេស, ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរតែនៅបរទេស, ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសតែនៅបរទេស, និងការរៀបអាពាហ៍ពិពាហ៍រវាងជនអន្តោប្រវេសន៍ ឬ ជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ដើម្បីរក្សាប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវប្រធានបទនេះ ក្រុមខ្ញុំបាទ សូមលើកឡើងចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ២.ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ដោយសារតែប្រជាពលរដ្ឋមួយចំនួនមិនបានយល់ច្បាស់អំពីលក្ខខណ្ឌ និងបទដ្ឋានគតិយុត្តិ ផ្សេងៗនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា ទើបអាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់នៅតែមាន ហើយបន្តរាតត្បាតសង្គមឥតឈប់ឈរ។ អនីតិសង្វាសដែលជាមូលហេតុចម្បងនៃការស្វែងរកមាតុភាព និងបិតុភាព ក៏នៅបន្តកើតឡើងផងដែរ។ នេះហើយជាមូលហេតុមួយចំនួនដែលត្រូវបានបង្កើតឡើងដោយអាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់។

បញ្ហាទាំងនេះបណ្ដាលមកពីកង្វះខាតនូវការយល់ដឹងអំពីការរៀបអាពាហ៍ពិពាហ៍ទាំងអស់ ពុំមានការផ្សព្វផ្សាយឲ្យទំលំទូលាយនៃការរៀបអាពាហ៍ពិពាហ៍ ភាពចន្លោះប្រហោងនៃការអនុវត្តច្បាប់នៅកម្ពុជាជាដើម។

ហេតុដូចនេះហើយ បញ្ហាចោទឡើងថា ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ តើគេត្រូវគោរពលក្ខខណ្ឌគតិយុត្តអ្វីខ្លះ? តើនីតិវិធីផ្សេងៗនៃអាពាហ៍ពិពាហ៍ត្រូវប្រព្រឹត្តទៅយ៉ាងដូចម្ដេច? តើមានមូលហេតុអ្វីខ្លះ ដែលបណ្ដាលឲ្យមានបញ្ហាមិនចេះចប់នៅក្នុងអាពាហ៍ពិពាហ៍? អ្នកដែលរស់នៅជាមួយគ្នាជារបៀប អនីតិសង្វាស មានសិទ្ធិប្ដឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍បានឬទេ?

## ៣. គោលបំណងនៃការសិក្សា

ចំពោះគោលបំណងនៃការសិក្សាចំពោះកិច្ចការស្រាវជ្រាវមួយនេះ ដើម្បីធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើបញ្ហាក៏ដូចជា កត្តាប៉ះពាល់ដែលទាក់ទិនជាមួយការការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា។ គោលបំណងទាំងនោះរួមមាន៖

- ស្វែងយល់ពីលក្ខខណ្ឌផ្សេងៗនៃការរៀបអាពាហ៍ពិពាហ៍
- ស្វែងយល់អំពីទិដ្ឋភាពច្បាប់ដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍
- ស្វែងយល់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឬ ជនបរទេស
- ស្វែងយល់ពីការអនុវត្តជាក់ស្ដែង និងទ្រឹស្ដីច្បាប់ដែលពាក់ព័ន្ធ
- ស្វែងយល់អំពីផលប៉ះពាល់ដែលកើតឡើងដោយសារការមិនអនុវត្តទៅតាមនីតិវិធីច្បាប់
- ធ្វើការសន្និដ្ឋាន និងផ្ដល់អនុសាសន៍ដើម្បីអាចធ្វើការកែតម្រូវចំពោះបញ្ហា ចងក្រងទុកជាឯកសារសម្រាប់ជាស្នាដៃ និង ចំណុចផ្ដើមនៃការស្រាវជ្រាវបន្តសម្រាប់និស្សិតជំនាន់ ក្រោយៗទៀត។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា

សារណានេះ មានដែនកំណត់គ្របដណ្ដប់ទៅលើទិដ្ឋភាពច្បាប់ ក៏ដូចជាការអនុវត្តច្បាប់ដែលទាក់ទង ទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះ មានវិសាលភាពក្នុងក្របខណ្ឌ នៃច្បាប់កម្ពុជា ដែលរួមមានក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាអនុក្រឹត្យ ឬ ប្រកាសផ្សេងៗ ដែលទាក់ទងផងដែរ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទស្រាវជ្រាវនេះ គឺអាចធ្វើឲ្យអ្នកសិក្សាទាំងឡាយ យល់ដឹងកាន់តែស៊ីជម្រៅអំពី ប្រវត្តិនៃអាពាហ៍ពិពាហ៍ លក្ខខណ្ឌផ្សេងៗ និងអានុភាពនៃអាពាហ៍ពិពាហ៍ ព្រមទាំងលក្ខខណ្ឌនៃការហាមឃាត់ និងការបញ្ចប់ការរៀបអាពាហ៍ពិពាហ៍ និងនីតិវិធីមួយចំនួនក្នុងការរៀបអាពាហ៍ពិពាហ៍ ផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺពឹងផ្អែកទៅលើ សុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា , សុំមតិ យោបល់ពី មេធាវី ក្រឡាបញ្ជី, ឯកសារគតិយុត្ត (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំដែល ទាក់ទងទៅនឹង ការរៀបអាពាហ៍ពិពាហ៍)ឯកសារដែលទទួលបានពីប្រព័ន្ធអ៊ុនធើណែត, ឯកសារពីបណ្ណាល័យ សៀវភៅច្បាប់ឯកសារដែលទទួលបានពីសាស្ត្រាចារ្យ, ឯកសារដែលទទួលបានពីសិស្សច្បង, សុំមតិយោបល់ពី អ្នកដែលមានបទពិសោធយល់ដឹងច្រើនអំពីការរៀបអាពាហ៍ពិពាហ៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យកាន់តែជ្រាបកាន់តែច្បាស់នៃការរៀបអាពាហ៍ពិពាហ៍មួយស្របច្បាប់ និងនីតិវិធីសម្រាប់រៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា សារណានេះ បានលើកយកការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា ចែកចេញជា២ជំពូក។ ជំពូកទី១ បកស្រាយអំពី សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ និង នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍។ រីឯ ជំពូកទី២ បកស្រាយអំពី លក្ខខណ្ឌនៃការហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍ និង ការបញ្ចប់អាពាហ៍ពិពាហ៍។

# ជំពូកទី១

# សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍តាំងពីបុរាណកាលមក ប្រជាជនខ្មែរតែងតែមានការរៀបចំគូស្រករសម្រាប់កូនប្រុសស្រីរបស់ខ្លួននៅពេលដល់វ័យរៀបអាពាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍ពីមុនប្រជាជនខ្មែរ តែងតែធ្វើទៅតាមប្រពៃណី។ លុះមកដល់ពេលបច្ចុប្បន្ន វិសាលភាពច្បាប់មានការទូលំទូលាយជាងមុន ធ្វើឲ្យការរៀបអាពាហ៍ពិពាហ៍នោះមានលក្ខណៈស្របច្បាប់។ ជាធម្មតាប្រជាជនខ្មែរតែងតែមានការយល់ច្រលំចំពោះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីថាជាអាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែបច្ចុប្បន្នការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីគ្រាន់តែជាការអនុវត្តទៅតាមទំនៀមទំលាប់ដែលមានតាំងពីដូនតាមកម្ល៉េះ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ទៅបាន លុះត្រាតែបុរស នឹងស្ត្រីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ បានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ ទើបអាពាហ៍ពិពាហ៍នោះមានលក្ខណៈស្របច្បាប់។

ការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ ដែលប្តេជ្ញា ថាខ្លួននឹងរួមរស់ជាមួយគ្នា បង្កើតជាចំណងគតិយុត្តក្នុងនាមជាប្តី ប្រពន្ធ ដោយទំនាក់ទំនងនេះគឺត្រូវបានច្បាប់ទទួលស្គាល់ លុះត្រាតែអ្នកទាំងពីរត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា។[1] ទោះបីជាអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយដែលមិនដូចកិច្ចសន្យាដទៃទៀតក៏ដោយ ក៏សហព័ទ្ធមិនអាចរំលាយអាពាហ៍ពិពាហ៍តាមទំនើងចិត្តបានឡើយ។ ប៉ុន្តែសហព័ទ្ធអាចបញ្ចប់អាពាហ៍ពិពាហ៍របស់គេបានដោយស្របទៅតាមនីតិវិធីជាក់លាក់ដែលមានចែងនៅក្នុងច្បាប់បានកំណត់ប៉ុណ្ណោះ។ បន្ថែមពីនេះ អាពាហ៍ពិពាហ៍ក៏ជាទំនាក់ទំនងយូរអង្វែង រួមរស់សុខទុក្ខជាមួយគ្នា និងការបង្កើតគ្រួសារមួយ រហូតទាល់តែមរណៈភាពរបស់សហព័ទ្ធណាមួយ។ ម្យ៉ាង ទៀតអំឡុងពេលអាពាហ៍ពិពាហ៍ ភាគីបានបង្កើតនូវចំណងរវាងគ្នាជាច្រើនដូចជា មានបុត្រ, ការប្រើប្រាស់នាមត្រកូល, ទ្រព្យសម្បត្តិរួម ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀត។

## ១.១ ប្រវត្តិនៃអាពាហ៍ពិពាហ៍

ប្រវត្តិនៃអាពាហ៍ពិពាហ៍ខ្មែរគេមិនដឹងអំពីការចាប់បដិសន្ធិពិតប្រាកដនៅឡើយទេតែតាមឯកសារជាច្រើនបានសន្និដ្ឋានស្រដៀងគ្នាថាអាពាហ៍ពិពាហ៍ខ្មែរបានចាប់ផ្តើមតាំងពីនៅក្នុងសម័យហ្វូណនឬសម័យអាណាចក្រភ្នំ ឬសម័យនគរគោកធ្លក នៅដើមសតវត្សទី១នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទហ៊ុន ទៀន និងព្រះនាងលីវយី ។[2]

តាមប្រវត្តិសាស្ត្រ ការត្រៀមរៀបអាពាហ៍ពិពាហ៍នៅក្នុងសង្គមខ្មែរ បានប្រើរយៈពេលយូរថ្ងៃ ឬ ខែមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ កាលដើមឡើយ កូនប្រុសត្រូវទៅបម្រើក្រុមគ្រួសារខាងស្រី អស់រយៈ

[1] មាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសា លេខ ៥៦ក្រ, ២៦កក្កដា ១៩៨៩

[2] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, បណ្ឌិត គនឃឿន ភាគ១ពោះពុម្ពឆ្នាំ២០១៣ទំព័រ១៥

ពេលច្រើនថ្ងៃ ឬ ច្រើនខែ ដូចជាពុះអូស រែកទឹក ធ្វើស្រែ ធ្វើចំការ ជំនួញជួញដូរជាដើម ដើម្បីឲ្យគ្រួសារ ខាងស្រីមើលពីអត្តចរិត និងកិរិយាមារយាទ។ ការទៅបម្រើផ្ទះខាងស្រី គឺមិនទទួលបានប្រាក់នោះទេ គ្រាន់តែទទួលបានម្ហូបអាហារសម្រាប់បរិភោគប៉ុណ្ណោះ។ ប្រសិនបើគ្រួសារខាងស្រីមិនពេញចិត្ត អាចផ្តាច់ពាក្យវិញពេលណាក៏បាន។

ការរៀបអាពាហ៍ពិពាហ៍ពីបុរាណ គឺធ្វើឡើងរយៈពេល៣ថ្ងៃ តែបច្ចុប្បន្នកាត់មកនៅត្រឹម២ថ្ងៃតាម កម្មវិធីដូចជា៖ **ថ្ងៃទី១** ថ្ងៃចូលរោង គឺជាថ្ងៃដែលគេតំឡើងរោងនៅផ្ទះខាងស្រី ជាថ្ងៃដែលខាងស្រីត្រូវ រៀបចំសែនក្រុងពាលីដើម្បីសុំសេចក្តីសុខ ក្នុងថ្ងៃមង្គលការ តង្វាយត្រូវរៀបលក្ខណៈជាគូៗ និងមាន ពិធីសូត្រមន្តនាពេលរសៀល ដើម្បីចម្រើនព្រះបរិត្ត និងបណ្តេញពួកផ្លូវងងឹតក្នុងពិធីមង្គលផងដែរ។ **ថ្ងៃទី២** ជាថ្ងៃដែលគេប្រារព្ធពិធីមង្គលការ កិច្ចចាប់ផ្តើងបើកដោយពិធីហែជំនួន។ ពិធីហែជំនួនគេកំណត់យកម៉ោង ដង្ហែ៧ព្រឹក ដើម្បីហែគ្រឿងភស្តុភាបណ្ណាការ ទៅផ្ទះខាងស្រីដែលគេកំណត់យកបណ្ណាការ ៣៦មុខ ដែល បងប្អូនខ្មែរច្រទ្បំថាផ្លែឈើ ៣៦មុខរហូតមកដល់បច្ចុប្បន្ន។ អ្នកចូលរួមហែជំនួនគឺចង់ដឹងពីរបៀបរៀបរយ ខាងប្រុស ហែជំនួនត្រូវមានលក្ខណៈហែស្របនិងទល់មុខរោងការ ហាមការហែបញ្ច្រាសរោងការ ពីព្រោះវា អាចធ្វើឲ្យបែកបាក់គ្នា ឬ រកស៊ីតឹងតែង។ ផ្លែឈើដែលហាមក្នុងថ្ងៃហែជំនួនគឺមានតែមួយប៉ុណ្ណោះ គឺផ្លែ ត្របែក ព្រោះវាតំណាងឲ្យភាពបែកបាក់។ នៅមុខក្លោងទ្វារការគេត្រូវរៀបចំអ្នកកាន់ផ្កា២នាក់មកកាន់ខ្សែ បិទក្លោងទ្វារ ដើម្បីបញ្ជាក់ពីភាពបរិសុទ្ធរបស់ខាងស្រី ហើយនៅពេលខាងប្រុសមកដល់ អ្នកកំដរដែល កាន់ឆ័ត្រ២នាក់ និងម្នាក់ទៀតដែលទំនេរ ត្រូវយកដាវហុចទៅកូនកំលោះ ដើម្បីកាត់ខ្សែរចំណងនោះ ទើបគេឲ្យកូនក្រមុំចេញមក។ បន្ទាប់មកពិធីសែនមេបា និងជំនាងផ្ទះ ដោយគេដាក់ចំណីក្នុងកន្ទោង លើកដាក់ ទៅក្នុងច្រមជាកន្លែងសម្រាប់តង្វាយជូនដល់ជំនាងផ្ទះ និងរៀបចំម្ហូអាហារមួយតុ ឬ មួយថាសដើម្បីប្រាប់ជាដំណឹងកុំឲ្យមេបា ជីដូនជីតាប្រកាន់ខឹង។ ពិធីកាត់សក់ជាដំបូងអាចារ្យបួងសួងសុំរបស់ទិព្វពីទេវតា ដែលមានប្រុសស្រីមួយគូចេញរាំច្រៀងជាតំណាង ហើយឧបកិច្ចកាត់សក់ក្រាសមាស កម្រៃប្រាក់ កញ្ចក់ ផ្ទិលទឹក។ ឪពុកម្តាយត្រូវកាត់សក់ គឺតំណាងឲ្យការកាត់ចិត្ត និងដោះលែងសិទ្ធិឃុំគ្រងលើជីវិតកូន ទាំងខាងប្រុស និងខាងស្រី។ ពិធីរាំបើកវាំងននអញ្ជើញកូនក្រមុំ ពិធីសំពះផ្ទឹម បន្ទាប់មកពិធីអុជទៀនបង្វិល ប្រាំពីរជុំ បន្ទាប់មកពិធីសែនចងដៃ រួចបញ្ចប់ដោយពិធីបាចផ្កាស្លា និងពីធីតោងស្បៃចូលក្នុងបន្ទប់។ ពិធីរៀបភោជនីអាហារជូនភ្ញៀវ គឺគេនិយមរៀបចំពិធីជប់លៀងភ្ញៀវនាពេលយប់ជាមួយនឹងការច្រៀងរាំ កំសាន្ត។ ក្រោយបញ្ចប់ពិធីមង្គលការ ទើបគូស្វាមីភរិយាសន្មតជាថ្ងៃជ័យមង្គលសម្រាប់ការចាប់ផ្តើមដំណើរជីវិតរួមគ្នា ។[3]

[3] សៀវភៅសិក្សាសង្គមថ្នាក់ទី៩ អំពីពិធីរៀបមង្គលការ, ក្រសួងអប់រំយុវជន និងកីឡា បោះពុម្ពឆ្នាំ១៩៩៩

## ១.២. លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍

មុខនឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍ ប្រជាជនខ្មែរមួយចំនួនក៏មានជាការធ្វើពិធីកំជាប់ពាក្យ ដែលបានបន្សល់ទុកភ្ជាប់តាំងពីដូនតាជំនាន់មុនតាមបែបប្រពៃណី ហើយតាមបញ្ញត្តិច្បាប់ក៏បានកំណត់ផងដែរ។

### ១.២.១. កំជាប់ពាក្យ

កំជាប់ពាក្យ ឬ ពិធីភ្ជាប់ពាក្យ ជាពិធីប្រពៃណីខ្មែរដែលមានតាំងពីបរមបុរាណមក ហើយក៏ជាពិធីដ៏ធំ មួយ មុននឹងឈានដល់ពិធីរៀបអាពាហ៍ពិពាហ៍។ កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្តីសន្យារវាងបុរស និង នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគតនិងដោយធ្វើពិធីកំជាប់ពាក្យ។[4] កំជាប់ពាក្យភាគច្រើន ដែលការនិយាយរបស់ប្រជាជនខ្មែរ ហៅជាប្រចាំ ថា "ការភ្ជាប់ពាក្យ" ដែលជាពិធីតាមទំនៀមទំលាប់ប្រពៃណី និងច្បាប់ក៏បានទទួលស្គាល់ផងដែរ។

សព្វថ្ងៃនេះពិធីភ្ជាប់ពាក្យនៅតែមានការពេញនិយមធ្វើជាទូទៅ មុននឹងបុត្រធីតារបស់គេ ឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយនៅក្នុងគ្រួសារដែលមានជីវភាព ធូរធារបាន រៀបចំពិធីនេះយ៉ាងអធិកអធមផងដែរ ប៉ុន្តែសម្រាប់អ្នកដែលមានជីវភាពមធ្យម ក៏បានរៀបចំពិធីនេះតូចល្មមទៅតាមជីវភាពរបស់ពួកគេ ហើយនឹងអ្នកដែលពុំសូវមានលទ្ធភាព ក៏បានលើកពិធីនេះចោលក៏មានដែរ។ ពិធីនេះ គេច្រើនធ្វើមួយព្រឹក ឬ មួយថ្ងៃពេញតែម្តង និងមានចាស់ទុំភាគីទាំងសងខាង អ្នកផ្លូវចៅមហា ព្រមទាំងភ្ញៀវជួយធ្វើជាសាក្សី និងដឹងឮផងដែរ។ ពិធីភ្ជាប់ពាក្យ មានការបំពាក់ចិញ្ចៀន ឬ គ្រឿងអលង្ការ ឬ ប្រគល់វត្ថុអនុស្សាវរីយ៍ ផ្សេងៗដល់អនាគតស្វាមី ឬ ភរិយាទៀតផង ទៅតាមការនិយម និងតាមសមត្ថភាព ធនធានដែលពួកគេមាន។ កំជាប់ពាក្យនេះទុកជាបានការ លុះត្រាតែភាគីបានធ្វើពិធីនេះជាឱឡារិកមួយដែលហៅថា ពិធីលើកស្លា។

### ១.២.២. អាយុរបស់បុគ្គលដែលអាចភ្ជាប់ពាក្យ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានកំណត់លក្ខខណ្ឌអាយុសម្រាប់ពិធីកំជាប់ពាក្យឬ ពិធីភ្ជាប់ពាក្យដូចទៅនឹងការរៀបអាពាហ៍ពិពាហ៍នោះទេ។ ដោយហេតុថា ពិធីកំជាប់ពាក្យ គ្រាន់តែជាកិច្ចសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃអនាគត ពោលគឺមិនទាន់បានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធនៅឡើយ។ ជាក់ស្តែង ភាគីដែលបានធ្វើពិធីកំជាប់ពាក្យ គេអាចទុករយៈពេលច្រើនឆ្នាំដើម្បីរៀបអាពាហ៍ពិពាហ៍ក៏បានអាស្រ័យទៅតាមការចាំបាច់របស់គូភាគី ដូចជាមិនទាន់ដល់វ័យរៀបអាពាហ៍ពិពាហ៍ បន្តការសិក្សា ឬ នៅមើលចិត្តគំនិត ផ្សេងៗទៀតជាដើម។

[4] មាត្រា៩៤៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ក្នុងករណីដែលភាគីជាអនីតិជន (អាយុក្រោម១៨ឆ្នាំ) បានធ្វើកំជាប់ពាក្យ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានកំណត់ថា ត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលទេ តែនៅក្នុងក្រមរដ្ឋប្បវេណីពីសង្គមចាស់គឺភាគីជាអនីតិជននឹងអាចធ្វើពិធីកំជាប់ពាក្យនេះបាន លុះត្រាតែមានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលជាមុនសិន។[5]

**១.២.៣. លក្ខខណ្ឌទ្វេពន្ធភាព**

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធ នៅក្នុងបីថ្នាក់រាប់ទាំងថ្នាក់ទីបីផង។ ដូច្នេះរាល់អាពាហ៍ពិពាហ៍ដែលធ្វើឡើងរវាងឪពុក ឬ ម្តាយក្មេក និងកូនប្រសា ជីដូន ជីតា និងចៅប្រសារ បងថ្លៃ ឬប្អូនថ្លៃ និងត្រូវបានលុបចោល ។

ប្រសិនបើ អាពាហ៍ពិពាហ៍មុនមិនទាន់បានរំលាយតាមផ្លូវច្បាប់ភាគីបុរស ឬនារីមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ពីព្រោះជាករណីទ្វេពន្ធភាព។

## ១.៣. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

**១.៣.១. គោលការណ៍ស្ម័គ្រចិត្ត**

បុរស នារីមានសិទ្ធិស្មើគ្នាគ្រប់វិស័យទាំងអស់ ពិសេសក្នុងអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[6] ដូចនេះភាគីទាំងសងខាងត្រូវតែមានការស្ម័គ្រចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលមានគោលបំណងរួមរស់ជាមួយគ្នា ប្រសិនបើភាគីទាំងសងខាងពុំមានការព្រមព្រៀង នោះការរៀបអាពាហ៍ពិពាហ៍ពុំអាចធ្វើឡើងបានឡើយ។

ការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ឈរលើគោលការណ៍ស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្ត ដែលពេល ខ្លះពិបាកកំណត់ណាស់ ដោយសារតែប្រទេសកម្ពុជាមានប្រពៃណីទំនៀមទំលាប់ច្រើន។ ហេតុដូចនេះហើយ ទើបកូនៗ (ពិសេសកូនស្រី) ត្រូវស្តាប់តាមបង្គាប់ឪពុកម្តាយ ជីដូនជីតាក្នុងរឿងអាពាហ៍ពិពាហ៍ដែលមានពាក្យ ស្លោកមួយពោលថា ( **នំមិនធំជាងនាឡិ** )។ មានន័យថាកាលណានៅពេលកូនៗឈានដល់វ័យរៀបអាពាហ៍ពិពាហ៍ គឺទុកឲ្យឪពុកម្តាយ ជាអ្នកសម្រេចចិត្តជំនួសសាមីខ្លួន។ ប៉ុន្តែសព្វថ្ងៃ កូនចៅប្រុសស្រី មានសិទ្ធិសេរីភាពជាងមុនក្នុងការជ្រើសរើសគូស្រករ ដោយសារតែមានការរីកចម្រើននៃសិទ្ធិសេរីភាព ការសិក្សាអប់រំ និងទទួលវប្បធម៌ខ្លះៗពីបរទេស។

---

[5] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍ភាគ១, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០១៣ទំព័រទី២៣

[6] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

### ១.៣.២. ភេទរបស់គូភាគី

ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវធ្វើឡើងរវាងបុរស និងនារី។[7] ចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយភេទដូចគ្នាអាពាហ៍ពិពាហ៍នោះពុំត្រូវបានច្បាប់ទទួលស្គាល់ឡើយ។ ច្បាប់ប្រទេសកម្ពុជាមិនទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍ដែលមានភេទដូចគ្នានោះទេ ពុំដូចជាបណ្តាលប្រទេសមួយចំនួននៅលើសកលលោក ដែលទទួលស្គាល់ឲ្យអ្នកដែលមានភេទដូចគ្នារួមរស់ជាមួយគ្នា និងអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់បានឡើយ។

ករណីជាក់ស្តែងមួយចំនួន នៅក្នុងប្រទេសកម្ពុជាទៅតាមបណ្តាញព័ត៌មាន និងបណ្តាញសង្គម មានការចុះផ្សាយអំពីមនុស្សដែលមានភេទដូចគ្នា រួមរស់ជាមួយគ្នា ទោះបីជាច្បាប់មិនទទួលស្គាល់ក៏ដោយ ពោលគឺពួកគេរស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាសដែលមិនស្របជាមួយនិងលក្ខខណ្ឌច្បាប់។

### ១.៣.៣.លក្ខខណ្ឌអាយុសម្រាប់រៀបអាពាហ៍ពិពាហ៍

បុរស នារី ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ លុះត្រាតែភាគីទាំងសងខាងគ្រប់អាយុ១៨ឆ្នាំ ទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាពហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុយ៉ាងតិចចាប់ពី១៦ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះជាមុនសិន។[8]

ដោយផ្អែកលើក្រមរដ្ឋប្បវេណីសង្គមចាស់ បានកំណត់ថា បុរសមានអាយុមិនដល់១៧ឆ្នាំ រីឯនារីមានអាយុមិនដល់១៤ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ [9]ចំណែកឯច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩បានកំណត់ថា បុរសត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងរីឯនារីត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[10]

ទោះបីជាយ៉ាងណាក៏ដោយ ជនប្រុសស្រីទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន ដោយការសម្រេចចិត្តរបស់ខ្លួន និងមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលឡើយ ពោលគឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានផ្តល់សិទ្ធិពេញលេញដល់ពលរដ្ឋខ្មែរក្នុងការសម្រេចចិត្តជ្រើសរើសដៃគូរ ដើម្បីរៀបអាពាហ៍ពិពាហ៍។

[7] មាត្រា២ នៃច្បាប់ស្តីពីឯកពន្ធភាព ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃ០៦ ខែតុលា ឆ្នាំ២០០៦

[8] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[9] មាត្រា១១៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០

[10] មាត្រា៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ នឹងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩

### ១.៣.៤. ការរៀបអាពាហ៍អាពាហ៍របស់អនីតិជន

ភាគីដែលជាអនីតិជនដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ ត្រូវតែមានអាយុយ៉ាងតិចចាប់១៦ឆ្នាំឡើងទៅ ទើបច្បាប់អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បាន ដោយមានលក្ខខណ្ឌដូចខាងក្រោមៈ

#### ១.៣.៤.១. អនីតិជន និងនីតិជន

បុរស នារី មានបំណងរៀបអាពាហ៍ពិពាហ៍ តែភាគីម្ខាងមានអាយុមិនតិចជាង១៦ឆ្នាំ ហើយភាគីម្ខាងទៀតមានអាយុ១៨ឆ្នាំឡើងទៅ ត្រូវតែមានការយល់ព្រមពីឪពុកម្ដាយ ឬ អាណាព្យាបាលរបស់អនីតិជននោះ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[11]

#### ១.៣.៤.២. ជនដែលទទួលបានអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកជានីតិជន។[12] ដូចនេះ អនីតិជនដែលទទួលបានអត្តាធីនភាព អាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្ដាយ ឬ អាណាព្យាបាល។

ក្នុងករណីដែល អាពាហ៍ពិពាហ៍នោះកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីនភាព និង អនីតិជនចាំបាច់ត្រូវមានការយល់ព្រមពីឪពុកម្ដាយរបស់អនីតិជននោះទើបអាចរៀបអាពាហ៍ពិពាហ៍បាន។

ប្រសិនបើអាពាហ៍ពិពាហ៍នោះកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានអត្តាធីនភាពដូចគ្នា ពួកគេអាចអាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្ដាយឡើយ។

**តារាងទី១៖ ស្ដីពីភាពចាំបាច់ ឬ មិនចាំបាច់របស់អំណាចមេបា ឬ អ្នកអាណាព្យាបាលទូទៅ**

| ករណី | អាយុរបស់ភាគី | | ការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល |
|---|---|---|---|
| | អាយុភាគីម្ខាង | អាយុភាគីម្ខាងទៀត | |
| ១ | នីតិជន | នីតិជន | មិនចាំបាច់យល់ព្រម |
| ២ | នីតិជន | អនីតិជន (អាយុចាប់ពី១៦ដល់ក្រោម ១៨ឆ្នាំឡើង) | ភាគីអនីតិជនចាំបាច់ត្រូវតែមានការយល់ព្រមជាមុនសិន |

[11] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[12] មាត្រា២២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

| | | | |
|---|---|---|---|
| ៣ | ជនទទួលបាននៅអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម ១៨ឆ្នាំ) | នីតិជន | មិនចាំបាច់មានការយល់ព្រម |
| ៤ | ជនទទួលបាននៅអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម ១៨ឆ្នាំ) | អនីតិជន (អាយុចាប់ពី១៦ដល់ក្រោម ១៨ឆ្នាំឡើង) | ភាគីដែលជាអនីតិជន ចាំបាច់ត្រូវតែមានការយល់ព្រម |
| ៥ | ជនទទួលបាននៅអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម ១៨ឆ្នាំ) | ជនទទួលបាននៅអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) | មិនចាំបាច់មានការយល់ព្រម |

**១.៣.៤.៣.ជននៅក្រោមអាណាព្យាបាលទូទៅ**

ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជនវិកលចរិត ដែលជានីតិជន អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ហើយការដែលជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជនវិកលចរិត ចង់រៀបអាពាហ៍ពិពាហ៍ អាចសម្រេចចិត្តដោយខ្លួនឯងបាន និងអាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅដែលគ្រប់គ្រងជនវិកលចរិតនោះទេ។[13]

**១.៣.៥. ឧបសគ្គក្នុងការរៀបអាពាហ៍ពិពាហ៍**

កាលណានៅពេលដែល សហព័ទ្ធណាម្នាក់ អវត្តមាន ឬ បាត់ខ្លួន ហើយសហព័ទ្ធម្ខាងទៀតនៅរស់ដោយមានភាពលំបាកក្នុងការគ្រប់គ្រងគ្រួសារ កូននៅក្នុងបន្ទុក ជាពិសេសការសម្រេចចិត្តដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។

អវត្តមាន សំដៅដល់បុគ្គលណាម្នាក់ដែលបានចេញពីលំនៅដ្ឋាន ឬ ទីសំណាក់ដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួល។

ការបាត់ខ្លួន សំដៅដល់ករណីដែលបុគ្គលណាម្នាក់ពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ដូចជាករណីដែលបុគ្គលដែលចូលទៅក្នុងតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាលិចទឹក ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗទៀតដូចជា ការរញ្ជួយដី អគ្គិភ័យ ស៊ូនាមីការ

[13] មាត្រា៩៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

រអិលផ្ទាំងទឹកកកពីភ្នំជាដើម ដែលអាចនាំឲ្យទទួលមរណៈភាព ហើយពុំមានដំណឹងច្បាស់លាស់ថាអ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព។ ក្នុងករណីដែលសហព័ទ្ធរបស់អ្នកដែលអវត្តមាន មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីមិនមានសិទ្ធិដើម្បីនឹងរៀបអាពាហ៍ពិពាហ៍ថ្មីឡើយ ពីព្រោះអ្នកដែលអវត្តមាន អាចមានលទ្ធភាពនឹងវិលត្រឡប់មកវិញ។

ប៉ុន្តែក្នុងករណីដែលបុគ្គលអវត្តមាន មានរយៈពេលយូរ គេអាចប្រកាសអំពីការបាត់ខ្លួន ឬ ក្នុងករណីដែលបុគ្គលបានជួបនឹងឧបទ្ទវហេតុដែលគេគ្មានសង្ឃឹមថា នឹងមានជីវិតមកវិញ ហើយសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែមានលក្ខខណ្ឌដូចជា៖

### ១.៣.៥.១. ការបាត់ខ្លួនលើសពី៥ឆ្នាំ

ក្នុងករណីដែលអវត្តមានរបស់សហព័ទ្ធណាម្នាក់ មានរយៈពេលលើសពី៥ឆ្នាំហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកដែលអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកដែលមានផលប្រយោជន៍ផ្សេងទៀត អាចស្នើសុំទៅតុលាការដើម្បីប្រកាសអំពីការបាត់របស់អ្នកដែលអវត្តមានយូនោះបាន ហើយសហពទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ ឬប្តីថ្មីទៀតបាន ក្រោយពេលដែលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួននោះ។

### ១.៣.៥.២. ការបាត់ខ្លួនលើសពី១ឆ្នាំ ដោយឧបទ្ទវហេតុ

ក្នុងករណី ដែលអវត្តមានរបស់សហព័ទ្ធណាម្នាក់ជួបនឹងឧបទ្ទវហេតុដូចជា ចូលទៅក្នុងតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាលិចទឹក ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗទៀត ដូចជាការរញ្ជួយដី អគ្គិភ័យ ស៊ូនាមី ការរអិលផ្ទាំងទឹកកកពីភ្នំជាដើម ដែលអាចនាំឲ្យទទួលមរណៈភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ដែលមានរយៈពេលលើស១ឆ្នាំទៅ ក្រោយពីជួបឧបទ្ទវហេតុនោះ តុលាការអាចប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលនោះ តាមពាក្យសុំរបស់ សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្តាយ ឬ អាណាព្យាបាល ឬ អ្នកដែលមានផលប្រយោជន៍ផ្សេងទៀត ហើយ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីបាន ក្រោយពេលដែលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួន ។[14]

## ១.៤. អានុភាពនៃអាពាហ៍ពិពាហ៍

### ១.៤.១. ការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ

ផ្អែកទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធអាចប្រើប្រាស់នាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួនដែលមាននៅមុនពេលរៀប

[14] មាត្រា៩៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

អាពាហ៍ពិពាហ៍បាន។[15] ជាក់ស្តែងក្នុងសង្គម ការប្រើប្រាស់នាមត្រកូលប្តី ប្រពន្ធ គេសង្កេតឃើញថា ភាគច្រើន មានតែភាគីប្រពន្ធតែប៉ុណ្ណោះ ដែលយកនាមត្រកូលប្តីមកប្រើ ជាពិសេសអ្នកដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់ ( សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលឈ្មោះភរិយារបស់លោកគឺ សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន) ។

### ១.៤.២. ករណីយកិច្ចរបស់សហព័ន្ធ

ប្តី ប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។[16] ក្រោយពេលរៀប អាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរមានករណីយកិច្ចរួមរស់សហការគ្នា ជួយរំលែកទុក្ខធុរៈទៅវិញទៅមក និងចូល រួមដោះស្រាយបញ្ហាទាំងអស់គ្នា។

### ១.៤.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមសកម្មភាពសង្គម

ទោះបីជាអាពាហ៍ពិពាហ៍ ជាចំណងចងភ្ជាប់កាតព្វកិច្ចជាមួយគ្នារវាង ប្តី ប្រពន្ធ និងជាចំណងចងភ្ជាប់គ្នា គ្រប់សកម្មភាពរវាងគ្នា នឹងគ្នាទៅវិញទៅមកក៏ដោយ ក៏ក្រមរដ្ឋប្បវេណីបានផ្តល់សេរីភាពដល់ប្តីប្រពន្ធក្នុងការ ជ្រើសរើសវិជ្ជាជីវៈ ហើយមានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សាសនា សង្គមរៀងៗ ខ្លួន[17]។ ប្រពន្ធមានសេរីភាពធ្វើការងារអ្វីដែលខ្លួនពេញចិត្ត ហើយប្តីក៏មានសេរីភាពធ្វើការងារអ្វីដែលខ្លួនពេញ ចិត្តដូចគ្នាផងដែរ។ សហព័ទ្ធម្ខាងមិនអាចបង្ខំឲ្យសហព័ទ្ធម្ខាងទៀតឈប់ប្រកបមុខរបរ ឬ ការងាររបស់គេបាន នោះទេ លើសពីនេះទៅទៀតសហព័ទ្ធទាំងពីរមានសិទ្ធិសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយរាងៗខ្លួន ដោយគ្មានសហព័ទ្ធណាអាចបង្ខំឲ្យប្តី ឬ ប្រពន្ធរបស់ខ្លួនចូលរួមសកម្មភាពនយោបាយរបស់ខ្លួនបាននោះទេ មានន័យថាសហព័ទ្ធទាំងពីរស្រឡាញ់គណបក្សនយោបាយខុសគ្នាបាន។ ប្តីប្រពន្ធក៏មានសិទ្ធិសេរីភាពក្នុងការ គោរពជំនឿ នឹងសាសនារៀងៗខ្លួនបានផងដែរ ។

### ១.៤.៤. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា

ឪពុកម្តាយ មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា។[18] ឪពុកម្តាយដែលបានបង្កើតកូនហើយ មិនអាចបោះបង់កូន ឬ ទុក កូនចោល ឬ បង្កើតកូនដើម្បីយកកូនធ្វើអាជីវកម្ម ឬ កេងប្រវ័ញ្ចលើកម្លាំងពលកម្មកូនបានទេ។ ប្រសិនបើ ឪពុក ម្តាយធ្វើបែបនេះ ពួកគេនឹងត្រូវទទួលទោសតាមច្បាប់។

### ១.៤.៥. ទំនាក់ទំនងសហព័ន្ធ និងញាតិ

[15] មាត្រា៩៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[16] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[17] មាត្រា៩៦៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[18] មាត្រា៤៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ក្រោយពីការរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងបានក្លាយទៅជាសមាជិករបស់គ្រួសារម្ខាងទៀត។ នេះក៏ជាគោលបំណងនៃអាពាហ៍ពិពាហ៍ផងដែរ ដែលចង់ពង្រីកសមាជិកគ្រួសារឲ្យកាន់តែធំ ទោះបីសហព័ទ្ធម្ខាងមិនមែនជាញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ ប៉ុន្តែសហព័ទ្ធនោះមានករណីយកិច្ច គោរពញាតិ និងគោរពសិទ្ធិរបស់សមាជិកក្នុងគ្រួសារនោះផងដែរ មិនតែប៉ុណ្ណោះត្រូវសង្គ្រោះគ្នាទៅវិញទៅមក។ ហើយសមាជិកម្នាក់ៗ ក្នុងគ្រួសារ ត្រូវបង្ការកុំឲ្យមានអំពើហិង្សាក្នុងគ្រួសារ និងត្រូវធ្វើយ៉ាងណាកុំឲ្យមានការកើតឡើង នូវការរំលោភសិទ្ធិមនុស្ស។[19]

### ១.៤.៦. ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ

ក្រោយពេលដែលសហព័ទ្ធទាំងពីរបានក្លាយជាប្ដីប្រពន្ធស្របច្បាប់ ពួកគេទាំងពីរអាចជ្រើសរើសប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់) ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលពួកគេរកបាន ព្រមទាំងជៀសវាងជម្លោះដែលកើតឡើងដោយសារទ្រព្យ។

#### ១.៤.៦.១ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យា

ប្ដីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន ប៉ុន្តែកិច្ចសន្យានេះមិនអាចផ្ទុយនឹងបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ។[20] ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺដើម្បីកំណត់នូវសិទ្ធិ និងកាតព្វកិច្ចលើទ្រព្យសម្បត្តិដែលប្ដីប្រពន្ធ ដែលបានកំណត់នៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងដើម្បីបង្ការលក្ខណៈងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលមានការលែងលះគ្នា។

ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយត្រូវធ្វើនៅក្រសួងយុត្តិធម៌។ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺត្រូវបានទាមទារឱ្យចុះបញ្ជី។ ប្រសិនបើមិនបានចុះបញ្ជីទេ ប្ដីប្រពន្ធមិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ។[21]

ក្នុងករណីដែលប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់។[22]

---

[19] មាត្រា៩៤៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[20] មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[21] មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[22] មាត្រា៩៦៩ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

**១.៤.៦.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**

ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ គឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់តម្រូវឱ្យភាគីប្តីប្រពន្ធអនុវត្ត ប្រសិនបើពួកគេមិនបានជ្រើសរើសអនុវត្តប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ បានបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធជា២គឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

**ក. ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងជាទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ខាងលើ ។[23]

សហព័ទ្ធទាំងពីរអាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបានដោយសេរីដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀត។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។[24]

**ខ. ទ្រព្យសម្បត្តិរួម**

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[25] ទ្រព្យសម្បត្តិរួម គឺចង់សំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធរកបានដូចជាប្រាក់ខែរបស់ប្តី ឬ ប្រពន្ធ និងចំណូលពីការរកស៊ីរបស់ប្តី ឬ ប្រពន្ធ ជាដើម។

[23] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[24] មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[25] មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

# ជំពូកទី២
# នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវតែបំពេញបែបបទ និងនីតិវិធីមួយចំនួនទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ការបំពេញបែបបទ និងនីតិវិធីទៅតាមបញ្ញត្តិច្បាប់មានសារៈសំខាន់ណាស់ ប្រសិនបើមិនបានបំពេញលក្ខខណ្ឌឲ្យបានត្រឹមត្រូវនោះទេអាចប្រឈមមុខនឹងបញ្ហាមួយចំនួន ព្រមទាំងធ្វើឲ្យខាតពេលវេលា និងថវិកាជាដើម។ ដូចនេះប្រជាពលរដ្ឋគ្រប់រូប ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅសាលាឃុំ/សង្កាត់របស់ខ្លួនដែលរស់នៅ ហើយបំពេញបែបបទក្នុងការសុំចេញសំបុត្រអាពាហ៍ពិពាហ៍។ ដើម្បីឲ្យយល់កាន់តែច្បាស់ គឺត្រូវស្វែងយល់អំពីនីតិវិធីដែលពាក់ព័ន្ធដូចខាងក្រោម។

## ២.១. នីតិវិធីសម្រាប់រៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ

បុរស នារី ដែលប្រាថ្នាចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវអនុវត្តតាមនីតិវិធី ដើម្បីឲ្យប្រាកដថាការអាពាហ៍ពិពាហ៍របស់ពួកគេមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ គ្រប់ប្រទេសក្នុងពិភពលោកក៏ដូច្នេះដែរការបំពេញបែបបទនៃនីតិវិធីដើម្បីរៀបអាពាហ៍ពិពាហ៍មួយដែលពេញលក្ខណៈច្បាប់ មានសារៈសំខាន់ខ្លាំងណាស់។

### ២.១.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវទៅដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ/សង្កាត់នៃលំនៅឋានសាមីខ្លួនខាងនារី។[26] នៅមុនពេលរៀបអាពាហ៍ពិពាហ៍ បុរស និង នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវធ្វើលិខិតបញ្ជាក់ពីឃុំ/សង្កាត់ខាងលំនៅឋានរបស់ភាគីរៀងៗខ្លួន។ ភាគីទាំងពីរត្រូវភ្ជាប់នូវឯកសារមួយចំនួននៅពេលដាក់ពាក្យស្នើសុំ គឺត្រូវមានការយល់ព្រមពីឪពុក ម្ដាយ ឬ អាណាព្យាបាល ចំពោះអនីតិជន ភស្តុតាងនៃការរំលាយអាពាហ៍ពិពាហ៍មុនមានដូចជា (សាលក្រមលែងលះ ឬ សាលក្រមស្ដីពីការបាត់ខ្លួន ឬ សំបុត្រមរណភាព ឬ មោឃភាពនៃអាពាហ៍ពិពាហ៍) សំបុត្របញ្ជាក់ថា បានគោរព វិធវភាព(ភាពពោះម៉ាយ) និងលិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន ឬ ពីកន្លែងការងារ ថាខ្លួនពិតជានៅលីវ (លិខិត នេះហៅថា កិច្ចសន្យាសាមីជនកូនប្រុស កូនស្រី)។

មេឃុំ/ចៅសង្កាត់ដែលបានចេញលិខិតបញ្ជាក់ភាពនៅលីវ ឬ មេម៉ាយនេះត្រូវមានបិទរូប ថតទំហំ៤x៦ ដែលថតចំពីមុខចំនួនមួយសន្លឹកផងដែរ ហើយលិខិតនេះមានសុពលភាពត្រឹមរយៈ៣ខែតែប៉ុណ្ណោះ។

ក្រោយពីទទួលបានលិខិតបញ្ជាក់នេះហើយ ដោយមានទាំងឪពុកម្ដាយ ឬ អាណាព្យាបាលរួមជាមួយផងដែរ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅឃុំ /សង្កាត់ខាងភាគីនារី។ ក្រោយពីមន្ត្រីអាត្រានុកូលដ្ឋានទទួល

[26] មាត្រា២៨ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីអាត្រានុកូលដ្ឋាន

ពាក្យស្នើសុំនេះហើយត្រូវចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងចេញប័ណ្ណប្រកាសរៀបអាពាហ៍ពិពាហ៍ ឲ្យទៅភាគីទាំងពីរយកទៅបិទផ្សាយជាសាធារណៈចំនួន១០ថ្ងៃ មុនរៀបអាពាហ៍ពិពាហ៍ ។

### ២.១.២. ការប្រកាសជាសាធារណៈ

មេឃុំ/ចៅសង្កាត់ដែលមានមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងឃុំ/សង្កាត់ខាងស្ត្រីរស់នៅ ជាអ្នកចេញសេចក្តីសម្រេចអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និងជាអ្នកចេញប័ណ្ណប្រកាសការរៀបអាពាហ៍ពិពាហ៍។

បុរស នារី នៃអាពាហ៍ពិពាហ៍ដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ត្រូវតែបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ក្នុងរយៈពេល១០ថ្ងៃ។ ០១ច្បាប់ត្រូវបិទផ្សាយនៅលំនៅឋានខាងស្រី និងនៅសាលាឃុំ/សង្កាត់ខាងស្រីហើយ ដូចគ្នាផងដែរត្រូវធ្វើបិទផ្សាយនៅលំនៅឋាន និងនៅសាលាឃុំ/សង្កាត់ខាងប្រុស ដើម្បីឲ្យអ្នកមានផលប្រយោជន៍ក្នុងអាពាហ៍ពិពាហ៍អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នេះ។[27]

ច្បាប់បានបញ្ជាក់ដោយចំៗថា ប័ណ្ណប្រកាសត្រូវតែមានចុះព័ត៌មានដូចខាងក្រោមៈ

នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងទីលំនៅរបស់អនាគតប្តី និងប្រពន្ធ នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង ទីលំនៅរបស់ឪពុកម្តាយរបស់អនាគតប្តីប្រពន្ធ ឬ បើឪពុកម្តាយណាមួយត្រូវបានទទួលមរណៈភាពត្រូវដាក់ថាមរណៈភាព និងចុះការកំណត់រយៈពេល ដែលភាគីពាក់ព័ន្ធអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍បាន។

ភាគីទាំងពីរដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវរង់ចាំរយៈពេលយ៉ាងតិច១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រួចរាល់ ហើយប្រសិនបើផុតរយៈពេលនេះគ្មានអ្នកណាម្នាក់ប្តឹងជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍របស់ពួកគេទេ ពិធីមង្គលការនោះនឹងអាចប្រព្រឹត្តទៅបាន។[28]

### ២.១.៣. ជនដែលអាចធ្វើបណ្តឹងជំទាស់អំឡុងពេលធ្វើការប្រកាសជាសាធារណៈ

ប្រសិនបើមានជនណាម្នាក់ដាក់ពាក្យប្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍ មន្ត្រីនៃស្ថាប័នដែលពាក់ព័ន្ធ ត្រូវដោះស្រាយបណ្តឹងនោះឲ្យចប់សព្វគ្រប់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[29]

ជនដែលមានផលប្រយោជន៍អាចជាសាច់ញាតិ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ តតិយជនណាម្នាក់ដែលអាចមានការពាក់ព័ន្ធជាមួយអាពាហ៍ពិពាហ៍ដោយផ្ទាល់ ដូចជាភាគីដែលគ្រោងរៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្តីប្រពន្ធរបស់ខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬ ធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍ជាដើម អាចប្តឹងជំទាស់គម្រោងអាពាហ៍ពិពាហ៍ក្នុងចន្លោះ១០ថ្ងៃចាប់ពីការបិទប័ណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងរៀបចំនេះ។ នៅក្នុងករណីដែលអ្នកទាំងពីរមានសំបុត្រស្នាក់នៅជាមួយគ្នា ឬ

[27] មាត្រា២៩ កថាខណ្ឌទី១នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន

[28] មាត្រា២៩ កថាខណ្ឌទី២នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន

[29] មាត្រា២៩ កថាខណ្ឌទី៣នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក.ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អាត្រានុកូលដ្ឋាន

មានសំបុត្រគ្រួសារបញ្ជាក់ ដើម្បីធ្វើជាភស្តុតាងបង្ហាញទៅមេឃុំ ឬ ចៅសង្កាត់ ឬ ទៅតុលាការ។ សំបុត្រស្នាក់នៅជាមួយគ្នា ឬ មានសំបុត្រគ្រួសារ មិនមែនជាសំបុត្រអាពាហ៍ពិពាហ៍ដែលបញ្ជាក់ច្បាស់ថា ភាគីទាំងពីរជាប្តីប្រពន្ធនឹងគ្នាទេ សំបុត្រនោះ គ្រាន់តែបញ្ជាក់អំពីការស្នាក់នៅ នឹងអត្តសញ្ញាណគ្រួសារប៉ុណ្ណោះ។ មេឃុំ ឬ ចៅសង្កាត់ ឬតុលាការ នៅតែមិនមានភស្តុតាងសម្រាប់ការសម្រេចសេចក្តីជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍។

បញ្ហានេះមិនមានវិធានច្បាប់ដោះស្រាយទេ ហើយនៅក្នុងទម្លាប់អនុវត្តរបស់មេឃុំ ឬ ចៅសង្កាត់ ឬ តុលាការ គឺអនុវត្តដូចអ្វីដែលបានរៀបរាប់ខាងលើនេះ។ គោលការណ៍នេះ មិនសមស្របឡើយសម្រាប់ភាគីដែលមិនមានដំណោះស្រាយសម្រាប់ពួកគេ ដោយមេឃុំ ឬ ចៅសង្កាត់ ឬ តុលាការមិនទទួលការ ដោះស្រាយចំពោះការរស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាស។ ជាគោលការណ៍ទទួលស្គាល់អាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែមិនទទួលស្គាល់អាពាហ៍ពិពាហ៍មិនស្របច្បាប់ឡើយ។

### ២.១.៤ មូលហេតុជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយប្រសិនបើក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោមនេះ៖

អនាគតប្តី ឬ ប្រពន្ធមិនទាន់ដល់នីតិភាព (អាយុក្រោម១៨ឆ្នាំ) ឬ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាពហើយភាគីម្ខាងទៀតមានអាយុក្រោម១៦ឆ្នាំ ករណីភាគីមានសហព័ទ្ធហើយ (មានប្តី ឬ ប្រពន្ធ)អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ក្នុងករណីដែលចំណងគតិយុត្តអាពាហ៍ពិពាហ៍ចាស់របស់នារីត្រូវបានរំលាយលុប ហើយនៅមិនទាន់គ្រប់រយៈពេល១២០ថ្ងៃ ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬ អាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធ រហូតថ្នាក់ទី៣ និងរាប់ទាំងថ្នាក់ទី៣ផងអាពាហ៍ពិពាហ៍របស់អនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអាពាហ៍ពិពាហ៍របស់ជនវិកលចរិត (ជននៅក្រោមអាណាព្យាបាលទូទៅ) ដែលមិនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។[30]

នៅក្នុងករណីទាំងអស់ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិបដិសេធអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ ឬ មានសិទ្ធិប្តឹងជំទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍បាន។

### ២.១.៥. ការសម្រេចលើបណ្តឹង

នៅក្នុងក្រមរដ្ឋប្បវេណីមិនបានកំណត់ពីនីតិវិធី និងរយៈពេលដែលមេឃុំ/ចៅសង្កាត់អាចធ្វើការជំទាស់មិនទទួលយកសំណើររៀបអាពាហ៍ពិពាហ៍ទេ ក៏ដូចជាសិទ្ធិរបស់ភាគីក្នុងការប្តឹងតវ៉ាចំពោះការបដិសេធរបស់មេឃុំ/ចៅសង្កាត់។ ប៉ុន្តែនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់នូវនីតិវិធីមួយចំនួនដូចតទៅ៖

[30] មាត្រា៩៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

មេឃុំ/ចៅសង្កាត់ត្រូវធ្វើសេចក្តីសម្រេចស្តីពីសុពលភាពនៃបណ្តឹងនោះក្នុងរយៈពេល៣ថ្ងៃ ប្រសិនបើមេឃុំ/ចៅសង្កាត់ដែលសម្រេចជំទាស់ពីពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ទាន់ពេលវេលាហើយ ហើយដើមបណ្តឹងឬអនាគតប្តីប្រពន្ធ មិនយល់ស្របនឹងសេចក្តីសម្រេចរបស់មេឃុំ ចៅ/សង្កាត់ទេ គេអាចប្តឹងតវ៉ាទៅតុលាការ។[31]

អនាគតប្តីប្រពន្ធនោះ អាចតវ៉ាដោយបញ្ជាក់នូវការមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់មេឃុំ/ចៅសង្កាត់ ដែលបានធ្វើសេចក្តីសម្រេចក្នុងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃដែលភាគីមិនយល់ស្របនឹងសេចក្តីសម្រេចនោះ មេឃុំ/ចៅសង្កាត់ដែលបានធ្វើសេចក្តីសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅតុលាការ។[32]

តុលាការត្រូវពិនិត្យសំណុំរឿងឡើងវិញ ហើយចេញសេចក្តីសម្រេចក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរគិតពីថ្ងៃបានទទួលសំណុំរឿង។ បើសិនតុលាការចេញសាលក្រមរក្សាទុកសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានជាការត្រឹមត្រូវនោះភាគីពុំអាចអនុញ្ញាតឲ្យធ្វើពិធីរៀបអាពាហ៍ពិពាហ៍បានឡើយ បើសិនតុលាការសម្រេចបដិសេធចោលសេចក្តីសម្រេច នោះមេឃុំ/ចៅសង្កាត់នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានដោយស្របច្បាប់។[33] សេចក្តីសម្រេចរបស់តុលាការ មិនអាចប្តឹងតវ៉ាបានឡើយ ពោលគឺមិនមានសិទ្ធិប្តឹងឧទ្ធរណ៍ទេ។

### ២.១.៦. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដំណាក់កាលចុងក្រោយក្នុងការបង្កើតឲ្យមានអាពាហ៍ពិពាហ៍ស្របច្បាប់មួយដែលទទួលស្គាល់ដោយច្បាប់គឺ ការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី។[34] នីតិវិធីបែបនេះគេហៅថា " ការចុះអេតាស៊ីវិល " ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះកិច្ចសន្យានោះ ក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់ឃុំ/សង្កាត់ ហើយភាគីទាំងពីរត្រូវផ្តិតមេដៃព្រមទាំងមានសាក្សីពីរនាក់ដែលដល់នីតិភាព ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាលើ សៀវភៅនោះផងដែរ។

ទោះបីជាយ៉ាងណា អនាគតប្តី ឬ ប្រពន្ធត្រូវបញ្ជាក់ប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា " អាពាហ៍ពិពាហ៍របស់ពួកគេធ្វើឡើងដោយស្ម័គ្រចិត្ត"។ ក្រោយពីមន្ត្រីអត្រានុកូលដ្ឋានបានចុះបញ្ជីអនាគតប្តី ប្រពន្ធក្នុងសៀវភៅអាពាហ៍ពិពាហ៍រួចហើយ ត្រូវប្រគល់អោយសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។

[31] មាត្រ១៨ ចំណុចទី១នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩

[32] មាត្រា១៨ ចំណុចទី២នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩

[33] មាត្រា១៩ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩

[34] មាត្រា៣០ ចំណុចទី១នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

### ២.១.៧.ការសុំចុះសំបុត្រអាពាហ៍ពិពាហ៍ចំពោះពលរដ្ឋខ្មែរដែលរស់នៅក្នុងស្ថានភាពជាប្តីប្រពន្ធ

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយតែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍ដើម្បីប្រើប្រាស់ សាមីខ្លួនទាំងពីររូប ត្រូវប្តឹងសុំចុះសៀវភៅអាត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ដែលអាចហៅបានថាជា ការរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល។ ការរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល ត្រូវធ្វើឡើងនៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ នៃទីលំនៅដែលសាមីខ្លួន ទាំងពីររស់នៅពិតប្រាកដ។

ដើម្បីទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីត្រូវមានលិខិតដូចជាៈ

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬ ពោះម៉ាយ និងសេចក្តីចម្លងសំបុតកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន (ប្រសិនបើមាន) ឬ សៀវភៅគ្រួសាររបស់សាមីខ្លួន (ប្រសិនបើមាន) ឬ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន។[35]

មន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ ក្រោយពីពិនិត្យឃើញថាមានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវហើយត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន០៣ច្បាប់ ដោយមួយច្បាប់បិទផ្សាយជាសាធារណៈនៅផ្ទះសាមីខ្លួនទាំងពីររូបមួយច្បាប់បិទនៅសាលាឃុំ/សង្កាត់សាមី និងមួយច្បាប់ទៀតរក្សាទុកជាឯកសារនៅសាលាឃុំ/សង្កាត់សាមី។ ក្នុងពេលបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រយៈពេល១០ថ្ងៃ បើគ្មានការប្តឹងជំទាស់អំពីសាមីខ្លួនទាំងពីររូបនោះទេ សាមីខ្លួនទាំងពីរអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់សាមីដោយនាំសាក្សី០២រូបដែលមានអាយុគ្រប់ការ និងមានទីលំនៅពិតប្រាកដទៅជាមួយ។[36]

### ២.១.៨. ការចេញសំបុត្រអាពាហ៍ពិពាហ៍

នៅក្រោយពេលសាមីខ្លួន អនាគតប្តីនិងប្រពន្ធបានមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ បន្ទាប់មកត្រូវប្រគល់ឱ្យសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រមួយហៅថា សំបុត្រអាពាហ៍ពិពាហ៍ជាច្បាប់ដើមមួយច្បាប់ និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍មួយចំនួនទៀតតាមការស្នើសុំរបស់ភាគី។[37]

ជនបរទេស គឺជាជនណាដែលគ្មានសញ្ញាតិជាខ្មែរទោះបីជននោះស្ថិតនៅក្រៅប្រទេសកម្ពុជាក្តី ឬកំពុងស្ថិតនៅឬស្នាក់នៅក្នុងប្រទេសកម្ពុជាក្តី។

[35] សេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអាត្រានុកូដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអាត្រានុកូលដ្ឋានទំព័រទី៨

[36] មាត្រា៣០នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន

[37] មាត្រា៣១នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន

## ២.២.នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

កន្លងមកមានពលរដ្ឋខ្មែរ និងជនបរទេសដែលបានមករៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាមានចំនួនច្រើន មានស្ត្រីខ្មែរជាច្រើននាក់ហើយបានទៅរស់នៅបរទេស។ មានជនបរទេសជាច្រើនបានមករៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរបង្កើតបានគ្រួសារល្អចម្រុះដោយវប្បធម៌និងជាតិសាសន៍ នឹងប្រកបដោយសុភមង្គល។ ប៉ុន្តែមានករណីខ្លះស្ត្រីជនជាតិខ្មែរមួយចំនួនតូចត្រូវបានរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ហើយមានស្ត្រីខ្មែររងគ្រោះខ្លះ ត្រូវបានគេជួញដូរនិងធ្វើអាជីវកម្មផ្លូវភេទ។

ដើម្បីចៀសវាងនូវសកម្មភាពទាំងអស់នោះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាង ពលរដ្ឋខ្មែរ និងជនបរទេស អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជារវាងពលរដ្ឋខ្មែរ និងជនបរទេស។

ពលរដ្ឋខ្មែរដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនបរទេសដែលមានបំណងមករៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិខ្មែរ ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដើម្បីឱ្យអាពាហ៍ពិពាហ៍នោះមានអានុភាព។

### ២.២.១. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍

#### ២.២.១.១. នីតិវិធីសម្រាប់ជនបរទេស

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរត្រូវបំពេញបែបបទ និងនីតិវិធីមួយចំនួនដូចជា៖

ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយភ្ជាប់ទៅជាមួយនូវឯកសារដូចជា៖ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសដែលមានទិដ្ឋាការចូលប្រទេសកម្ពុជា ហើយនៅមានសុពលភាព មានលិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយដែលចេញដោយសមត្ថកិច្ចសាមីខ្លួនជនបរទេស មានលិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃ ប្រទេសកម្ពុជាមានលិខិតថ្កោលទោសចេញដោយសមត្ថកិច្ច នៃប្រទេសរបស់សាមីខ្លួនជនបរទេស មានលិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅដែលចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។[38]

[38] មាត្រា៦ នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

រាល់ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ត្រូវ មានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬកុងស៊ុលនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំនៅប្រទេសកម្ពុជា។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកម្ពុជា មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេស ដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញក្នុងរយៈពេលយ៉ាងយូរ៥ថ្ងៃ នៃថ្ងៃធ្វើការ។

បន្ទាប់មកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍នោះទៅក្រសួងមហាផ្ទៃដែលក្រសួងនេះមានភារកិច្ចបន្តដូចជា៖ ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និង ត្រូវជូនដំណឹងទៅសាមីខ្លួនវិញក្នុងរយៈពេលយ៉ាងយូរ៥ថ្ងៃត្រូវជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

**២.២.១.២. នីតិវិធីសម្រាប់ពលរដ្ឋខ្មែរ**

ចំពោះសាមីខ្លួនជាពលរដ្ឋខ្មែរដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ/ង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយភ្ជាប់មកជាមួយនូវឯកសារដូចជា៖

ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនពលរដ្ឋខ្មែរទំហំ៤គុណ៦ ថតចំពីមុខក្នុងរយៈពេល០៣ខែចុងក្រោយ សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត របស់សាមីខ្លួនពលរដ្ឋខ្មែរ លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយ ដែលចេញដោយមេឃុំ/ចៅសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ (ករណី ពោះម៉ាយ ឬមេម៉ាយ ដោយប្រពន្ធ ឬ ប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬ មេម៉ាយដោយលែងលះ ត្រូវមានសាលក្រមស្ពាពរពីតុលាការ) លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃ ព្រះរាជាណាចក្រ-កម្ពុជា និងសៀវភៅគ្រួសារដែលមានទិន្នន័យច្បាស់លាស់ និងត្រឹមត្រូវ។[39]

[39] មាត្រា៩ ចំណុច២នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

### ២.២.៣. នីតិវិធីសម្រាប់មេឃុំ/ចៅសង្កាត់

សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ត្រូវយកទៅដាក់ស្របពេលជាមួយគ្នានៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងការងារនៃអត្រានុកូលដ្ឋាន។[40]

បន្ទាប់មក មេឃុំ/ចៅសង្កាត់ជាអ្នកមានភារកិច្ចត្រូវពិនិត្យលើពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរស និងនារីក្នុងរយៈពេល០៣ថ្ងៃយ៉ាងយូរនៃថ្ងៃធ្វើការងារគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។បន្ទាប់ពីពិនិត្យពាក្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនថា ត្រឹមត្រូវតាមគោការណ៍ច្បាប់រួចហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំបណ្ណប្រកាសអាពាហ៍ពិពាហ៍ដោយមានវត្តមានសាមីខ្លួនទាំងពីររូប នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់សាម៉ីខ្លួនពលរដ្ឋខ្មែរ។ បន្ទាប់ពីភាគីទាំងពីរបានទទួលប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ហើយត្រូវយកប័ណ្ណប្រកាសនេះបិទនៅស្ថានទូត ឬ ស្ថានតំណាងនៃសាម៉ីជនបរទេសប្រចាំនៅប្រទេសកម្ពុជានៅសាលាឃុំ/សង្កាត់ និងនៅលំនៅឋានអចិន្ត្រៃយ៍នៃសាមីខ្លួនជាពលរដ្ឋខ្មែរក្នុងរយៈពេល ១០ថ្ងៃ។[41]

### ២.២.៤. រយៈពេលរង់ចាំ

បន្ទាប់ពីបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ហើយ ភាគីត្រូវរង់ចាំក្នុងរយៈពេល១០ថ្ងៃ បើផុតរយៈពេល១០ថ្ងៃនេះហើយគ្មានអ្នកប្តឹងតវ៉ា ឬ ប្តឹងជំទាស់ទេទើបសាមីខ្លួនបុរស នារីអាចរៀបអាពាហ៍ពិពាហ៍បាន។ ក្នុងករណីដែលមានបណ្តឹងតវ៉ាគេត្រូវដោះស្រាយបណ្តឹងតវ៉ានោះឱ្យចប់សិនទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[42]

### ២.២.៥. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន

ក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធអំពីគំរូលិខិតស្នាមបែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំអំពីគំរូលិខិតស្នាមបែបបទនិងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងនិង ការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ។[43]

---

[40] មាត្រា៩ ចំណុច៣នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[41] មាត្រា១០ នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[42] មាត្រា១០ ចំណុច៣នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[43] មាត្រា១២ នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

**២.២.៥.១. ការពិនិត្យរបស់ថ្នាក់ក្រសួង**

នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃជាសេនាធិការឲ្យក្រសួងលើការងារទាក់ទងនឹងអត្រានុកូលដ្ឋាន និងមានភារកិច្ចដូចជាៈ ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលផ្ញើមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថតចម្លងឯកសារសាមីខ្លួនជនបរទេសបញ្ជូនទៅអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ដើម្បីសហការផ្តល់ព័ត៌មានពីអត្តសញ្ញាណជនបរទេសនោះ ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមីនិងមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរនិងជូនដំណឹងព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅសាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេសរយៈពេលយ៉ាងយូរ០៥ថ្ងៃ ការងារដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអាត្រានុកូលដ្ឋាន ឃុំ/សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ។[44]

**២.២.៥.២. ការពិនិត្យរបស់ថ្នាក់រាជធានី/ខេត្ត**

អភិបាលរាជធានី/ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅរាជធានី/ខេត្ត របស់ខ្លួនដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃសាលារាជធានី/ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចជាៈ គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្សព្វផ្សាយ និងចលនាឲ្យមន្ទីរពាក់ព័ន្ធនានាជុំវិញរាជធានី/ខេត្ត សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្ញើមកក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) នៅរៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់។[45]

**២.២.៥.៣. ការពិនិត្យរបស់ ថ្នាក់ក្រុង ស្រុក ខណ្ឌ**

អភិបាលក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ របស់ខ្លួន និងមានភារកិច្ចដូចជាៈ គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ផ្សព្វផ្សាយ និងចលនាឲ្យការិយាល័យពាក់ព័ន្ធនានាជុំវិញ ក្រុង ស្រុក ខណ្ឌ សហ

[44] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអាត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអាត្រានុកូដ្ឋានអាពាហ៍ពិពាហ៍ ឆ្នាំ២០១២ ទំព័រទី៩៨

[45] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអាត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអាត្រានុកូដ្ឋានអាពាហ៍ពិពាហ៍ ឆ្នាំ២០១២ ទំព័រទី៩៨

ការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមករាជធានី/ខេត្ត នៅរៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់។[46]

**២.២.៥.៤. ការពិនិត្យរបស់ ថ្នាក់ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ/សង្កាត់ ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋាននៅក្នុងដែនដីឃុំ/សង្កាត់ ដែលខ្លួនគ្រប់គ្រង។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ ក្រោយពីទទួលបាននូវសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃស្តីពីការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស ជាមួយពលរដ្ឋខ្មែរ និងបន្ទាប់ពីបានទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ពីសាមីខ្លួនជនបរទេស និងពីសាមីខ្លួនពលរដ្ឋខ្មែររួចហើយមានភារកិច្ចដូចជា៖ ពិនិត្យ និងសម្រេចលើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស និងរបស់ពលរដ្ឋខ្មែរ យ៉ាងយូរក្នុងរយៈពេល០៣ថ្ងៃការងារ។ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារ សាមីខ្លួនជាជនបរទេស និងរបស់ពលរដ្ឋខ្មែរត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ។[47]

**២.២.៦. ការចុះសំបុត្រអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍មានអានុភាពលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ/សង្កាត់ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន២នាក់ផងស្របទៅតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។[48]

## ២.៣. អាពាហ៍ពិពាហ៍រវាងជនអន្តោប្រវេសន៍ ឬជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា

ជនអន្តោប្រវេសន៍ និងជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជាអាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ដែលមានចែងនៅក្នុងប្រទេសរបស់សាមីខ្លួន ប៉ុន្តែត្រូវសុំការអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន (មេឃុំ ចៅសង្កាត់) ដោយប្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នោះឱ្យច្បាស់លាស់។[49]

---

[46] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអាត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអាត្រានុកូដ្ឋានអាពាហ៍ពិពាហ៍ ឆ្នាំ២០១២ ទំព័រទី៥៨

[47] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអាត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអាត្រានុកូដ្ឋានអាពាហ៍ពិពាហ៍ ឆ្នាំ២០១២ ទំព័រទី៥៨

[48] មាត្រា១១នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[49] មាត្រា៤ ចំណុច១នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អាត្រានុកូលដ្ឋាន

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធនោះអាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅប្រទេសកម្ពុជា ហើយប្តីប្រពន្ធទាំងនោះក៏អាចស្នើសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងឃុំ/សង្កាត់ដែលខ្លួនបានរៀបអាពាហ៍ពិពាហ៍នៅប្រទេសកម្ពុជាតាមច្បាប់របស់ប្រទេសកម្ពុជាក៏បាន។[50]

[50] មាត្រា៤ ចំណុច២នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អត្រានុកូលដ្ឋាន

# ជំពូកទី៣

# លក្ខខណ្ឌនៃការហាមឃាត់ និងការបញ្ចប់នៃការរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ អាចប្រព្រឹត្តទៅបានលុះត្រាតែធ្វើទៅតាមលក្ខខណ្ឌច្បាប់ដែលបានកំណត់ បើពុំដូច្នេះទេ គឺការរៀបអាពាហ៍ពិពាហ៍នោះពុំអាចមានអានុភាពតាមផ្លូវច្បាប់ ហើយមិនអាចធ្វើឡើងតាមតែចិត្តចង់ ឬដោយឯកឯងនោះទេ ។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ពុំមានអានុភាពគតិយុត្តគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់នោះទេ។ ដូច្នេះគួរគប្បីស្វែងយល់មុននឹងធ្វើការរៀបអាពាហ៍ពិពាហ៍អំពីលក្ខខណ្ឌនៃការហាមឃាត់ និងការបញ្ចប់អាពាហ៍ពិពាហ៍ខ្លះៗដើម្បីអោយយល់កាន់តែច្បាស់អំពីអានុភាពទៅតាមច្បាប់ដែលបានកំណត់ ។

## ៣.១. លក្ខខណ្ឌនៃការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍

### ៣.១.១. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានប្ដី ឬ ប្រពន្ធហើយចំណងអាពាហ៍ពិពាហ៍នោះនៅមានអានុភាពនៅឡើយពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានឡើយ ( មិនទាន់លែងលះគ្នាដាច់ស្រាច់នៅឡើយ ) ហើយចង់រៀបអាពាហ៍ពិពាហ៍ប្ដី ឬ ប្រពន្ធថ្មីមួយទៀត គឺច្បាប់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ ។[51]

បុរស ឬស្ត្រីមានសិទ្ធិស្មើគ្នានៅក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍នឹងគ្រួសារ ។ អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមលក្ខខណ្ឌច្បាប់ នឹងគោលការណ៍ស័គ្រចិត្តប្ដីមួយ ប្រពន្ធមួយ។[52] ប៉ុន្តែក្នុងករណីដែលបុរស ឬ ស្ត្រីនោះបានលួចទៅចុះបញ្ជីអាពាហ៍ពិពាហ៍ស្របពេលចំណងអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរលាយ គឺត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ។[53]

នៅក្នុងក្រមរដ្ឋប្បវេណីចាស់ អនុញ្ញាតឱ្យបុរសអាចរៀបអាពាហ៍ពិពាហ៍លើកទី១ ហើយអាចបន្តរៀបអាពាហ៍ពិពាហ៍លើកទី២បានដោយមិនខុសច្បាប់ឡើយ។[54] ប៉ុន្តែសម្រាប់ស្ត្រី អនុញ្ញាតឱ្យតែរៀបអាពាហ៍ពិពាហ៍បានតែប្ដីមួយប៉ុណ្ណោះ ។[55]

### ៣.១.២. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ដោយ មរណភាព លែងលះ ឬ មោឃភាពនៃអាពាហ៍ពិពាហ៍នោះ បុរសអាចរៀបអាពាហ៍ថ្មីម្តងទៀតនៅពេលណាក៏បានក្រោយពេលបញ្ចប់អាពាហ៍ពិពាហ៍

[51] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[52] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[53] មាត្រា៤ នៃច្បាប់ស្តីពីឯកពន្ធភាព, ព្រះរាជក្រមលេខ នស/រកម/១០១៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦

[54] មាត្រា១៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

[55] មាត្រា១៤០ នៃក្រមរដ្ឋប្បវេណីឆ្នា១៩២០

មុន។ ប៉ុន្តែសម្រាប់ស្ត្រីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ម្តងទៀតត្រូវរង់ចាំ១២០ថ្ងៃ បន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍ពីលើកមុន ។[56]

ប្រសិនបើតុលាការបានសម្រេចឱ្យប្តីប្រពន្ធលែងលះតាមផ្លូវច្បាប់ មុនពេលសម្រេចឱ្យលែងលះគ្នារយៈពេលរងចាំត្រូវរាប់ពីថ្ងៃមានសាលក្រម ឬ សាលដីការឱ្យនៅបែកគ្នា។ ច្បាប់តម្រូវឱ្យស្ត្រីរង់ចាំ១២០ថ្ងៃដើម្បីកំណត់បិតុភាពនៃកូនដែលកើតនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន។ ប្រសិនបើស្ត្រីម្នាក់បានរៀបអាពាហ៍ពិពាហ៍ឆាប់រហ័សពេកក្រោយការបញ្ចប់អាពាហ៍ពិពាហ៍លើកមុនរបស់ខ្លួនហើយកូនដែលកើតឡើងក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មី នោះធ្វើឱ្យកូនកើតមានមកមានមន្ទិលសង្ស័យ កំណត់បិតុភាពមិនច្បាស់ មិនដឹងថាកូននោះជាកូនប្តីមុន ឬ ជាកូនប្តីក្រោយ ។

អំឡុងពេលដែលត្រូវរង់ចាំដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីនេះត្រូវលើកឡើងក្នុងករណីដូចខាងក្រោម៖

**ករណីទី១៖** ស្ត្រីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬ លុបចោល ឬ ប្តីស្លាប់ហើយត្រូវបានសម្រាលកូន គឺស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនចាំបាច់រងចាំរយៈពេល១២០ថ្ងៃទេ ពីព្រោះកូននោះត្រូវបានគេសន្មតថា ជាកូនរបស់ប្តីមុនហើយ ។

**ករណីទី២៖** ស្ត្រីដែលបានលែងលះ ឬ ប្តីស្លាប់ចោល ហើយមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតថា គ្មានផ្ទៃពោះស្ត្រីនោះក៏អាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនចាំបាច់រងចាំរយៈពេល១២០ថ្ងៃនោះទេ ។

### ៣.១.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

ញាតិលោហិតសំដៅលើ ញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក ម្តាយ និងកូន ជាដើម ។ សាខាញាតិសំដៅលើ ញាតិដែលចែកជាមែកធាងពីអ្នកបង្កើតរួមដូចជា បងប្អូនបង្កើត មីងពូ ក្មួយ បងប្អូនជីដូនមួយ ជាដើម ។

ការរៀបអាពាហ៍ពិពាហ៍រវាងថ្នាក់ជិតគ្នាត្រូវបានហាមឃាត់ ដោយសារមូលហេតុនៃសុជាតិវិជ្ជា និងសីលធម៌សង្គម។ ចំពោះមូលហេតុសុជាតិវិជ្ជា ការរៀបអាពាហ៍ពិពាហ៍រវាងថ្នាក់ជិតគ្នាងាយនឹងបណ្តាលឱ្យពន្ធុខ្សោយជាប់គ្នា ហើយលទ្ធភាពដែលកូនកើតមកអាចមានភាពពិការមានចំនួនអត្រាខ្ពស់។ ក៏ប៉ុន្តែការហាមឃាត់នូវអាពាហ៍ពិពាហ៍ចំពោះញាតិលោហិតបែបនេះ គឺបណ្តាលមកពីសីលធម៌សង្គមច្រើនជាងហេតុផលសុជាតិវិជ្ជា ។[57]

បុរស នឹងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នាមិនត្រូវមានជាប់ចំណងញាតិលោហិត ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣ ទោះជាមានករណីដែលមានការបញ្ចប់នូវទំនាក់ទំនងរវាងឪពុកម្តាយបង្កើត

[56] មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[57] មាត្រា៩៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ឬ ការកាត់កាល់រវាងឪពុកម្តាយចិញ្ចឹមនឹងកូនសុំហើយក៏ដោយ។ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិដែលមានទំនាក់ទំនងគ្នា ចំពោះករណីមួយចំនួនដូចខាងក្រោម៖

**៣.១.៣.១.ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែរផ្ទាល់**

អាពាហ៍ពិពាហ៍មិនអាចធ្វើឡើងបានឡើយ រវាងញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៣ រវាងបងប្អូនបង្កើត ( ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី១) រវាងជីតា ឬ ជីដូន ជាមួយចៅ ( ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២ ) រវាងជីទួតជាមួយចៅទួត រវាងពូ ឬ មីង ជាមួយក្មួយ ( ញាតិលោហិតថ្នាក់ទី៣ ) ។

**៣.១.៣.២. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត**

អាពាហ៍ពិពាហ៍ ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុង៣ថ្នាក់ រវាងបងប្អូនបង្កើត ( សាខាញាតិថ្នាក់ទី២ ) រវាងពូ ឬ មីង ជាមួយក្មួយ ( សាខាញាតិថ្នាក់ទី៣ ) ។

ចំពោះសាខាញាតិលោហិតចាប់ពីថ្នាក់ទី៤ទៅ អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដូចជា បងប្អូនជីដូនមួយ ឬ បងប្អូនជីទួតមួយជាដើម ។

**៣.១.៣.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្តាយបង្កើតជាមួយអតីតកូនបង្កើត**

ច្បាប់ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្តាយបង្កើតជាមួយអតីតកូនបង្កើតដែលបានបញ្ចប់ញាតិភាពជាមួយ នឹងឪពុកម្តាយបង្កើយដោយសារការបង្កើតសុំកូនពេញលេញ។ មានន័យថា ក្នុងករណីដែលអតីតឪពុកបង្កើត ឬ អតីតម្តាយបង្កើតត្រូវបានបញ្ចប់នូវភាពជាឪពុក ឬ ម្តាយបង្កើតដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកបង្កើត ឬ អតីតម្តាយបង្កើត មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនបង្កើតរបស់ខ្លួនបានដែរ ។[58]

**៣.១.៣.៤. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬម្តាយចិញ្ចឹមជាមួយកូនសុំ**

ច្បាប់ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមជាមួយកូនសុំ។ ទោះបីជាទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ហើយដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកចិញ្ចឹម ឬ អតីតម្តាយចិញ្ចឹមមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនចិញ្ចឹមបានដែរ ។

**៣.១.៤. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ**

ញាតិពន្ធ សំដៅលើចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង នឹង ញាតិលោហិតរបស់ហសព័ទ្ធម្ខាងទៀត ឬ ហៅថា (សាច់ថ្លៃ ឪពុកម្តាយក្មេក នឹងកូនប្រសារ បងថ្លៃប្អូនថ្លៃ ខាងប្តី ឬ ខាងប្រពន្ធ )។ ញាតិពន្ធខ្សែផ្ទាល់

[58] មាត្រា៩៥១ ចំណុច២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧

សំដៅលើញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃដែលកើតពីមួយទៅមួយតាមលំដាប់ដូចជា ជីដូនជីតាក្មេក ឪពុកក្មេក ម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត (ប៉ុន្តែជាកូនចុងរបស់សហព័ទ្ធម្ខាងទៀត ) ។

បុរស នឹង ស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវមានចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជាថ្នាក់ណាក៏ដោយដែលច្បាប់បានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ទេ។[59] ទោះបីជាញាតិខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ក៏ច្បាប់មិនអានុញ្ញាត ឱ្យញាតិពន្ធខ្សែផ្ទាល់នោះអាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានឡើយ ។

ច្បាប់ក៏បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ រហូតដល់៣ថ្នាក់ផងដែរ។ ក្នុងករណីដែលទំនាក់ទំនងរវាងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏ច្បាប់នៅតែមិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ផងដែរ ។ ការរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធ គឺមានលក្ខណៈជិតស្និទ្ធស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ នឹងសាខាញាតិលោហិតដែរ។ ដោយសារតែប្រទេសកម្ពុជាមានករណី ការរៀបអាពាហ៍ពិពាហ៍ជាមួយបងថ្លៃ ឬ ប្អូនថ្លៃ ។[60]ឧទាហរណ៍៖ នៅពេលដែលប្តីបានទទួលមរណភាពទៅហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្អូនប្រុសរបស់បងខ្លួន ។ មួយវិញទៀត ទោះបីជាក្នុងករណីដែលទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ដោយមូលហេតុលែងលះក៏ដោយ ក៏នៅតែមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរវាងសាខាញាតិពន្ធរហូតដល់ថ្នាក់ទី៣ផងដែរ ។[61]

### ៣.១.៤.១. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់

ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ហើយក៏ដោយមានដូចជា៖ រវាងឪពុកម្តាយក្មេក នឹងកូនប្រសារ រវាងជីដូនជីតាក្មេក នឹងចៅប្រសារ រវាងជីដូនជីតាទួតក្មេក នឹងចៅទួតប្រសា ,រវាងជីលួតក្មេក នឹងចៅលួតប្រសា រវាងជីលាក្មេក នឹងចៅប្រសារ រវាងអតីតកឪពុកម្តាយក្មេក នឹងអតីតកូនប្រសារ រវាងអតីតជីដូនជីតាក្មេក នឹងអតីតចៅប្រសារ រវាងអតីតកជីដូនជីតាទួតក្មេក នឹងអតីតចៅទួត រវាងអតីតជីលួតក្មេក នឹងអតីតចៅលួតប្រសារ រវាងអតីតជីលាក្មេក នឹងអតីតចៅលាប្រសារ ។

---

[59] មាត្រា៩៥២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[60] មាត្រា៩៥២ ចំណុច១នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧

[61] មាត្រា៩៥២ ចំណុច២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧

### ៣.១.៤.២. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិពន្ធ

ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង ហើយទោះបីជាទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ មានដូចជា រវាងបងថ្លៃ ប្អូនថ្លៃ ( សាខាញាតិពន្ធថ្នាក់ទី២ ) ,រវាងអតីតបងថ្លៃ នឹងអតីតប្អូនថ្លៃ រវាងពូ ឬ មីងក្មេក ជាមួយក្មួយប្រសា ( សាខាញាតិពន្ធថ្នាក់ទី៣ ) រវាងអតីតពូមីងក្មេក ជាមួយអតីតក្មួយប្រសារ រវាងបងប្អូនបង្កើតរបស់ប្តីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ រវាងអតីតបងប្អូនបង្កើតរបស់ប្តី ជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ ។

### ៣.១.៤.៣. ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិពន្ធ

ក្នុងករណីសហព័ទ្ធណាម្នាក់បានទទួលមរណភាព ហើយសហព័ទ្ធម្ខាងទៀតនៅរស់អាចរៀបអាពាហ៍អាពាហ៍ពិពាហ៍ជាមួយសាខាញាតិរបស់សហព័ទ្ធម្ខាងទៀតបាននៅក្នុង៣ថ្នាក់បាន។ ពោលគឺ អាចរៀបអាពាហ៍ពិពាហ៍រវាងអតីត ពូ មីងសាច់ថ្លៃ ឬអតីតប្អូនថ្លៃបាន។

### ៣.១.៥. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

អនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ ច្បាប់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានទេ។ ម្យ៉ាងទៀតទោះបីករណីដែលអនីតិជន នឹងអនីតិជនដែលមានអាយុ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានដែរ ។

## ៣.២. ការបញ្ចប់អាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ដែលអាចបញ្ចប់តាមផ្លូវច្បាប់ដោយវិធីមាន ៥យ៉ាង៖ រួមមានមរណភាពរបស់សហព័ទ្ធណាមួយ មោឃភាពអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ បុគ្គលដែលអវត្តមាន នឹងការប្រកាសបាត់ខ្លួន និងការលែងលះ។

### ៣.២.១. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ មានអានុភាពនៃគតិយុត្តមួយចំនួនដូចខាងក្រោម៖

ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ ពោលគ្រាន់តែមានអានុភាពទៅលើអនាគតប៉ុណ្ណោះ។ មានន័យថា គេមិនអាចធ្វើអ្វីឲ្យមានលក្ខណៈ ដូចកាលពីមុនមិនទាន់រៀបអាពាហ៍ពិពាហ៍ ដូចជាភាពនៅកម្លោះ ឬជាភាពនៅក្រមុំ ឬភាពមិនមានកូន។ ចំពោះកូនដែលកើតមកត្រូវសន្មតថាកូនរបស់ប្តីមុន។

ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល មានអានុភាពដល់ការកំណត់បិតុភាពរបស់ទារកផងដែរ។ ទារកនៅក្នុងគភ៌របស់ប្រពន្ធដែលមាននៅក្នុងពេលចំណងអាពិហ៍ពាហ៍ត្រូវសន្មតថា ជាកូនរបស់ប្តីនោះ។ ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវលុបចោល ប្រសិនបើក្នុងករណីកូនដែលបានកើតនៅក្នុងអំឡុងពេលក្រោយ១៨០ថ្ងៃ គិតចាប់ពីថ្ងៃអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបាន

រំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ច្បាប់បានសន្មត់ថា ស្ត្រីនោះមានគភ៌ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។ ក្នុងករណីដែលកូនមិនអាចកំណត់ឪពុកបានតាមខាងលើនេះទេ កូននោះត្រូវច្បាប់សន្មតថា ជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។[62]នៅក្រោយពេលអាពាហ៍ពិពាហ៍លុបចោល ទ្រព្យសម្បត្តិរបស់ភាគីទាំងពីរត្រូវយកមកធ្វើការបែងចែកគ្នាផងដែរ។ ប្រសិនបើភាគីទាំងពីរមិនអាចធ្វើការបែងចែកទ្រព្យសម្បត្តិគ្នាបាននោះតុលាការអាចមានសិទ្ធិបែងចែកទ្រព្យសម្បត្តិជំនួយបាន។

**៣.២.២. មរណភាពរបស់សហព័ន្ធ**

ករណីដែលសហព័ទ្ធណាមួយបានទទួលមរណភាព គឺនាំឲ្យអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយស្វ័យប្រវត្តិ។ សហពទ្ធដែលរស់នៅត្រូវទៅសាលាឃុំ/សង្កាត់ដើម្បីបញ្ជាក់អំពីសំបុត្រមរណភាព សម្រាប់សហព័ទ្ធដែលបានស្លាប់។ សហព័ទ្ធដែលនៅរស់មានសិទ្ធិចាត់ចែងនូវទ្រព្យសម្បត្តិរួមដែលនៅមានក្រោយពេលសហព័ទ្ធម្ខាងទៀតបានទទួលមរណភាព ម្យ៉ាងវិញទៀត ដើម្បីងាយស្រួលដល់សហពទ្ធ័នៅរស់នោះមានសិទ្ធិបង្កើតនៅចំណងអាពាហ៍ពិពាហ៍ថ្មីបាន។ មានន័យថា សបុត្រមរណភាព ក៏ជាឯកសារមួយដ៏សំខាន់នៅពេលដែលសពទ្ធ័ដែលនៅរស់នោះមានចំណងច្បាប់រៀបអាពាហ៍ពិពាហ៍ថ្មីជាមួយបុរស នារី គឺត្រូវយកសបុត្រមរណភាពនោះទៅបង្ហាញមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានអនាគតរបស់សហពទ្ធ័ថ្មីនោះ ទើបមន្ត្រីអត្រានុកូលដ្ឋានចេញនូវបណ្ណ័ប្រកាសរៀបអាពាហ៍ពិពាហ៍។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឲ្យធ្វើបុណ្យបូជា ឬបញ្ចុះសពប្រសិនបើអ្នកស្លាប់ដោយជំងឺធម្មតាដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋណាមួយ ។ ការចុះសៀវភៅមរណភាព នឹងចេញសំបុត្រមរណភាពត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។[63]

**៣.២.៣. មោឃភាពនៃអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍មួយមានអានុភាពលុះត្រាតែត្រូវបានទទួលស្គាល់ដោយច្បាប់។ ចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងភាន់ច្រឡំលើមនុស្ស នឹងដោយការបង្ខំ អាពាហ៍ពិពាហ៍នោះនឹងត្រូវបានចាត់ទុកថាជាមោឃះ ។[64]

**៣.២.៣.១. មោឃភាពដាច់ខាត**

**ក. ការភាន់ច្រឡំលើមនុស្ស**

[62] មាត្រា៩៨៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[63] មាត្រា៣៥ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអាត្រានុកូលដ្ឋាន

[64] មាត្រា៩៥៨ ចំណុច(ក)នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ការរៀបអាពាហ៍ពិពាហ៍ដែលអាចប្រព្រឹត្តទៅបាន ដោយរលូនលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងពីឆន្ទៈរបស់គូភាគីទាំងពីរ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះប្រព្រឹត្តទៅដោយ ការភាន់ច្រឡំនៃឈ្មោះ ឬរូបរាងភាគីម្ខាងទៀតអាចសុំមោឃភាពអាពាហ៍ពិពាហ៍នោះបានក្រោយពីខ្លួនបានដឹង។[65] ប៉ុន្តែការភាន់ច្រឡំលើអត្តចរិក ឬ អាកប្បកិរិយា ដោយគិតថាមនុស្សនោះចិត្តល្អ តែក្រោយរៀបអាពាហ៍ពិពាហ៍ហើយបែរជាចិត្តមិនល្អវិញ ភាគីដែលភាន់ច្រឡំបែបនេះ មិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បានឡើយ ។[66]

**ខ. ការបង្ខិតបង្ខំ**

ប្រសិនបើភាគីម្ខាងត្រូវបានបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀតដោយឪពុក ម្តាយ ឬ អាណាព្យាបាល ឬ តតិយជន ភាគីនោះអាចដាក់ពាក្យសុំមោឃភាពអាពាហ៍ពិពាហ៍បាន។ អាពាហ៍ពិពាហ៍មួយដែលអាចយកជាការបានលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងដោយ ភាគីទាំងពីរមានឆន្ទៈព្រមព្រៀងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ការបង្ខិតបង្ខំភាគីដែលគ្មានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាវាផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

**៣.២.៣.២. មោឃភាពមិនដាច់ខាត**

អាពាហ៍ពិពាហ៍មួយត្រូវបានចាត់ទុកជាមោឃភាព ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះមិនបានបំពេញបែបបទទៅតាមផ្លូវច្បាប់ដូចជា ការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឬ មិនបានជូនដំណឹងជាសាធារណៈជាដើម។ ប៉ុន្តែប្រសិនមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នោះមិនត្រូវបានរារាំងដោយសារហេតុនោះឡើយ ។[67]

**ក. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

ប្រសិនបើ ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅកាន់ទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានខាងនារីនោះទេ គេអាចប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍នោះបាន ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយច្បាប់ប្រទេសកម្ពុជាមិនបានចែងច្បាស់អំពីអ្នកមានសិទ្ធិ ប្តឹងក្នុងករណីនេះទេ ។

**ខ. ភាគីមិនបានជូនដំណឹងជាសាធារណៈ**

[65] មាត្រា៩៥៨ ចំណុច(ខ)នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[66] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០១៣ ទំព័រទី៨៥

[67] មាត្រា៩៥៨ ចំណុច(ខ)នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ប្រសិនបើគូស្រករទាំងពីរ បានទទួលការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋាន ហើយ ប៉ុន្តែភាគីទាំងពីរមិនបានបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍តាមការកំណត់របស់មន្ត្រីអត្រានុកូលដ្ឋាននោះ គេអាចប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន ។

**គ. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច ប្រសិនបើសហព័ទ្ធទាំងពីរមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ សំបុត្រអាពាហ៍ពិពាហ៍ គេអាចប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន ។

**ឃ. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍**

ក្នុងករណីដែលសហព័ទ្ធទាំងពីរ បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចហើយនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំ/សង្កាត់ខាងលំនៅដ្ឋាននារី ប៉ុន្តែពួកគេមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋាន គេអាចស្នើសុំប្តឹងមោឃភាពអាពាហ៍ពិពាហ៍នោះបាន ។

សរុបមក ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងអំពីមូលហេតុមួយចំនួននៃមោឃៈភាពក៏ដោយ រាល់មូលហេតុនៃចំណុចមោឃភាពមិនដាច់ខាតនេះ ក្នុងករណីជាក់ស្តែង វាស្ទើរតែគ្មានអានុភាពក្នុងការរារាំងអាពាហ៍ពិពាហ៍នោះឡើយ ។

**៣.២.៤. ការលុបចោលអាពាហ៍ពិពាហ៍**

ការលុបចោលអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងលើគ្រប់អាពាហ៍ពិពាហ៍ដែលផ្ទុយនឹង បទប្បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ អ្នកដែលមានសិទ្ធប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍មានដូចជា ញាតិសន្តាន របស់ជននោះ ឬ តំណាងអយ្យការ។ ប៉ុន្តែនៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាព ហើយតំណាងអយ្យការពុំអាចទាមទារលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។[68]

ការលុបចោលអាពាហ៍ពិពាហ៍ទាំងនោះរួមមាន៖ អាពាហ៍ពិពាហ៍មិនគ្រប់អាយុ ទ្វេពន្ធភាព ការហាមឃាត់អំឡុងពេលរៀបអាពាហ៍ពិពាហ៍ថ្មី ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត នឹងញាតិពន្ធ ការឆបោក នឹងការកំហែងជាដើម ។

**៣.២.៤.១.អាពាហ៍ពិពាហ៍មិនទាន់គ្រប់អាយុ**

បុរស នឹងនារីមានអាយុមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ដូច្នេះរាល់អាពាហ៍ពិពាហ៍ដែលកូនក្រមុំ នឹងកូនកំលោះមានអាយុក្រោម១៨ឆ្នាំ ពួកគេអាចសុំប្តឹងលុបចោល

[68] មាត្រា៩៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

អាពាហ៍ពិពាហ៍នោះបាន។[69] ប៉ុន្តែប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។

ក្នុងករណីនេះដែរ ជននោះក៏នៅអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានក្នុងអំឡុងពេល៣ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ ។[70]

**៣.២.៤.២.ឯកពន្ធភាព**

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើចំណងអាពាហ៍ពិពាហ៍មុនមិនទាន់បានរំលាយតាមផ្លូវច្បាប់។ យោងច្បាប់ស្តីពីឯកពន្ធភាពបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្តីតែមួយ។

ដូច្នេះចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងរវាងជនមានសហព័ទ្ធហើយ នឹងជនដែលនៅលីវ អាពាហ៍ពិពាហ៍នោះ នឹងរងនូវការលុបចោល ព្រោះវាជាអាពាហ៍ពិពាហ៍ផ្ទុយច្បាប់ ។[71]

**៣.២.៤.៣. អំឡុងពេលរៀបអាពាហ៍ពិពាហ៍ថ្មី**

ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ម្តងទៀត ក្នុងពេលមិនទាន់ផុតរយៈពេល១២០ថ្ងៃ ក្រោយពេលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយអាពាហ៍ពិពាហ៍ថ្មីនោះត្រូវបានលុបចោលផងដែរ ។[72] ប៉ុន្តែក្នុងករណីដែលស្ត្រីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោលហើយបានសម្រាលកូន ឬ មានការបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត ការលុបចោលមិនមានអានុភាពទៅលើអាពាហ៍ពិពាហ៍ថ្មីឡើយ ។

**៣.២.៤.៤. ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត**

បុរស នឹងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយមានជាប់ចំណងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣ត្រូវបានហាមឃាត់។ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្តាយ នឹងកូនបង្កើត ឬ រវាងឪពុកម្តាយចិញ្ចឹម នឹងកូនសុំ ហើយទោះបីមានការបញ្ចប់នូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ នឹងកូនបង្កើត ឬ ការកាត់កាល់រវាងឪពុកម្តាយចិញ្ចឹម នឹងកូនសុំហើយក៏ដោយ អាពាហ៍ពិពាហ៍ទាំងនេះអាចត្រូវបានលុបចោលផងដែរ។[73]ដូច្នេះអ្នកដែលមានសិទ្ធទាមទារលុបចោលមានដូចជា ភាគីនីមួយៗនៃញាតិសន្តានរបស់

[69] មាត្រា៩៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[70] មាត្រា៩៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[71] មាត្រា៩៦០ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[72] មាត្រា៩៦២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[73] មាត្រា៩៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ជននោះ នឹងតំណាងអយ្យការអាចទាមទារទៅតុលាការឱ្យលុបចោលបាន ប៉ុន្តែនៅក្រោយពេលភាគីណាម្ខាង បានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានទេ ។[74]

**៣.២.៤.៥. ការឆបោក**

អាពាហ៍ពិពាហ៍រវាងគូស្រករទាំងពីរដែលកើតឡើងដោយការឆបោករបស់ភាគីណាម្ខាង ឬ តតិយជន ដោយ មធ្យោបាយឲ្យភាគីម្ខាងទៀតធ្លាក់ទៅក្នុងការភ័ន្តច្រឡំ ភាគីដែលបានបង្ហាញឆន្ទៈដោយការឆបោកនោះ អាចស្នើទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍នោះបាន។[75] សិទ្ធិប្តឹងលុបចោលអាពាហ៍ពិពាហ៍នោះមាន ត្រឹមតែ៣ខែប៉ុណ្ណោះ ចាប់តាំងពីពេលដែលភាគីបានរកឃើញការឆបោកនោះ ឬការរិតត្បិតសេរីភាពត្រូវបានបើក ចំហ។ បើផុតរយៈពេលខែ ភាគីមិនអាចប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍នោះ ឬ បានសុខចិត្តទទួលស្គាល់ អាពាហ៍ពិពាហ៍ដោយការឆបោកនោះ សិទ្ធិក្នុងការប្តឹងលុបចោលអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរលត់ ហើយ។[76]

**៣.២.៤.៦. ការគំរាមកំហែង**

អាពាហ៍ពិពាហ៍រវាងគូស្រករទាំងពីរដែលកើតឡើងដោយការគំរាមកំហែងរបស់ភាគីម្ខាងទៀត ឬ របស់ តតិយជនតាមគ្រប់មធ្យោបាយដល់ភាគីម្ខាងទៀត មិនសុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពី ឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមគំហែងនោះអាចសុំប្តឹងលុបអាពាហ៍ពិពាហ៍នោះបាន។ រយៈពេលនៃការប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍នេះគឺដូចគ្នានឹងករណីឆបោកដែរ។

**៣.២.៥. ការអវត្តមាននិងការប្រកាសបាត់ខ្លួន**

ប្រសិនបើគេពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងកំឡុងពេល ៥ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ន្ធអ្នកដែលត្រូវបានសន្មតថា ជា សន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកមានផលប្រយោជន៍សំខាន់ផ្សេងទៀតតាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។

ដូចគ្នាផងដែរក្នុងករណីដែលបុគ្គលដែលចូលទៅក្នុងតំបន់មានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវា ដែលលិច រំជួយដី អគ្គីភ័យ ស៊ូណាមិ ការរអិលផ្ទាំងទឹកកកពីភ្នំជាដើមដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ជីវិត

[74] មាត្រា៩៦០ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[75] មាត្រា៩៦៣ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[76] មាត្រា៩៦៣ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងកំឡុងពេលមួយឆ្នាំ ក្រោយចប់សង្គ្រាម ឬ ក្រោយព្រឹត្តិការណ៍ផ្សេងៗទាំងនោះត្រូវបានបញ្ចប់។

ក្នុងករណីទាំងពីរខាងលើនេះ សហព័ន្ធរបស់អ្នកអវត្តមាន ឬ បាត់ខ្លួនអ្នកដែលត្រូវសន្មតថា ជាសន្តតិជន អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់អាចស្នើសុំតុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន ឬ បាត់ខ្លួនដើម្បីប្រកាសអំពីការបាត់ខ្លួន។ ក្រោយពេលតុលាការប្រកាសសេចក្តីសម្រេច ឬសាលក្រមអំពីការបាត់ខ្លួនអ្នកដែលបាត់ខ្លួន សហព័ទ្ធដែលនៅរស់មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

ដូច្នេះ ការប្រកាសបាត់ខ្លួននឹងបង្កើតអនុភាពគតិយុត្តដ៏សំខាន់ហេតុដូច្នេះហើយ គឺត្រូវធ្វើការដាស់តឿនជាសាធារណៈ[77] ព្រមទាំងមានកំណត់នៅអំឡុងពេលដែលត្រូវដាស់តឿននេះ ប្រយោជន៍ដល់ជនដែលអវត្តមាន ឬ អ្នកដែលបានដឹងដំណឹង ឬ បានឃើញជនដែលអវត្តមាននោះមករាយការណ៍។ តុលាការដែលមានសមត្ថកិច្ចសម្រាប់ធ្វើការដាស់តឿនជាសាធារណៈ ជាតុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន។

### ៣.២.៦. ការលែងលះ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវសិទ្ធិនិងសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការជ្រើសរើសគូស្រករ សិទ្ធិសេរីភាព កាតព្វកិច្ច និងករណីកិច្ចរបស់សហព័ទ្ធទាំងពីរក្នុងគោលបំណងរក្សាចំណងអាពាហ៍ពិពាហ៍ឲ្យបានគង់វង្សស្ថិតស្ថេរ។ ប៉ុន្តែដោយមានជនខិលខូចមួយចំនួន ដើម្បីកេងចំណេញផលប្រយោជន៍ណាមួយពីសហព័ន្ធម្ខាងទៀតក្រោយពេលរៀបអាពាហ៍ពិពាហ៍ ពួកគេតែងតែរកមូលហេតុនានាដើម្បីធ្វើការលែងលះ។ ការលែងលះដោយគ្មានមូលហេតុត្រឹមត្រូវនេះ បានធ្វើឲ្យជនខិលខូចទាំងនេះរួចផុតពីការទទួលខុសត្រូវក្នុងនាមជាឪពុក ជាម្តាយ ដែលមានកូននៅក្នុងបន្ទុក។ កូនរបស់ពួកគេបានក្លាយជាជនរងគ្រោះដោយផ្ទាល់ដូចជា ក្លាយជាក្មេងកំព្រាឪពុក ឬ ម្តាយ កង្វះអាហាររូបត្ថម្ភ និងការបីបាច់ថែរក្សាពីឪពុកម្តាយ និងការខ្វះភាពកក់ក្តៅពីក្រុមគ្រួសារ។

#### ៣.២.៦.១. មូលហេតុនៃការលែងលះ

មូលហេតុនៃការលែងលះមានដូចជា បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធបានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ មិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនិងគោលបំណងនៃអាពាហ៍ពិពាហ៍ និងករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ដោយគ្មានសង្ឃឹមនឹងអាចបដិទានឡើងវិញបាន។[78]

---

[77] មាត្រា៩២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[78] មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

**ក. ការប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ**

អំពើផិតគឺជាការរួមសេវនកិច្ចរវាងបុរស ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[79] ការប្រព្រឹត្តអំពើផិតនេះគឺជាមូលហេតុដ៏ចម្បងមួយនៃការលែងលះក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ពីព្រោះវាអាចបំផ្លាញនូវមនោសញ្ចេតនារវាងសហព័ទ្ធទាំងពីរដែលបានកសាងជាមួយគ្នាជាច្រើនឆ្នាំក្នុងរយៈពេលតែមួយពព្រិចភ្នែក។

**ខ. ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ**

ការមិនបានផ្តល់មូលហេតុត្រឹមត្រូវក្នុងការចុះចោលផ្ទះ ឬ បោះបង់សហព័ទ្ធម្ខាងទៀតដោយចេតនាក្នុងរយៈពេលមួយយ៉ាងយូរ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំលែងលះបាន ការបោះបង់នេះគឺសំដៅដល់បំណងរបស់សហព័ន្ធម្ខាង ដែលចង់រួចផុតពីការទទួលខុសត្រូវទៅលើសហព័ទ្ធម្ខាងទៀតឬក្រុមគ្រួសារដូចជាកូនជាដើម។ ទោះបីជាយ៉ាងណាក៏ដោយមូលហេតុមួយចំនួនដូចជាការទៅបន្តការសិក្សានៅក្រៅប្រទេស និង ការទៅរកស៊ីឆ្ងាយស្រុកមិនអាចក្លាយជាមូលហេតុមិនត្រឹមត្រូវក្នុងការបោះបង់សហព័ទ្ធខាងទៀតទេ។

**គ. ការមិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់អស់រយៈពេលជាង១ឆ្នាំ**

ក្នុងករណីសហព័ន្ធម្ខាងទៀតបានចុះចោលផ្ទះឬចាកចេញពីសហព័ទ្ធម្ខាងទៀត និងក្រុមគ្រួសារហើយមិនបានត្រឡប់មកវិញ ឬ មិនជូនដំណឹងទៅសហព័ទ្ធម្ខាងទៀតក្នុងរយៈពេលមួយឆ្នាំ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យទៅតុលាការសុំប្តឹងលែងលះបាន។ ប៉ុន្តែប្រសិនបើការចុះចោលផ្ទះ ឬ ការរស់នៅបែកគ្នាក្នុងរយៈពេល១ឆ្នាំ ដោយការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត នោះជាមូលហេតុនៃការសុំលែងលះបាននោះទេ។ មួយវិញទៀតផងដែរ ទោះបីជាសហព័ទ្ធម្ខាងបានស្គាល់ពីកន្លែងស្នាក់នៅថ្មីរបស់សហព័ទ្ធម្ខាងទៀត ប៉ុន្តែសហព័ទ្ធនោះមិនមានបំណងវិលត្រឡប់មករស់នៅជាមួយខ្លួនវិញ នោះសហព័ទ្ធនៅម្ខាងទៀតអាចប្តឹងសុំលែងលះបានដូចករណីខាងលើផងដែរ « ផ្ទុយទៅវិញ» ក្នុងករណីដែលមិនបានដឹងអំពីវត្តមានរបស់សហព័ទ្ធមួយណាថាស្លាប់ ឬ រស់ក្នុងរយៈពេលមួយឆ្នាំ សហព័ទ្ធម្ខាងទៀតមិនអាចដាក់ពាក្យសុំលែងលះបានតែម្តងទេ ប៉ុន្តែទៅដាក់ពាក្យសុំតុលាការចេញសាលក្រមស្តីពីការបាត់ខ្លួនហើយសាលក្រមនេះមានរយៈពេល ១៥ថ្ងៃ សម្រាប់ប្តឹងទាស់។ នៅពេលដែលរយៈពេលនេះផុតកំណត់ទៅហើយ ទើបសហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន។ក្នុងរយៈ

[79] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព, ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦

ពេលផុតកំណត់ខាងលើ ទោះបីជាសហព័ទ្ធដែលបានបាត់ខ្លួនត្រឡប់មកវិញក៏ដោយ ក៏មិនអាចដាក់ពាក្យសុំទៅតុលាការឲ្យមោឃភាពឬលុបចោលបានឡើយ។

**ឃ. សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍**

គោលបំណងនៃអាពាហ៍ពិពាហ៍ គឺចង់ឲ្យសហព័ទ្ធទាំងពីររស់នៅជាមួយគ្នាក្នុងលំនៅសង្វាសរួមគ្នាថែរក្សាគ្នាទៅវិញទៅមក និងស្រឡាញ់គ្នារហូតដល់ចាស់កោងខ្នង។ ប៉ុន្តែគូស្វាមីភរិយាទាំងអស់មិនអាចបំពេញគោលបំណងនេះបានទាំងអស់នោះទេ ពីព្រោះក្នុងគ្រួសារខ្លះ ភាគីបុរសដែលជាស្វាមីត្រូវចាកចេញពីភរិយា ឬក្រុមគ្រួសារជាច្រើនខែ ដើម្បីស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ប៉ុន្តែនេះមិនមែនជាមូលហេតុនៃការលែងលះនោះទេ។ មូលហេតុដែលសហព័ទ្ធទាំងពីរឈានដល់ការលែងលះ គឺដោយសារសហព័ទ្ធទាំងពីរតែងតែមានជម្លោះនឹងគ្នា ហើយបានរស់នៅបែកគ្នា ក្រោយពេលមានជម្លោះនោះជាបន្តបន្ទាប់អស់រយៈពេលជាងមួយឆ្នាំ ការរស់នៅបែកគ្នាប្រភេទនេះ គឺមានភាពផ្ទុយនិងគោលបំណងនៃអាពាហ៍ពិពាហ៍។ ក្នុងករណីនេះសហព័ទ្ធម្ខាងអាចដាក់ពាក្យសុំលែងលះពីសហព័ទ្ធម្ខាងទៀតបាន។

**ង.ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមនឹងអាចបដិទានវិញបាន**

ក្នុងករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយមិនអាចស្តារទំនាក់ទំនងចំណងអាពាហ៍ពិពាហ៍នេះវិញបានអាចមានមូលហេតុច្រើនយ៉ាងណាស់ដែលធ្វើឲ្យប្រេះឆាចំណងអាពាហ៍ពិពាហ៍នេះ។ ក្រមរដ្ឋប្បវេណី បានផ្តល់សិទ្ធិ និងសេរីភាពមួយកម្រិតថែមទៀតដល់ស្វាមីភរិយា គឺការរស់នៅជាមួយគ្នាឈរលើគោលការណ៍ស្ម័គ្រចិត្ត ការស្រុះស្រួលគ្នាទៅវិញទៅមករវាងភាគីទាំងពីរ ក្នុងករណីដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយមិនអាចស្តារឡើងវិញបាន ហើយគេមិនអាចបង្ខិតបង្ខំមនុស្សឲ្យរស់នៅជាមួយគ្នា ដោយរស់នៅមិនចុះសម្រុងនឹងគ្នា ដោយគ្មានផ្លូវសម្រាប់ដោះស្រាយបានឡើយ ។

មូលហេតុនៃការបែកបាក់គ្នានៅក្នុងសង្គមគ្រួសារខ្មែរអាចមានច្រើនយ៉ាងទៀតដូចជា អំពើហិង្សាក្នុងគ្រួសារដែលបានប្រព្រឹត្តលើប្តីឬប្រពន្ធ ឬកូនក្នុងបន្ទុក ឬជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ ឬនៅក្នុងបន្ទុក ការមាក់ងាយពីសំណាកសហព័ទ្ធម្ខាងទៅលើសហព័ទ្ធម្ខាងទៀត អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ គ្មានការព្រមព្រៀងមុន ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្រួសារពីសំណាក់ឪពុកម្តាយញាតិមិត្ត ឬសមាជិកណាមួយទៀតដែលធ្វើឲ្យគ្រួសារងាយនឹងបែកបាក់ឬមិនចុះសម្រុងនឹងគ្នា ការមិនចុះសម្រុងគ្នាកើតឡើងដោយការមិនទុកចិត្តគ្នា ការការប្រច័ណ្ឌគ្នាទៅវិញទៅមក។ ជួនកាលមានករណីជាច្រើនទៀតដែលភាគីមានទំនាស់នឹងគ្នា និងមិនចុះសម្រុងគ្នា ហើយដែលភាគីមិនអាចផ្សះផ្សាទំនាស់រវាងពួកគេទាំងពីរនាក់បាន។

ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារការលែងលះដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។

ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះផ្ទៃសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន។[80]

**៣.២.៦.២.ករណីផ្សេងទៀតនៃការលែងលះ**

**ក. ការលែងលះដោយឯកតោភាគី**

ការលែងលះដោយឯកតោភាគីមានន័យថា សហព័ទ្ធម្ខាងអាចធ្វើការប្តឹងសុំលែងលះសហព័ទ្ធម្ខាង ទៀតបាន ដោយមិនចាំបាច់មានការព្រមព្រៀងពីសហព័ទ្ធដែលត្រូវបានប្តឹងនោះ ទោះបីជាសហព័ទ្ធម្ខាងរកឃើញ មិនឃើញកំហុសរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ។ សហព័ទ្ធម្ខាងអាច ដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំលែងលះដោយយល់ឃើញថា ខ្លួនមិនអាចបន្តជីវិតជាស្វាមី ឬភរិយាបន្តទៀតបាន។ ការលែងលះដោយឯកតោភាគីនេះ គឺត្រូវពិនិត្យទៅលើធាតុផ្សំសំខាន់ៗ២គឺ ការលែងលះដោយមានកំហុស និង ការលែងលះដោយឥតកំហុស។

**ក .១.ការលែងលះដោយមានកំហុស**

ក្នុងករណីដែលសហព័ទ្ធម្ខាងបានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ធ្ងរ ដែលសហព័ទ្ធម្ខាងទៀតមិនអាចទទួលយកបាន ឬ កាលៈទេសៈខ្លះនៅពេលដែលសហព័ទ្ធម្នាក់ បានប្រព្រឹត្តអំពើល្មើសយ៉ាងធ្ងន់ធ្ងរលើករណីយកិច្ចជាប្តីប្រពន្ធ។ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន ដោយបញ្ជាក់ពីកំហុសរបស់សហព័ទ្ធមួយនោះឱ្យបានច្បាស់លាស់ទៅកាន់តុលាការ ។

**ក.២.ការលែងលះដោយឥតមូលហេតុ**

ការលែងលះដោយឥតកំហុស គឺផ្អែកលើសញ្ញាណទំនើបនៃសុភមង្គលផ្ទាល់ខ្លួនច្រើនជាង ការលែងលះគ្នាដោយផ្អែកលើកំហុស។ គំនិតមួយនៅពីខាងក្រោយការលែងលះគ្នាដោយឥតកំហុស គឺថា មនុស្សត្រូវតែមានសេរីភាពក្នុងការបញ្ចប់ទំនាក់ទំនងដែលលែងជាប្រភពនៃការពេញចិត្តផ្ទាល់ខ្លួនតទៅទៀត។ ការលែងលះ

[80] មាត្រា៩៧៨កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ដោយឥតកំហុសនេះក៏ត្រូវផ្អែកលើទស្សនៈដែលថា ប្រសិនបើសហព័ទ្ធម្នាក់ពិតជាមានបំណងលែងលះមែនគឺពុំមែនជាការល្អទេក្នុងការបង្ខំឱ្យសហព័ទ្ធនោះឱ្យនៅរក្សាចំណងអាពាហ៍ពិពាហ៍។[81]

ការលែងលះដោយឥតកំហុស សហព័ទ្ធម្ខាងមិនចាំបាច់ខិតខំស្វែងរកកំហុសរបស់សហព័ទ្ធម្ខាងទៀតនោះទេ គឺគ្រាន់តែបង្ហាញឆន្ទៈ ឬ បំណងរបស់ខ្លួនក្នុងការចង់បញ្ចប់ចំណងអាពាហ៍ពិពាហ៍ នេះជាមូលហេតុគ្រប់គ្រាន់បាត់ទៅហើយ។

**ខ. ការលែងលះដោយការព្រមព្រៀង**

ការលែងលះដោយការព្រមព្រៀង គឺចង់បង្ហាញថាសហព័ទ្ធទាំងពីរមានឆន្ទៈ ឬ បំណងក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។ ក្រោយពីការសម្រេចចិត្តថានឹងផ្តាច់ចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន បើបំណងផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេនៅតែមាន។ ពិតណាស់ទាំងនេះគឺជាសេរីភាពរបស់បុគ្គលក្នុងការជ្រើសរើសផ្លូវដើររបស់ពួកគេ ប្រសិនបើសហព័ទ្ធទាំងពីរមានបំណងចង់លែងលះហើយ ការបង្ខិតបង្ខំឱ្យពួកគេទាំងពីររក្សាចំណងអាពាហ៍ពិពាហ៍ក៏ គ្មានតម្លៃទៀតដែរ។ ការលែងលះដោយការព្រមព្រៀងកើតឡើងនៅពេលដែលសហព័ទ្ធទាំងពីរ បានអស់អារម្មណ៍មនោសញ្ចេតនាជាមួយគ្នា (លែងស្រឡាញ់គ្នា) ហើយចង់លែងលះគ្នា ដោយការលែងលះនេះមិន មែនជាកំហុសរបស់ភាគីទាំងសងខាងណាឡើយ។[82]ភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបានក្នុងករណីដែលភាគីទាំងសងខាង បានព្រមព្រៀងអំពីការលែងលះគ្នា។

ហើយតុលាការអាចឲ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[83]

[81] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០១៣ទំព័រទិ១៨៣

[82] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០១៣ទំព័រទិ១៨៩

[83] មាត្រា៩៧៩ កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ការរៀបអាពាហ៍ពិពាហ៍ ទោះបីជាមានលក្ខខណ្ឌបែបបទនីតិវិធីជាច្រើនក៏ដោយ ក៏ប្រជាពលរដ្ឋមួយចំនួនមិនបានយល់ដឹងគ្រប់គ្រាន់ និងមិនបានអនុវត្តឲ្យបានពេញលេញនោះទេ ដែលជាហេតុនាំឲ្យមានបញ្ហាជាច្រើនក្រោយពេលរៀបអាពាហ៍ពិពាហ៍។ សព្វថ្ងៃនេះប្រទេសមានការរីកចម្រើនព្រមទាំងអភិវឌ្ឍជាច្រើននៃទីក្រុង និងទៅតាមខេត្តតំបន់មួយចំនួនផងដែរ។ ការរីកចម្រើននេះហើយធ្វើឲ្យផ្នត់គំនិតប្រជាជនខ្មែរយកគំរូទៅតាមប្រទេសដទៃទៀត ហើយមិនបានប្រកាន់ខ្ជាប់ទៅតាមការរៀបអាពាហ៍ពិពាហ៍ប្រពៃណី ដែលជាទំនៀមទម្លាប់ដ៏ល្អពីបុព្វបុរសជំនាន់មុន ដូច្នេះប្រជាជនខ្មែរគ្រប់រូប គួរគប្បីថែរក្សាប្រពៃណីដ៏ល្អនេះ ក៏ដូចជាប្រៀបបានទៅនឹងសីលធម៌សង្គមផងដែរ។ ទោះបីជាប្រទេសមានសន្តិភាព មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពគ្រប់គ្រាន់មានសិទ្ធិក្នុងការជ្រើសរើសមនុស្សដែលខ្លួនស្រឡាញ់ ប៉ុន្តែការដែលមិនបានគោរពទៅនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺពួកគេមិនត្រូវបានច្បាប់ការពារនេះទេ ហើយបានក្លាយទៅជារឿងដ៏ស្មុគស្មាញនៅក្នុងសង្គមគ្រួសារខ្មែរ។ ការបង្កើតគ្រួសារ គឺជាបញ្ហាមួយយ៉ាងសំខាន់នៅក្នុងសង្គមជាតិនីមួយៗ ព្រោះថា ការបង្កើតគ្រួសារត្រូវបំពេញតាមបែបបទច្បាប់ ទើបសង្គមជាតិមានសណ្តាប់ធ្នាប់និងរបៀបរៀបរយល្អ។ ប្រសិនបើគ្រួសារទទួលបានការអប់រំល្អ កូនប្រុស កូនស្រីដែលជាទំពាំងស្នងឫស្សីនៃសង្គមជាតិល្អផងដែល។ នីតិវិធីការរៀបអាពាហ៍ពិពាហ៍ពុំមែនជាបញ្ហាលំបាកនោះទេ បញ្ហាប្រឈមគឺ ប្រជាពលរដ្ឋពុំទទួលបានព័ត៌មានទូលំទូលាយអំពីចំណេះដឹងផ្នែកច្បាប់ ជាពិសេសការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើឡើងនៅប្រទេសកម្ពុជា។ កត្តាទាំងអស់នេះគឺ បណ្តាលមកពីប្រជាពលរដ្ឋខ្មែរពុំទាន់យល់ដឹងច្បាស់អំពីច្បាប់។ បញ្ហាប្រឈមបច្ចុប្បន្នមាន គូស្រករខ្លះបានរៀបអាពាហ៍ពិពាហ៍ដោយមានការបង្ខិតបង្ខំពីឪពុកម្តាយ និងគូស្រករខ្លះទៀត រស់នៅបែបអនីតិសង្វាសជាមួយគ្នាដោយពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងគូស្រករមួយចំនួនទៀត គឺគ្រាន់តែបានរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីប៉ុណ្ណោះ ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍បានត្រឹមត្រូវនោះទេ។ ក្រោយពីពួកគាត់បានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ គឺមានបញ្ហាមួយចំនួនដែលកើតឡើងដូចជា ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ការបោះបង់សហព័ទ្ធ ការផិតក្បត់មានទ្វេពន្ធភាពជាដើម ដែលជាហេតុនាំឲ្យប៉ះពាល់ដល់ ការអប់រំ និងសង្គមផងដែរ។ ខ្លះទៀតប្រជាពលរដ្ឋមួយចំនួន ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចត្រូវជនខិលខូចមួយចំនួនបោកយកទៅលក់នៅឯបរទេសទៀតផងពិសេសតំបន់ជនបទ។ ទោះបីជាមានចំណងអាពាហ៍ពិពាហ៍ហើយក៏ដោយក៏ចំណងអាពាហ៍ពិពាហ៍មិនត្រូវបានចាត់ទុកជាកត្តាចម្បងក្នុងការធានានូវការស្រឡាញ់ថែរក្សា និងជួយសង្គ្រោះគ្នារវាងសហព័ទ្ធទាំងពីរបានឡើយ។ ប្រសិនបើសហព័ទ្ធទាំងពីរមិនអាចរួមរស់នឹងគ្នាបន្តទៅទៀតបាន ពួកគេអាចបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេបានដោយការលែងលះ។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានដើរតួយ៉ាងសំខាន់ក្នុងការបង្កើត និងបញ្ចប់អាពាហ៍ពិពាហ៍ នៅកម្ពុជា។

## អនុសាសន៍

ក្រោយពីពួកយើងទាំងពីរបានសិក្សាស្រាវជ្រាវ និងសរសេរចងក្រងនូវសារណាបញ្ចប់ការសិក្សាមួយនេះ មកពួកយើងទាំងពីរនាក់បានមើលឃើញថា ការរៀបអាពាហ៍ពិពាហ៍មួយដែលស្របទៅតាមនីតិវិធីច្បាប់ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហព័ទ្ធ និងការរួមរស់នៅជាមួយគ្នាទៅថ្ងៃអនាគត។ ប៉ុន្តែប្រជាពលរដ្ឋខ្មែរមួយចំនួននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ពុំទាន់មានការយល់ដឹងឱ្យបានស៊ីជម្រៅពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ច្បាស់លាស់នៅឡើយ ដែលជាដើមហេតុធ្វើឲ្យពួកគេតែងតែរៀបអាពាហ៍ពិពាហ៍ទៅតាមទម្រង់ប្រពៃណី ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមទម្រង់ច្បាប់ដែលកំពុងអនុវត្ត។

ដោយយោងតាមទស្សនៈរបស់យើងខ្ញុំទាំងពីរនាក់ ពួកយើងគួរគប្បីធ្វើការផ្សព្វផ្សាយឲ្យកាន់តែស៊ីជម្រៅអំពីទិដ្ឋភាពច្បាប់សំខាន់ៗមួយចំនួនមិនមែនត្រឹមតែច្បាប់ស្តីអំពីអាពាហ៍ពិពាហ៍នោះទេ។ ជាពិសេសសម្រាប់ប្រទេសកម្ពុជាយើង គឺប្រជាពលរដ្ឋភាគច្រើននៅតែជាប់ជិតដាមនឹងទំនៀមទំលាប់ ប្រពៃណី ដោយហេតុថាពួកគាត់ពុំបានយល់ដឹងអំពីច្បាប់ និងផលប្រយោជន៍អំពីការចុះសំបុត្រអាពាហ៏ពិពាហ៏របស់ពួកគេនៅឡើយ។ ជាស្នូលនៅការផ្សព្វផ្សាយឱ្យកាន់តែច្បាស់ គឺត្រូវតែមានការចូលរួមដោយម៉ត់ចត់ពីសំណាកអាជ្ញាធរដែនដី និងមន្ត្រីអាត្រានុកូលដ្ឋាន អង្គការគប្បីត្រូវចូលរួមក្នុងការត្រួតពិនិត្យបណ្តុះបណ្តាលដល់ មន្ត្រីឃុំ/សង្កាត់ ដើម្បីបង្កើនបច្ចេកទេសឱ្យមន្ត្រីឃុំ/សង្កាត់អនុវត្តការងារប្រកបដោយភាពឆាប់រហ័ស និងកាត់បន្ថយនីតិវិធីស្មុគស្មាញមកជាភាពសាមញ្ញ ហើយមានលក្ខណៈងាយស្រួលជូនដល់ប្រជាពលរដ្ឋ ដើម្បីកែប្រែភាពអសកម្មមួយចំនួនរបស់មន្ត្រីឃុំ/សង្កាត់ គប្បីត្រូវតែប្រតិបត្តិតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានភាពស្មើគ្នាចំពោះមុខច្បាប់។

ក្នុងការផ្តល់នូវដំណឹង ឬជាមតិជូនដល់ប្រជាពលរដ្ឋរបស់ខ្លួនទៅតាមតម្រូវការជាក់ស្តែងដែលអាចជួយដោះស្រាយបានអំពីភាពកង្វះខាត ក៏ដូចជាការផ្តល់នូវសេវាកម្មដើម្បីឱ្យមានភាពល្អប្រសើរទៅដល់ពួកគាត់ដែលភាគច្រើនតែងតែជួបប្រទះនៅបញ្ហាទៅលើ លិខិតឯកសារនៃអាពាហ៍ពិពាហ៍ផ្សេងៗ ក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអាចជាសេវានៅពេលដែលប្រជាពលរដ្ឋមានតម្រូវការក្នុងការសហការប៉ុន្តែពុំបានទទួលសេវាទាន់ពេលវេលា ឬភាពយឺតយ៉ាវក្នុងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋនៃឯកសារដែលតម្រូវការជាចាំបាច់។

ហេតុដូចនេះហើយ ទើបបានជាអាត្រាកំណើននៃប្រជាពលរដ្ឋខ្មែរភាគច្រើនតែងតែរៀបអាពាហ៍ពិពាហ៍រួចហើយក៏ពិតមែន ប៉ុន្តែពួកគេបែរជាមករស់នៅបែបអនីតិសង្វាស់ដែលមានចែងផ្ទុយពីច្បាប់ទៅវិញ។ មិនត្រឹមតែផ្ទុយពីច្បាប់ប៉ុណ្ណោះនោះទេ វាក៏ជាបញ្ហាដែលពិបាកនិងដោះស្រាយទៅថ្ងៃអនាគតថែមទៀតផង ដូចជាកត្តាបែងចែកទ្រព្យសម្បត្តិ កូន និងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ផងដែរ។ ដូច្នេះមន្ត្រីឃុំ/សង្កាត់ត្រូវត្រួតពិនិត្យពាក្យសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឱ្យបានល្អិតល្អន់ មុននឹងអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ដើម្បីជៀសវាងការកើតមានបញ្ហាក្រោយរៀបអាពាហ៍ពិពាហ៍។ ប្រជាពលរដ្ឋត្រូវចូលរួមគោរពច្បាប់ជាធរមានឱ្យបាន

គ្រប់ៗគ្នាពិសេសត្រូវនាំគ្នារៀបអាពាហ៍ពិពាហ៍តាមច្បាប់ដែលបានចែង ដើម្បីផ្តល់ជាផលប្រយោជន៍ចំពោះសហព័ទ្ធទាំងសងខាងនៅមុន ។

# បញ្ជីឯកសារយោង

## ឯកសារបទដ្ឋានគតិយុត្ត


1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
2. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
3. ច្បាប់ស្តីពីឯកពន្ធភាព, ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦
4. ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០
5. អនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ
6. អនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន


## សៀវភៅ និងប្រភពផ្សេងៗ


1. សេចក្តីព្រាងក្រមរដ្ឋប្បវេណី និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥, គន្ថីទី៧ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩) រៀបរៀងឡើងដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុន
2. សេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអាត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអាត្រានុកូលដ្ឋានចល័ត
3. កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអាត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអាត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ឆ្នាំ២០១២
4. សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, បណ្ឌិត ឥន យឿន ភាគ១បោះពុម្ពឆ្នាំ២០១៣
5. សៀវភៅសិក្សាសង្គមថ្នាក់ទី៩ អំពីពិធីរៀបមង្គលការ, ក្រសួងអប់រំយុវជន និងកីឡា, ឆ្នាំ១៩៩៩
6. https://khmer.rvasia.org/ , ២០២០។

## ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣
- **ឧបសម្ព័ន្ធទី២៖** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារក្រឹត្យច្បាប់លេខ ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៨៨
- **ឧបសម្ព័ន្ធទី៣៖** ច្បាប់ស្តីពីឯកពន្ធភាព ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦
- **ឧបសម្ព័ន្ធទី៤៖** ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- **ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យលេខ ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអាត្រានុកូលដ្ឋាន
- **ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យលេខ ១៨៣ អនក្រ.បក. ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងជនបរទេស
- **ឧបសម្ព័ន្ធទី៧៖** លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ
- **ឧបសម្ព័ន្ធទី៨៖** បញ្ជីអាពាហ៍ពិពាហ៍
- **ឧបសម្ព័ន្ធទី៩៖** ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- **ឧបសម្ព័ន្ធទី១០៖** សំបុត្រកំណើត
- **ឧបសម្ព័ន្ធទី១១៖** សេចក្តីចម្លងសំបុត្រកំណើត
- **ឧបសម្ព័ន្ធទី១២៖** សំបុត្រអាពាហ៍ពិពាហ៍(អេតាស៊ីវិល)
- **ឧបសម្ព័ន្ធទី១៣៖** បញ្ជីមរណភាព
- **ឧបសម្ព័ន្ធទី១៤៖** សៀវភៅគ្រួសារ
- **ឧបសម្ព័ន្ធទី១៥៖** និងសៀវភៅស្នាក់នៅ
- **ឧបសម្ព័ន្ធទី១៦៖** ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង
- **ឧបសម្ព័ន្ធទី១៧៖** ពាក្យបណ្តឹងលែងលះ

ឧបសម្ព័ន្ធ ទី១

# រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ៣

## ស្តីពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

## មាត្រា ៤១.-

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

## មាត្រា ៤២.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

## មាត្រា ៤៣.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

## មាត្រា ៤៤.-

ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្ដល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវ-កម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩.-**

**ឧបសម្ព័ន្ធ ទី២**

# ច្បាប់
## ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅដោះស្រាយបញ្ហា និង ការពារការរៀបអាពាហ៍ពិពាហ៍ និង គ្រួសារ ធានាសមភាពរវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និង ក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្ដាយក្នុងការចិញ្ចឹមថែរក្សាកូន និង ជំរុញការបណ្ដុះបណ្ដាលសីលធម៌ និងការអប់រំកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

**មាត្រា ២.-**

ហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍ ។

## ជំពូកទី ២
## អំពីអាពាហ៍ពិពាហ៍
### ផ្នែកទី ១
### អំពីល័ក្ខខ័ណ្ឌដែលត្រូវមាន ដើម្បីរៀបអាពាហ៍ពិពាហ៍

**មាត្រា ៣.-**

អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឧឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាថា ខ្លួននឹងរួមសមគ្គសម្លាញជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែល មិនអាចរំលាយចោលវិញបានតាមចំនើងចិត្តរបស់ខ្លួន ។

**មាត្រា ៤.-**

បុរស និងនារី ដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់ អោយរៀប ឬរាំងមិនអោយរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍-ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥.-**

អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ។

**មាត្រា ៦.-**

មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

-បុគ្គលមានភេទដូចគ្នា

-បុគ្គលគ្មានពលានុភាពនៃលិង្គ

-បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់

-ជនវិកលចរិក ជនមិនដឹងខុសត្រូវ

-បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

**មាត្រា ៧.-**

អាពាហ៍ពិពាហ៍ត្រូវហាមឃាត់រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ចិញ្ចឹមក្តី ។

**មាត្រា ៨.-**

អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះ មានខាន់ស្លាក្តី ឥតខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមឪពុកម្តាយក្តី ជាញាតិលោហិតក្តី ឬជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី ៣ នេះផង ។

ក្នុងករណីពិសេស ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ បាន ។

**មាត្រា ៩.-**

ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព "ភាពមេម៉ាយ" ចំនួន ៣០០ ថ្ងៃ គិតពីថ្ងៃដែលប្តីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលសំរេចពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមជាស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសំរេចអោយប្តីប្រពន្ធនៅបែកគ្នា នោះសាលក្រមនៃការលែងលះត្រូវគិតវិធវភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ហើយក៏គ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈ ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន ។

ជនណាក៏ដោយ មិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ទ្ធដែលបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។

**មាត្រា ១១.-**

មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្តី ប្រពន្ធ ត្រូវប្តឹងដល់គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏បាន ។

**មាត្រា ១២.-**

ប្រធាន ឬសមាជិកនៃគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ក្នុងឋានៈជាមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រកាសផ្សាយជាសាធារណៈនូវអាពាហ៍ពិពាហ៍នោះ ដោយបិទប័ណ្ណប្រកាសនៅលំនៅរបស់នារី និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅរបស់បុរស និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសត្រូវចុះ :

១-ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅនៃអនាគតប្តី និងប្រពន្ធ

២-ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅរបស់ឪពុកម្តាយនៃអនាគតប្តី ប្រពន្ធ "បើឪពុក ឬម្តាយស្លាប់ត្រូវដាក់ថាស្លាប់ផង" ។

៣-រយៈពេលប្តឹងជំទាស់

**មាត្រា ១៣.-**

ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីអោយជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈ-ពេល ១០ ថ្ងៃ នេះពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។

**មាត្រា ១៤.-**

អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និង នារីដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី ។ កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជី

## អំពីបណ្តឹងទាស់មិនអោយរៀបអាពាហ៍ពិពាហ៍

**មាត្រា ១៥.-**

ក្នុងរយៈពេល ១០ ថ្ងៃ គិតពីថ្ងៃដែលបិទផ្សាយជាសាធារណៈ ញាតិក្តី ជនដែលមានប្រយោជន៏ក្នុងរឿងនេះក្តី អាចនឹងប្តឹងជំទាស់មិនអោយរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១៦.-**

បណ្តឹងជំទាស់នេះនឹងយកជាការបាន លុះណាតែអ្នកប្តឹងជំទាស់ចុះហត្ថលេខាលើពាក្យរបស់ខ្លួនដោយផ្ទាល់ដៃខ្លួនឯង ។

បណ្តឹងនេះត្រូវចង្អុលពីមូលហេតុនៃការប្តឹងទាស់ ។ មូលហេតុដែលអាចយកមកប្តឹងជំទាស់បាននោះ គឺអសមត្ថភាពរបស់បុរស ឬនារី ឬមានប្រការណាមួយដែលច្បាប់ហាមឃាត់ក្នុងមាត្រា ៥ វាក្យខ័ណ្ឌទីមួយ មាត្រា ៦ មាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ១៧.-**

បណ្តឹងទាស់នោះត្រូវអ្នកប្តឹងជំទាស់ ឬតំណាងរបស់ខ្លួនយកទៅជូនគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ខាងលំនៅនៃអនាគតប្រពន្ធ ។ គណៈកម្មាធិការនេះ ត្រូវសំរេចក្នុងរយៈពេល ៣ ថ្ងៃ គិតពីថ្ងៃទទួលបណ្តឹងទាស់ ។

បើអ្នកប្តឹងជំទាស់ ឬអនាគតប្តី ប្រពន្ធ មិនសុខចិត្តនឹងសេចក្តីសំរេចនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងទាស់ ដើម្បីសំរេច ។

**មាត្រា ១៨.-**

តុលាការប្រជាជន ត្រូវសំរេចចិត្តពីបណ្តឹងទាស់ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃបានទទួលសំណុំរឿង ។

សាលក្រមរបស់តុលាការប្រជាជន មិនអាចប្តឹងតវ៉ាបានឡើយ ទោះបីសាលក្រមនោះវាជាសាលក្រមកំបាំងមុខក៏ដោយ ។

**មាត្រា ១៩.-**

បើតុលាការប្រជាជនបដិសេធបណ្តឹងទាស់ចោល អនាគតប្តី ប្រពន្ធ អាចរៀបអាពាហ៍ពិពាហ៍បាន ។

បើតុលាការប្រជាជនចាត់ទុកបណ្តឹងទាស់នោះ ជាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់មិនអោយរៀបអា-ពាហ៍ពិពាហ៍ ។

## អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

### មាត្រា ២១..

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះចុះបញ្ជីនៅពេលដែលសហព័ទ្ធណាម្នាក់ឆ្កួត ឬមិនដឹងខុសត្រូវ ។ តែបើសហព័ទ្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំអោយទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

### មាត្រា ២២..

អាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ ឆ្នាំ ឬនារីអាយុតិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។

អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះនឹងលែងមោឃៈទៅវិញ កាលបើប្តី ឬប្រពន្ធនោះចំរើនវ័យដល់អាយុតាមបញ្ញត្តិច្បាប់ ឬ ក្នុងករណីដែលមានចែងក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ២ ។

### មាត្រា ២៣..

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈកាលបើសហព័ទ្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេចាប់បង្ខំអោយរៀបអាពាហ៍ពិពាហ៍ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះមិនធ្វើក្នុងរយៈពេល ៦ ខែ គិតពីថ្ងៃដែលគេលែងបង្ខំនោះមក ។

### មាត្រា ២៤..

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់រលាយ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ក្រោយនេះអាពាហ៍ពិពាហ៍មកមុនត្រូវបានរំលាយ ។

### មាត្រា ២៥..

អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខ័ណ្ឌទី ២ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

### មាត្រា ២៦..

មានតែសហព័ទ្ធ រដ្ឋអាជ្ញា និងជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

## អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

**មាត្រា ២១.-**

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះចុះបញ្ជីនៅពេលដែលសហព័ទ្ធណាម្នាក់ឆ្កួត ឬមិនដឹងខុសត្រូវ ។ តែបើសហព័ទ្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំអោយទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

**មាត្រា ២២.-**

អាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ ឆ្នាំ ឬនារីអាយុតិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។

អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះនឹងលែងមោឃៈទៅវិញ កាលបើប្ដី ឬប្រពន្ធនោះចំរើនវ័យដល់អាយុតាមបញ្ញត្តិច្បាប់ ឬ ក្នុងករណីដែលមានចែងក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ២ ។

**មាត្រា ២៣.-**

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈកាលបើសហព័ទ្ធណាម្នាក់ប្ដឹងថា ខ្លួនត្រូវគេចាប់បង្ខំអោយរៀបអាពាហ៍ពិពាហ៍ ។

ការប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្ដឹងនោះមិនធ្វើក្នុងរយៈពេល ៦ ខែ គិតពីថ្ងៃដែលគេលែងបង្ខំនោះមក ។

**មាត្រា ២៤.-**

អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់រលាយ ។

ការប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ក្រោយនេះអាពាហ៍ពិពាហ៍មកមុនត្រូវបានរលាយ ។

**មាត្រា ២៥.-**

អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខ័ណ្ឌទី ២ ។

ការប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

**មាត្រា ២៦.-**

មានតែសហព័ទ្ធ រដ្ឋអាជ្ញា និងជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

២-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធបានទទួលជាអំណោយ ជាមត៌ក ឬជាអច្ច័យទានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៣៥.-**

ត្រូវធ្លាក់លើបន្ទុកទ្រព្យសម្បត្តិរួម :

១-ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្តុះបណ្តាលកូន

២-បំណុល និង កាតព្វកិច្ចទាំងឡាយដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាសំរេចក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬដែលសហព័ទ្ធណាម្នាក់សំរេចក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ដោយមានការយល់ព្រមពីសហព័ទ្ធម្នាក់ទៀត ។

៣-ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម ។

**មាត្រា ៣៦.-**

សហព័ទ្ធម្នាក់ៗ អាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួម តាមការតំរូវនៃសម្ភារៈនោះ ។

សហព័ទ្ធទាំងពីរនាក់ ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមជាមួយគ្នា ។ សហព័ទ្ធម្នាក់អាចទាមទារអោយសហព័ទ្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ ដើម្បីថែទាំទ្រព្យសម្បត្តិរួម ឬរក្សាទុកតម្លៃរបស់ទ្រព្យសម្បត្តិនោះ ។

**មាត្រា ៣៧.-**

ទ្រព្យសម្បត្តិរួមអាចលក់ដូរ ឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ទ្ធទាំងពីរ ។

## ជំពូកទី ៣

## អំពីការលែងលះគ្នា

### ផ្នែកទី ១

### អំពីមូលហេតុនៃការលែងលះគ្នា

**មាត្រា ៣៨.-**

ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តី ប្រពន្ធដែលបានរៀបការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា ៣៩.-**

១-ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ ។

២-វាយដំ ឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ ។

៣-មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ

៤-អពលានុភាពនៃលិង្គ

៥-បែកគ្នាអស់រយៈជាង ១ ឆ្នាំ ។

**មាត្រា ៤០.-**

ប្តីប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

## ផ្នែកទី ២

## អំពីនីតិវិធីនៃការលែងលះគ្នា

**មាត្រា ៤១.-**

ការសំរេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្ត-ក្រុង ខាងលំនៅរបស់ចុងចម្លើយ ។

**មាត្រា ៤២.-**

បណ្តឹងសុំលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះមូលហេតុដែលនាំអោយលែងលះគ្នា ។

បណ្តឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណៈប្រជាជនឃុំឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយដោយខ្លួនឯងផ្ទាល់ក៏បាន ។

ក្នុងករណីខាងក្រោមនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សាក្នុងរយៈ ១៥ ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង ។ បើផ្សះផ្សាពុំបានសំរេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង ។

**មាត្រា ៤៣.-**

តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញអ្នកប្តឹងអោយចូលមក ហើយសំរួលយ៉ាងណាតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចូលចិត្តអ្នកនោះអោយឈប់ប្តឹង លើកលែងតែតុលាការប្រជាជនខេត្ត-ក្រុង យល់ឃើញថា ពាក្យសុំលែងលះគ្នានេះមានអាងហេតុធ្ងន់ធ្ងរណាស់ ។

**មាត្រា ៤៥.-**

ប្រសិនបើដើមចោទនៅតែទទូចសុំលែង តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធ អោយចូលមកកាន់តុលាការជាប្រញាប់ដើម្បីធ្វើការផ្សះផ្សា ។

ក្នុងករណីនេះ មេធាវីមិនត្រូវចូលរួមស្តាប់ទេ ។

**មាត្រា ៤៦.-**

ប្រសិនបើផ្សះផ្សាចំពោះមុខដើមចោទ និង ចុងចម្លើយហើយនៅតែពុំបានសំរេច តុលាការប្រជាជនខេត្ត-ក្រុង អាចធ្វើការផ្សះផ្សាជាលើកទី ២ បាន ។

**មាត្រា ៤៧.-**

ប្រសិនបើនៅពេលផ្សះផ្សាលើកទី ១ ដើមចោទ ឬចុងចម្លើយដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនមកបង្ហាញខ្លួនតាមការអញ្ជើញនោះ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីទាំងពីរនោះជាលើកទី ២ ដើម្បីធ្វើការផ្សះផ្សា ។

**មាត្រា ៤៨.-**

ប្រសិនបើដើមចោទ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកកាន់តុលាការប្រជាជនខេត្ត ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុនោះ ត្រូវចាត់ទុកថាសុខចិត្តឈប់ប្តឹង ។

**មាត្រា ៤៩.-**

ប្រសិនបើចុងចម្លើយបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយនៅតែមិនព្រមចូលខ្លួនមកកាន់តុលាការប្រជាជនខេត្ត-ក្រុង ទាំងលើកទី១ ទាំងលើកទី ២ ដោយគ្មានមូលហេតុ នោះត្រូវចាត់ទុកថា មិនព្រមសះជានឹងគ្នា ។

**មាត្រា ៥០.-**

ប្រសិនបើអ្នកដែលមិនបានមកតាមដីកាអញ្ជើញលើកទី ១ មិនមែនជាអ្នកមិនបានមកលើកទី ២ ទេ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីនោះមកផ្សះផ្សាជាលើកទី៣ ។

**មាត្រា ៥១.-**

ការផ្សះផ្សាម្តងៗត្រូវឱ្យឃ្លាតពីគ្នា ១ខែ យ៉ាងឆាប់ និង២ខែយ៉ាងយូរ ។

បើការផ្សះផ្សាមិនបានសំរេច តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធឱ្យចូលមកកាន់តុលាការប្រជាជន ដើម្បីជំនុំជំរះ ។

**មាត្រា ៥៤.-**

ប្រសិនបើដើមចោទ ត្រូវបានតុលាការប្រជាជនអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកបង្ហាញខ្លួនចំពោះតុលាការប្រជាជន និងមិនបានជូនសេចក្តីដោះសារ ឬមិនបានសុំឱ្យបង្អង់កាត់សេចក្តីទៅថ្ងៃក្រោយទេនោះ ត្រូវចាត់ទុកថាសុខចិត្តឈប់ប្តឹងវិញហើយ ។

ក្នុងករណីនេះ ត្រូវចេញសាលក្រមចំណាយរឿងក្តីនោះចោល ។

**មាត្រា ៥៥.-**

ប្រសិនបើចុងចំលើយ មិនបានចូលមកកាន់តុលាការប្រជាជន ក្នុងលក្ខខណ្ឌដូចខាងលើនេះដែរ ហើយបើយល់ឃើញថា ហេតុដែលដើមចោទប្តឹងនោះមានភស្តុតាងពិតប្រាកដ ហើយតុលាការប្រជាជនអាចសំរេចសេចក្តីអោយលែងលះគ្នាបាន ។ បើបណ្តឹងនោះមិនទាន់មានភស្តុតាងគ្រប់គ្រាន់ទេតុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរអំពីរឿងនោះ ។

**មាត្រា ៥៦.-**

បើចុងចំលើយប្រកែកថា សេចក្តីដែលប្តឹងពីខ្លួននោះមិនពិតទេ តុលាការប្រជាជនត្រូវបញ្ជាឱ្យធ្វើការអង្កេតស៊ើបសួរ ។

**មាត្រា ៥៧.-**

ក្នុងរឿងដែលលែងលះគ្នា បើមានការត្រូវអង្កេតស៊ើបសួរ ។ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរជាបន្ទាន់ ត្រូវបង្គាប់ឱ្យគូភាគីជូនភស្តុតាងចំបាច់នានា អញ្ជើញសាក្សីដែលមានប្រយោជន៍ក្នុងរឿងនេះ និងចាត់វិធានការទូទៅបើយល់ថាគួរចាត់ ។

**មាត្រា ៥៨.-**

ក្នុងករណីសុំលែងលះដោយព្រមព្រៀងគ្នា បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ការសុំលែងលះគ្នានោះធ្វើដោយគ្មានការបង្ខិតបង្ខំ និងដោយស្ម័គ្រចិត្តពិតប្រាកដ តុលាការប្រជាជនត្រូវសំរេចឱ្យលែងលះគ្នា ។

**មាត្រា ៥៩.-**

ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ស្ថានភាពរវាងប្តីប្រពន្ធមានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យាររយូរបាន គោលបំណងអាពាហ៍ពិពាហ៍

មាត្រា ៦១.–

ការវិនិច្ឆ័យផ្តល់អនុសេចក្តី ត្រូវតែធ្វើក្នុងរយៈ១៥ថ្ងៃគិតពីថ្ងៃអង្គុយស៊ើបសួររួចមក ។

មាត្រា ៦២.–

តាមគោលការណ៍សាលក្រមលែងលះគ្នា ត្រូវសំរេចនៅចំពោះមុខគូក្តី ។ ប្រសិនបើសាលក្រមនោះជាសាល-ក្រមកំបាំងមុខ គូក្តីអាចប្តឹងទាស់បានក្នុងរយៈពេល១៥ថ្ងៃ ។ រយៈពេលនេះគិតពីថ្ងៃដែលបានឱ្យដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តីផ្ទាល់ ឬដល់លំនៅរបស់គូក្តី ។

មាត្រា ៦៣.–

បណ្តឹងទាស់ និងសាលក្រមកំបាំងមុខ ត្រូវធ្វើដោយសាម៉ីខ្លួន ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ នៅតុលាការប្រជាជនខេត្ត-ក្រុង ។ បណ្តឹងទាស់នាំឱ្យផ្អាកការអនុវត្តសាលក្រម ។

មាត្រា ៦៤.–

ប្រសិនបើផុតរយៈពេលប្តឹងទាស់ សាលក្រមកំបាំងមុខនឹងទៅជាសាលក្រមស្ថាពរ ។

មាត្រា ៦៥.–

ប្រសិនបើអ្នកប្តឹងទាស់ បានប្តឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនមកក្នុងពេលជំនុំជំរះ ដោយគ្មានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវតំកល់ទុកជាបានការ និងទៅជាសាលក្រមស្ថាពរ ។

មាត្រា ៦៦.–

ប្រសិនបើបណ្តឹងទាស់ត្រឹមត្រូវតាមទំរង់ច្បាប់ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវពិនិត្យ និងជំនុំជំរះសាជាថ្មីលើអនុសេចក្តី ។

តុលាការប្រជាជនអាចតំកល់ កែប្រែ ឬបដិសេធសាលក្រមកំបាំងមុខ ដែលបានសំរេចសេចក្តីលើកមុនបាន កុំឱ្យតែបំពានលើច្បាប់ ឬគោលការណ៍នៃច្បាប់ ។

មាត្រា ៦៧.–

កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវចាត់ចែងឱ្យចំលងសេចក្តីវិនិច្ឆ័យនៃសាលក្រមស្ថាពរនោះ ចុះនៅរឹមចំហៀងនៃសំបុត្រអាពាហ៍ពិពាហ៍

ដែលត្រូវលែងលះ ។

មាត្រា ៦៨.–

ប្រសិនបើប្រពន្ធមានផ្ទៃពោះ ប្តីអាចនឹងសុំលែងលះបាន លុះត្រាតែប្រពន្ធនោះសំរាលកូនរួចបានមួយឆ្នាំសិន ។

ការបន្ថយសិទ្ធិខាងលើ មិនត្រូវអនុវត្តលើនារីទេ ។ នារីអាចសុំលែងលះបាននៅពេលមានផ្ទៃពោះ ។

## អំពីអានុភាពនៃការលែងលះគ្នា

**មាត្រា ៦៩.-**

ការលែងលះគ្នារំលាយអានុភាពអាពាហ៍ពិពាហ៍ ចាប់តាំងពីថ្ងៃដែលការលែងលះគ្នានោះទៅជាស្ថាពរ ។

**មាត្រា ៧០.-**

ក្នុងករណីនៃការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង ។ បើគ្មានការព្រមព្រៀង សហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមរតកក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ក្រៅពីនេះ សហព័ទ្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់ ។

ប៉ុន្តែក្នុងករណីពិសេស និងតាមសំណើរបស់សហព័ទ្ធណាមួយ តុលាការប្រជាជនអាចសំរេចសេចក្តី ចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និងផលិតកម្ម ។

ការងារនៃគេហកិច្ច ត្រូវចាត់ទុកជាមានតំលៃស្មើ និងការងារផលិតកម្ម ។

**មាត្រា ៧១.-**

ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ទ្ធម្នាក់ត្រូវ សហព័ទ្ធម្នាក់ទៀតបំផ្លាញ សហព័ទ្ធនេះត្រូវតែសងតំលៃទ្រព្យនោះវិញ ។

**មាត្រា ៧២.-**

សាលក្រមដែលកាត់ឱ្យប្តីប្រពន្ធលែងលះគ្នានោះត្រូវសំរេចអំពីអំណាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬទៅម្តាយ ហើយនឹងត្រូវសំរេចអំពីការទាក់ទងរវាងឪពុកម្តាយ និងកូននោះផង ។

**មាត្រា ៧៣.-**

ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសំរេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងគ្នានោះ ។ តាមគោលការណ៍កូនដែលនៅបៅដោះត្រូវឱ្យទៅម្តាយរក្សា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសំរេច ។

**មាត្រា ៧៤.-**

ឪពុក ឬម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចដែលត្រូវឱ្យទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ទ្ធដែលលែងលះគ្នា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ ។

អាហារកិច្ចត្រូវផ្តល់ឱ្យកូនរហូត ដល់កូនមាននីតិភាព ។

**មាត្រា ៧៥.-**

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូន ។ ភាគីដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិប្តឹងទៅតុលាការប្រជាជនគ្រប់ពេលវេលា ឱ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងនោះបានបើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ។

**មាត្រា ៧៦.-**

ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេចសេចក្តី ។ បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ ។

**មាត្រា ៧៧.-**

តុលាការប្រជាជនខេត្ត-ក្រុង អាចកែប្រែដោយបង្កើន ឬបន្ថយកំរិតអាហារកិច្ចបាន បើមានសំណូមពររបស់ភាគីម្ខាង ។ ការបង្កើត ឬបន្ថយកំរិតអាហារកិច្ចនោះត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់អាហារកិច្ច និងតាមសេចក្តីត្រូវការ នៃភាគីដែលទទួលអាហារកិច្ច ។

អាហារកិច្ចអាចផ្តល់អោយជាទឹកប្រាក់ ឬរបស់ ។

**មាត្រា ៧៨.-**

ការមិនព្រមបង់អាហារកិច្ចដូចបានចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់អាហារកិច្ចនោះ មិនស្មោះត្រង់ ។

## ភាគ១នៃទ្វារកំញាតិភាព

## អំពីអាពាហ៍ពិពាហ៍

**មាត្រា ៧៩.-**

អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជា ឬរវាងពលរដ្ឋកម្ពុជា និងជនបរទេស ដែលរស់នៅឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជាប្រចាំនៅប្រទេសដែលគូភាគី មានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជា និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទំរង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍នោះ ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយ និងបទបញ្ញត្តិច្បាប់នៃរដ្ឋកម្ពុជា ។

លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចំលងលិខិតអាពាហ៍ពិពាហ៍នេះត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជា ឬបើគូស្វាមីភរិយាមកតាំងលំនៅនៅរដ្ឋកម្ពុជា ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍-ពិពាហ៍នៅឃុំ ឬសង្កាត់ ដែលមកតាំងទីលំនៅនោះ ។

**មាត្រា ៨០.-**

អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេសរស់នៅរដ្ឋកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃរដ្ឋកម្ពុជា ។

## ផ្នែកទី ២

## រំលាយអាពាហ៍ពិពាហ៍

**មាត្រា ៨១.-**

ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និងពលរដ្ឋកម្ពុជា ឬរវាងពលរដ្ឋកម្ពុជា និងជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ។

-ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជា ត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។

-តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍ របស់សហព័ទ្ធណាមួយ ដែលចូលមកតាំងទីលំនៅ នៅរដ្ឋកម្ពុជា ។

## អំពីកូនមានខាន់ស្លា

**មាត្រា ៨២.–**

កូននឹងទុកជាកូនមានខាន់ស្លាលុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងលុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេលដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថាកូនដែលកើត១៨០ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬក្នុងរយៈពេល ៣០០ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍

**មាត្រា ៨៣.–**

កូនដែលកើតក្នុងរយៈពេលតិចជាង ១៨០ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងចាត់ទុកថាជាកូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ ប្តីនេះបានដឹងថាប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនថ្ងៃរៀបអាពាហ៍ពិពាហ៍ មកម្ល៉េះ ឬ ក៏ព្រមទទួលស្គាល់ថាខ្លួនជាឪពុករបស់កូននោះ ។ បើមិនដូច្នេះទេប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថាខ្លួនមិនមែនជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

**មាត្រា ៨៤.–**

កូនដែលកើតក្នុងលក្ខណៈនៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ ត្រូវឱ្យសន្មតថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថាកូននោះជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

**មាត្រា ៨៥.–**

ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តីប្តឹងពីម្តាយ និងពីកូន ចំពោះមុខតុលាការប្រជាជនខាងលំនៅនៃម្តាយក្នុងរយៈពេល២ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

**មាត្រា ៨៦.–**

ប្តីត្រូវជូនភស្តុតាងថា កាលប្រពន្ធខ្លួនមានគភ៌ក្នុងរយៈពេលដែលច្បាប់បានកំនត់នោះ ខ្លួនមានវិបត្តិខាងរូបកាយមិនអាចរួមដំណេកជាមួយម្តាយនៃកូននោះបានទេ ។ វិបត្តិខាងរូបកាយដែលពុំអាចឱ្យរួមដំណេក បាននោះអាចកើតពីហេតុពីរយ៉ាង :

១.ប្តីប្រពន្ធរស់នៅដាច់ឆ្ងាយពីគ្នា

២.ប្តីគ្មានពលានុភាពបណ្តាលមកពីកាយវិកលកម្មដែលមិនអាចឱ្យបន្តពូជបាន ។

**មាត្រា ៨៧.–**

ទាយាទខាងប្តី អាចនឹងប្តឹងបដិសេធកូននោះជំនួសបានក្នុងរយៈពេលដែលមានចែងក្នុងមាត្រា៨៥ ប្រសិនបើប្តី

នោះមិនអាចប្តឹងបានដោយប្តីនោះស្លាប់ បាត់ខ្លួន ឬកំឡុតស្មារតី ។

ទាយាទខាងប្តីអាចនឹងបន្តការប្តឹងបដិសេធកូននោះ បានប្រសិនបើក្នុងរយៈដែលមានចែងក្នុងមាត្រា៨៥ ប្តីនោះបានប្តឹងបដិសេធរួចហើយ ហើយស្លាប់ បាត់ខ្លួន ឬកំឡុតស្មារតី ។

**មាត្រា ៨៨.-**

សាលក្រមដែលសំរេចទទួលបណ្តឹងបដិសេធនោះ ទុកជាត្រឹមត្រូវ ត្រូវបង្គាប់ឱ្យលុបឈ្មោះប្តីនោះចេញពីបញ្ជីសំបុត្រកំណើតរបស់កូន ហើយឱ្យដកត្រកូលឪពុកចេញពីកូន ដោយយកត្រកូលម្តាយដាក់ជំនួសវិញ

**មាត្រា ៨៩.-**

ត្រូវបញ្ជូនសេចក្តីសំរេចនៃសាលក្រមទៅឱ្យមន្ត្រីអត្រានុកូលដ្ឋាន ដែលបានធ្វើសំបុត្រកំណើតរបស់កូននោះ ដើម្បីឱ្យចំលងដាក់ក្នុងបញ្ជីសំបុត្រកំណើតកូន ហើយចុះនិទ្ទេសនៅលើរឹមទំព័រសំបុត្រកំណើតដែលត្រូវកែនោះ ។

## ផ្នែកទី ២

## អំពីកូនឥតខាន់ស្លា

**មាត្រា ៩០.-**

ដែលហៅថាកូនឥតខាន់ស្លា គឺកូនដែលកើតពីឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៩១.-**

នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា កូនដែលកើតមកនោះជាកូនរបស់ខ្លួន នោះត្រូវចាត់ទុកឪពុកម្តាយនេះថា ឪពុកម្តាយរបស់កូននោះ ។

**មាត្រា ៩២.-**

បើមានតែឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯងទេ កូននោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានឆ្លើយ ទទួលស្គាល់តែម្នាក់ឯងតែប៉ុណ្ណោះ ។

**មាត្រា ៩៣.-**

ក្រោយពេលដែលឪពុក ឬម្តាយបានប្តឹងចុះសំបុត្រកំណើតកូន ឪពុក ឬម្តាយណា ដែលមិនទាន់ទទួលស្គាល់ ឪពុក ឬម្តាយនោះអាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

**មាត្រា ៩៤.-**

កូនឥតខាន់ស្លាដែលឪពុកម្តាយបានទទួលស្គាល់ នឹងទៅជាកូនមានខាន់ស្លាបាន បើក្រោយពីកំណើតរបស់កូននោះ ឪពុកម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

## អំពីការស្វែងរកបិតុភាព ឬមាតុភាពនៃកូនឥតខាន់ស្លា

**មាត្រា ៩៥.-**

បើគ្មានលិខិតអ្វីទទួលស្គាល់ដោយស្ម័គ្រចិត្តនូវកូនឥតខាន់ស្លាទេ នោះតុលាការប្រជាជនអាចតំរូវឱ្យឪពុក ឬម្ដាយទទួលស្គាល់កូននោះបាន ។

**មាត្រា ៩៦ :**

កូនឥតខាន់ស្លាដែលឪពុក ឬម្ដាយមិនបានទទួលស្គាល់ មានសិទ្ធិប្ដឹងសុំឱ្យតុលាការប្រជាជនរកឪពុក ឬម្ដាយឱ្យខ្លួនបាន ។

**មាត្រា ៩៧.-**

បណ្ដឹងសុំឱ្យតុលាការប្រជាជន តំរូវឱ្យឪពុក ឬម្ដាយទទួលស្គាល់នោះ អាចធ្វើឡើងក្នុងរយៈពេល២ឆ្នាំ គិតពីថ្ងៃដែលកូននោះមាននីតិភាព ។

នីតិភាពត្រូវកំណត់ចាប់តាំងពីអាយុ ១៨ឆ្នាំឡើងទៅ ។ ក្នុងពេលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ អ្នកអាណាព្យាបាលរបស់កូននោះមានសិទ្ធិប្ដឹងជួសសុំឱ្យតុលាការប្រជាជនរកមាតុភាពអោយកូននោះ ។

**មាត្រា ៩៨.-**

តុលាការប្រជាជន អាចតំរូវឱ្យនារីជាម្ដាយទទួលស្គាល់កូនឥតខាន់ស្លាបាន បើមានភស្តុតាងបញ្ជាក់ថា :

ក-នារីនោះបានបង្កើតកូនពិតប្រាកដមែន

ខ-អត្តសញ្ញាណរបស់កូនដែលនារីនោះបានបង្កើត និងអត្តសញ្ញាណរបស់កូនដែលប្ដឹងទាមទាររកមាតុភាព មិនខុសប្លែកគ្នា

ភស្តុតាងអាចបង្ហាញបានគ្រប់មធ្យោបាយ ។

**មាត្រា ៩៩.-**

តុលាការប្រជាជន អាចតំរូវឱ្យបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន :

១-បើបុរសនោះនាំពង្រត់ ឬចាប់សេពសន្ថវៈនារីជាម្ដាយដោយរំលោភ ហើយបើសម័យនាំពង្រត់ ឬចាប់រំលោភសេពសន្ថវៈនោះ ត្រូវគ្នា និងសម័យដែលនារីនោះមានគភ៌ ។

២-បើបុរសនោះ បានខ្លួននារីដោយឧបាយកលបោកបញ្ឆោត ដោយការរំលោភអំណាច ឬដោយសន្យាជានឹងរៀបអាពាហ៍ពិពាហ៍ជាមួយនារីនោះ ។

៣-បើមានភស្តុតាងជាលាយលក្ខណ៍អក្សរពីបុរសនោះបង្ហាញឱ្យឃើញច្បាស់ថា បុរសនោះពិតជាឪពុក

របស់កូននោះ ។

៤-បើបុរស និងនារី ជាឪពុក និងជាម្តាយរបស់កូននោះបានរួមរស់ និងគ្នាជាអនីតិសម្ព័ន្ធជាក់ស្តែងក្នុងសម័យនិស្សានុកូលដែលនារីនោះមានគភ៌ ។

៥-បើបុរសនោះបានផ្គត់ផ្គង់ ឬបានចូលរួមក្នុងការបីបាច់រក្សា និងការអប់រំកូននោះក្នុងឋានៈខ្លួនជាឪពុក

**មាត្រា ១០០.-**

ពាក្យដែលប្តឹងរកបិតុភាពមិនអាចនឹងទទួលបាន :

១-បើមានភស្តុតាងថា នារីជាម្តាយមានទំនាក់ទំនងកាមគុណ និងប្រុសដទៃទៀតក្នុងសម័យនិស្សានុកូលភាពដែលនារីនោះមានគភ៌ ។

២-បើក្នុងសម័យនិស្សានុកូល ដែលនារីមានគភ៌ បុរសដែលត្រូវប្រកាន់ថា ជាឪពុករបស់កូននោះគ្មានលទ្ធភាពរួមដំណេកជាមួយនារីជាម្តាយនោះ ដោយរស់នៅឆ្ងាយពីគ្នា ឬដោយមកពីមានគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១០១.-**

ក្នុងពេលដែលកូនឥតខាន់ស្លានៅក្នុងអនីតិភាពនៅឡើយ ម្តាយ ឬអ្នកអាណាព្យាបាលនៃកូននោះអាចសុំប្តឹងរកបិតុភាពបាន ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ១០២.-**

សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា មានអានុភាពដូចគ្នានឹងលិខិតដែលទទួលស្គាល់កូនដោយស្ម័គ្រចិត្តដែរ ។

**មាត្រា ១០៣.-**

កូនឥតខាន់ស្លា ត្រូវយកត្រកូលរបស់ឪពុក ឬម្តាយដែលទទួលស្គាល់ខ្លួន ។ ប្រសិនបើឪពុក និងម្តាយទាំងពីរនាក់ទទួលស្គាល់ កូននោះត្រូវយកត្រកូលរបស់ឪពុក ។

ប្រសិនបើតុលាកាប្រជាជន តំរូវឱ្យឪពុក ឬម្តាយទទួលស្គាល់កូននោះ ត្រូវយកត្រកូលអ្នកដែលតុលាការតំរូវឱ្យទទួលស្គាល់ ។

ប្រសិនបើតុលាការប្រជាជន តំរូវឱ្យឪពុក និងម្តាយទាំងពីរនាក់ទទួលស្គាល់ កូននោះត្រូវយកត្រកូលរបស់ឪពុក

**មាត្រា ១០៤.-**

កូនឥតខាន់ស្លាដែលត្រូវបានទទួលស្គាល់ មានករណីយកិច្ច និងមានសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ ។

**មាត្រា ១០៥.-**

តុលាការប្រជាជន ត្រូវបង្គាប់ឱ្យឪពុកឬម្តាយផ្តល់អាហារកិច្ចឱ្យកូនជាដរាប តាមសមាមាត្រនៃធនធានរបស់ឪ

**មាត្រា ១០៦.-**

សាលាក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូន ឥតខាន់ស្លា អាច និងបង្គំឱ្យឪពុកសងសោហ៊ុយសំរាលកូន និងប្រាក់ចំណាយចិញ្ចឹមបីបាច់រក្សាកូន តាំងពីថ្ងៃដែលកូននោះកើតមក ទៅម្តាយនៃកូននោះបាន ។

**មាត្រា ១០៧.-**

កំណត់ដែមួយច្បាប់ នៃសាលាក្រមស្ថាពរ ដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា ត្រូវផ្ញើរទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើត ដើម្បីចុះនិទ្ទេសអំពីបុត្តភាពនោះ នៅលើរឹមចំព័រនៃសំបុត្រកំណើត ។

## ជំពូកទី ៤
## អំពីសុំកូន

**មាត្រា ១០៨.-**

សុំកូនគឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថា កូនចិញ្ចឹម អោយមានចំណង និងគ្នា ដូចជាបុត្តភាពមានខាន់ស្លា ។

**មាត្រា ១០៩.-**

ឪពុក ឬម្តាយចិញ្ចឹមត្រូវមានអាយុលើសពី ២៥ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ឆ្នាំ ។ ឪពុក ឬម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬជាជនបរទេស ។

**មាត្រា ១១០.-**

គេអាចសុំកូនបានត្រឹមពីរនាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់គេអាចសុំកូនមួយនាក់ទៀតបាន ។ កូនចិញ្ចឹមត្រូវមានអាយុតិចជាង៨ឆ្នាំ

**មាត្រា ១១១.-**

សហព័ទ្ធណាមួយអាចនឹងសុំកូនយកមកចិញ្ចឹមបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ក្នុងករណីនេះ កូនចិញ្ចឹមត្រូវទុកជាកូនចិញ្ចឹមរបស់សហព័ទ្ធទាំងពីរនាក់ ។

**មាត្រា ១១២.-**

ដើម្បីអោយការសុំកូនសំរេចទៅបាន ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។

បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬសង្កាត់ ។

**មាត្រា ១១៣.-**

កិច្ចសន្យាសុំកូន ត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយបញ្ជាក់ដោយគណៈកម្មាធិការប្រជាជន ឃុំ ឬសង្កាត់ ខាង

-ឪពុក-ម្ដាយ ប្រើអំណាចដោយរំលោភទៅលើកូនដោយ ប្រើឧបាយកលផ្សេងៗដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬអំពើណាមួយប៉ះពាល់ដល់សង្គម ។

-ឪពុក-ម្ដាយ វាយធ្វើបាបកូនឥតត្រាប្រណី

-ឪពុក-ម្ដាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្ដាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។

**មាត្រា ១២០..**

តុលាការប្រជាជន អាចនឹងសំរេចដកហូតអំណាចមេបាពីឪពុកម្ដាយដែលមានកំហុសបាន លុះត្រាតែមានពាក្យប្ដឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន ឬញាតិលោហិតណាមួយនៃឪពុកម្ដាយនោះ ។

**មាត្រា ១២១..**

ការដកហូតអំណាចមេបា បណ្ដាលឱ្យឪពុក-ម្ដាយលែងមានសិទ្ធិដែលខ្លួនធ្លាប់មានពីមុនមកចំពោះកូនរបស់ខ្លួន ប៉ុន្តែនៅមានកាតព្វកិច្ចចិញ្ចឹមកូនតទៅទៀត រហូតដល់កូននេះចូលនីតិភាព ។ ក្នុងករណីនេះតុលាការប្រជាជនត្រូវកំណត់កំរិតអាហារកិច្ច ដែលឪពុក-ម្ដាយ ត្រូវផ្ដល់ទៅឱ្យអង្គការ ឬញាតិលោហិតដែលទទួលបន្ទុកចិញ្ចឹមកូននោះ ។

**មាត្រា ១២២..**

ដើម្បីផលប្រយោជន៍របស់កូន ច្បាប់អនុញ្ញាតឱ្យតុលាការប្រជាជនប្រគល់ទៅឪពុក-ម្ដាយដែលត្រូវបានដកហូតអំណាចមេបា នូវអំណាចមេបានេះឡើងវិញ ប្រសិនបើឪពុក-ម្ដាយនោះ បានកែប្រែគំនិតមារយាទរបស់ខ្លួនបានល្អឡើងវិញគួរអោយទទួលបន្ទុកអប់រំកូនបាន លើកលែងតែចំពោះកូនចិញ្ចឹម ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ.រដ្ឋសភា

ហត្ថលេខា និងត្រា

**ជា ស៊ីម**

ឧបសម្ព័ន្ធ ទី៣

# ច្បាប់

# ស្តីពី

# ឯកពន្ធភាព

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសេចក្តីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គលក្នុងគ្រួសារ និងការគោរពសិទ្ធិស្មើគ្នាទៅវិញទៅមករវាងប្តីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ២.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

## ជំពូកទី ២

## និយមន័យ ពិរុទ្ធភាព និងនីតិវិធី

**មាត្រា ៣.-**

ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្តីតែមួយ ។ ដែលហៅថាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាចាប់រួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

ចំណងអាពាហ៍ពិពាហ៍ត្រូវរលាយក្នុងករណីណាមួយដូចខាងក្រោម :

-សហព័ទ្ធណាមួយស្លាប់ ។

-មានសេចក្តីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ ។

-សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬរស់ ។

មាត្រា ៤.–

ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឬស្ត្រីមានប្តីពីរ ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព បុរស ឬ ស្ត្រីណាដែលមានចំណងអា-ពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ។

អ្នកសមគំនិតត្រូវមានទោសដូចគ្នា ។

មាត្រា ៥.–

ត្រូវចាត់ទុកថាស្មន់ បុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធនឹងគ្នា ហើយរួមសេវនកិច្ចជាមួយគ្នា ។

មាត្រា ៦.–

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទស្មន់ :

-បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬ ជាសាច់ចិញ្ចឹមក្តី បានរួមសេវន-កិច្ចជាមួយគ្នា ។

-បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមម្តាយឪពុកក្តី ជាញាតិលោហិតក្តី ឬ ជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់នេះ ផងបានរួមសេវនកិច្ចជាមួយគ្នា ។

មិនចាត់ទុកថាមានពិរុទ្ធពីបទស្មន់ទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហ-ព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ។

មាត្រា ៧.–

ត្រូវចាត់ទុកថាផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិត ៖

-បុរសណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។

-ស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរសដទៃទៀត ។

**មាត្រា ៨.–**

ក្នុងករណីដែលមានចែងក្នុងមាត្រា ៧ ខាងលើ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់ ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា ៩.–**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ១០.–**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១១.—**

ច្បាប់នេះ ពុំមានអានុភាពប្រតិសកម្មឡើយ ។

**មាត្រា ១២.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស.០៦១០.០៤២ នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៤០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុង ជីឡេង

**ឧបសម្ព័ន្ធ ទី៤**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រមរដ្ឋប្បវេណី

## ផ្នែកទី ៣

## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់នឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤

## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១

### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីភាពព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថ-ភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអព្លាពីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអព្លាពីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អព្ភាជីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអព្ភាជីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអព្ភាជីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.-** អានុភាពនៃអព្ភាជីនភាព

អនីតិជនដែលទទួលអព្ភាជីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.-** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

## កថាភាគទី ២
## ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.–** ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិរញ្ញបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិរញ្ញបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមហិរញ្ញបត្ថម្ភចំពោះជននោះ ។

**មាត្រា ២៥.–** អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ២៦.–** សិទ្ធលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ ពំណាងអយ្យការ ។

## កថាភាគទី ៣
## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពពិចារណ៍ខ្សោយក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ ពំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជនទៅក្រោមហិរញ្ញបព្ទអ្នក ដោយគ្មានការយល់ព្រមពីហិរញ្ញបព្ទអ្នកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្តឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមតិក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិរញ្ញបព្ទអ្នកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិរញ្ញបព្ទ) នៃក្រមនេះ ឬ ហិរញ្ញបព្ទអ្នកៈ ឬ អ្នកត្រួតពិនិត្យហិរញ្ញបព្ទអ្នកៈ ។

**មាត្រា ៣៤.-** ការលុបចោលការប្រកាសចាប់ផ្តើមហិរញ្ញបព្ទ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិរញ្ញបព្ទ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិរញ្ញបព្ទ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ហិរញ្ញុបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិរញ្ញុបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៤
## ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបាន ក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិរញ្ញុបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិរញ្ញុបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិរញ្ញុបត្ថម្ភទទួលយកសច្ចានុមតិពីហិរញ្ញុបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិរញ្ញុបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

**មាត្រា ៣៣.–** ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក

## ផ្នែកទី ៥
## លំនៅឋាន

**មាត្រា ៣៤.-** អត្ថន័យនៃលំនៅឋាន

កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ។

**មាត្រា ៣៥.-** ទីលំនៅ

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីលំនៅ ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

**មាត្រា ៣៦.-** ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីលំនៅរបស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

## ផ្នែកទី ៦
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន

### កថាភាគទី ១
### ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

**មាត្រា ៣៧.-** ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ ទីលំនៅ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រង

ទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសិទ្ធិរបស់អ្នកគ្រប់គ្រងត្រូវបានរលត់ នៅក្នុងរយៈពេលដែលសាមីខ្លួនអវត្តមាន ។

**មាត្រា ៣៨.-** ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) នៃក្រមនេះ ប្រសិនបើក្រោយមក បុគ្គលដែលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង តុលាការអាចលុបចោលនូវការបង្គាប់ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៣៩.-** ការផ្លាស់ប្តូរអ្នកគ្រប់គ្រង

ក្នុងករណីដែលបុគ្គលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបាន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៤០.-** សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍

១-អ្នកគ្រប់គ្រងដែលបានជ្រើសតាំងមានសិទ្ធិធ្វើសកម្មភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៦៦ (ទំហំនៃសិទ្ធិតំណាង) នៃក្រមនេះ ។ ប្រសិនបើចាំបាច់ត្រូវធ្វើសកម្មភាពផ្សេងទៀត អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលអវត្តមាននៅរស់ ឬ ទទួលមរណភាពទេ ហើយអ្នកគ្រប់គ្រងរបស់បុគ្គលអវត្តមាននោះចាំបាច់ត្រូវធ្វើសកម្មភាពដែល

ហួសសិទ្ធិដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្ដល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណា នូវទំនាក់ទំនងរវាងអ្នកអវត្តមាន នឹង អ្នកគ្រប់គ្រង នឹង ស្ថានភាពផ្សេងទៀត តុលាការអាចផ្ដល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

## ផ្នែកទី ២
## ការប្រកាសអំពីការបាត់ខ្លួន

**មាត្រា ៤១.-** លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

**មាត្រា ៤២.-** ការផ្សាយជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើង ដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការផ្សាយជាសាធារណៈ ។

**មាត្រា ៤៣.-** អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤១ (លក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ បានកន្លងផុត និង ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីលំណាក់កន្លងមករហូតដល់ពេលនោះ ។

**មាត្រា ៤៤.-** ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ

១-ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថា ទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ ។

២-បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ។ ប៉ុន្តែ បុគ្គលដែលមិនបានដឹងថា ការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ។

៣-អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ ។

៤-ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍

ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយ នោះ ។

## ផ្នែកទី ៧

## ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

**មាត្រា ៤៥.–** ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ។

## គន្ថីទី ៧
## ញាតិ

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៣៨.-** ទំហំរបស់ញាតិ

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ គឺជាញាតិ :

ក- ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ ។

ខ- សហព័ទ្ធ ។

គ- ញាតិពន្ធក្នុង៣ (បី)ថ្នាក់ ។

**មាត្រា ៩៣៩.-** ការគណនាថ្នាក់ញាតិ

១- ថ្នាក់ញាតិ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ ។

២- ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។

**មាត្រា ៩៤០.-** ការកើតមានឡើងនូវទំនាក់ទំនងញាតិភាពដោយការសុំកូន

ទំនាក់ទំនងរវាងកូនចិញ្ចឹម និង ឪពុក ម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន ។

**មាត្រា ៩៤១.-** ការរលត់ទំនាក់ទំនងញាតិពន្ធ

១- ទំនាក់ទំនងញាតិពន្ធ ត្រូវបញ្ចប់ដោយការលែងលះគ្នា ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀប

**មាត្រា ៩៨២.-** ការរលត់ញាតិភាព ដោយការកាត់កាល់ ឬ លែងទទួលស្គាល់

ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយនឹងឪពុកម្ដាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬ លែងទទួលស្គាល់ ។

**មាត្រា ៩៨៣.-**ករណីយកិច្ចគោរពគ្នារវាងញាតិ និង ការបង្ការអំពើហិង្សាក្នុងគ្រួសារ

១-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវគោរពសិទ្ធិ និង សេរីភាពរវាងគ្នាទៅវិញទៅមក ហើយត្រូវសង្គ្រោះគ្នាទៅវិញទៅមក ។

២-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវបង្ការកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ និង ត្រូវធ្វើយ៉ាងណាកុំឱ្យកើតមានឡើង នូវការរំលោភសិទ្ធិមនុស្ស ។

## **ជំពូកទី ២**
## **ការភ្ជាប់ពាក្យ**

**មាត្រា ៩៨៤.-** ការបង្កើតការភ្ជាប់ពាក្យ

ការភ្ជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្ដីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និង ដោយធ្វើពិធីភ្ជាប់ពាក្យ ។

**មាត្រា ៩៨៥.-** ការសងជំនូន

ក្នុងករណីដែលការភ្ជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនូននៅពេលភ្ជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀត សងជំនូននោះមកវិញបាន ។

**មាត្រា ៩៨៦.-** ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ

ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធការភ្ជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាត

ដែលកើតឡើងដោយសារការបដិសេធចោលនោះបាន ។

**មាត្រា ៩៤៧.-** អំឡុងពេលដាក់ពាក្យបណ្ដឹង

បណ្ដឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនួន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្ដឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភ្ជាប់ពាក្យនោះ បានរលាយ ។

## ជំពូកទី ៣
## អាពាហ៍ពិពាហ៍

### ផ្នែកទី ១
### ការបង្កើតអាពាហ៍ពិពាហ៍

#### កថាភាគទី ១
#### លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៤៨.-** អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។

**មាត្រា ៩៤៩.-** ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ។

**មាត្រា ៩៥០.-** អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១-នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០

(មួយរយថ្ងៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបាន រំលាយ ឬ លុបចោល ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណី ដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជ-បណ្ឌិត ។

**មាត្រា ៩៥១.-** ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ រវាងញាតិលោហិត

១-អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិ លោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំង ថ្នាក់ទី ៣ (បី) ផង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្រោយ ពេលដែលទំនាក់ទំនងញាតិ ត្រូវបានបញ្ចប់ ដោយបញ្ញត្តិនៃមាត្រា ១០១៤ (ការបញ្ចប់ នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត) មាត្រា ១០១៦ (ការកាត់កាល់នៃសុំកូនពេញ លេញ) ឬ មាត្រា ១០៣២ (អានុភាពនៃការកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ។

**មាត្រា ៩៥២.-** ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

១-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយ បញ្ញត្តិមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬ មាត្រា ១០១៦ (ការកាត់កាល់នៃ សុំកូនពេញលេញ) នៃក្រមនេះ ។

២-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេល បានបញ្ចប់ទំនាក់ទំនងញាតិពន្ធ តាមបញ្ញត្តិនៃមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិ ពន្ធ) ខាងលើនេះ ។ ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅ រស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ បាន ។

**មាត្រា ៩៥៣.-** ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

១-ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់ហើយ ។

៣-ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន ។

**មាត្រា ៩៥៤.-** ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ។

**មាត្រា ៩៥៥.-** ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

២-ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្ដីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ។

**មាត្រា ៩៥៦.-** ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថា

អាពាហ៍ពិពាហ៍នោះ ផ្ទុយនឹងបញ្ញត្តិ ចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជនទៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ៩៥៧.-** ទម្រង់នៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស

១-បើមានបំណងចង់រៀបអាពាហ៍ពិពាហ៍រវាងគ្នា ពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ចុះបញ្ជីអាពាហ៍ពិពាហ៍នោះ នៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុល របស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

២-ការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយបិទនៅបញ្ជររបស់ស្ថានទូត ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

## កថាភាគទី ២
## មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

**មាត្រា ៩៥៨.-** មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈតែក្នុងករណីដូចកំណត់ខាងក្រោមនេះ :

ក-ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និង មូលហេតុផ្សេងៗទៀត ។

ខ-ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ ។

**មាត្រា ៩៥៩.-** ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ ត្រូវធ្វើ ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៦០ (ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម) ខាងក្រោមនេះ ។

**មាត្រា ៩៦០.-** ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥២ (ការហាមឃាត់មិនឱ្យរៀបអាពាហ៍-ពិពាហ៍រវាងញាតិពន្ធ) នៃក្រមនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬ តំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន ។ ប៉ុន្តែ នៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះ បានឡើយ ។

២-ចំពោះអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) ឬ មាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍-ពិពាហ៍ថ្មីទៀត) នៃក្រមនេះ សហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធមុននោះ ក៏អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ ។

**មាត្រា ៩៦១.-** ការរលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមនេះ ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។

២-ក្រោយពេលជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ នោះបាន នៅក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ ។ ប៉ុន្តែ

បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើជននោះបានធ្វើសច្ចានុមតិ បន្ទាប់ពីបាន គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ។

**មាត្រា ៩៦២.-** ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ ពុំអាចទាមទារឱ្យលុបចោលបានឡើយ ប្រសិនបើរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍-ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ឬ ប្រសិនបើនារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ។

**មាត្រា ៩៦៣.-** ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម

១-បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម អាចទាមទារទៅតុលាការ ឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន ។

២-សិទ្ធិលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ បើភាគីបានរកឃើញការឆបោក ឬ បើអំឡុងពេល ៣ (បី) ខែ បានកន្លងផុត ក្រោយពីបានរួចខ្លួនផុតពីការគំរាម ឬ បើបានធ្វើសច្ចានុមតិ ។

**មាត្រា ៩៦៤.-** អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

១-ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ ។

២-ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍-ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះ ត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល ។

៣-ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ។ ប្រសិនបើភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ ។

៤-បញ្ញត្តិនៃមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះកូនដែលមានកំណើតរវាងភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

៥-បញ្ញត្តិនៃមាត្រា ៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីនៃការរំលាយអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

## ផ្នែកទី ២
## អានុភាពនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៦៥.-** នាមត្រកូលរបស់ប្តី ប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ៩៦៦.-** ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក ។

**មាត្រា ៩៦៧.-** សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន ។

**មាត្រា ៩៦៨.-** ការចាត់ទុកជានីតិជន ដោយអាពាហ៍ពិពាហ៍

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ ។

## ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ

### កថាភាគទី ១

### ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**មាត្រា ៩៦៩.-** កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្ដីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ ។

២-បើប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

**មាត្រា ៩៧០.-** ភាពចាំបាច់នៃទម្រង់ជាលាយលក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និង លក្ខខណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ ។

### កថាភាគទី ២

### ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

**មាត្រា ៩៧១.-** ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍

ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

**មាត្រា ៩៧២.-** ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

**មាត្រា ៩៧៣.-** ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

**មាត្រា ៩៧៤.-** ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការ ឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

**មាត្រា ៩៧៥.-** ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះភាតព្វកិច្ច

ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះភាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ-ភាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ភាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

**មាត្រា ៩៧៦.-** ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្ដីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបាន

ដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង ។

**មាត្រា ៩៧៧.-** ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ បាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ ។

## ផ្នែកទី ៤

## ការលែងលះគ្នា

### កថាភាគទី ១

### មូលហេតុនៃការលែងលះគ្នា

**មាត្រា ៩៧៨.-** មូលហេតុនៃការលែងលះគ្នា

១-ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយ

គ្មានសង្ឃឹមថានឹងអាចបនិទានឡើងវិញបាន ។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬ ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ៩៧៩.-** ការលែងលះដោយការព្រមព្រៀង

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ។ ប៉ុន្តែ តុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៩៨០.-** ការបែងចែកទ្រព្យសម្បត្តិ

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់ នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការ

ទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ ។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

**មាត្រា ៩៨១.-** ការលែងលះគ្នា និង នាមត្រកូល

ប្តី ឬ ប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន ។

## កថាភាគទី ២
## នីតិវិធីនៃការលែងលះគ្នា

**មាត្រា ៩៨២.-** បណ្តឹងនៃការលែងលះគ្នា

១-ពាក្យបណ្តឹងលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុគ្គលភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។

២-ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬ ទីលំនៅ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុគ្គលភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សា

ឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងនោះ ទៅតុលាការជាបន្ទាន់ ។

**មាត្រា ៩៨៣.-** ការចាត់ចែងរក្សាការពារ

តុលាការដែលទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ៩៨៤.-** ការសាកល្បងផ្សះផ្សា ដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្ដឹងលែងលះគ្នា មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម ។

## ជំពូកទី ៤

## ឪពុកម្ដាយ និង កូន

### ផ្នែកទី ១

### បុត្តភាព

#### កថាភាគទី ១

#### បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៨៥.-** ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្ដាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្ដាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពី

ថ្ងៃដែលកូននោះកើត ។ ប្រសិនបើឪពុក ឬ ម្ដាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្ដាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះ ឱ្យបានឆាប់រហ័ស ។

២-ក្នុងករណីដែលឪពុកម្ដាយបានធ្វេសប្រហែសនឹងករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៩៨៦.-** វិធីគណនាអាយុ

១-អាយុត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ។

២-បញ្ញត្តិនៃមាត្រា ៣៣៩ (ការគណនាអំឡុងពេលតាមប្រតិទិនស៊ុរិយគតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគណនាអាយុ ។

## កថាភាគទី ២
## ការសម្រេចអំពីបុត្តភាព

**មាត្រា ៩៨៧.-** មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន ។

**មាត្រា ៩៨៨.-** ការសន្មតបិតុភាព

១-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្ដី ។

២-កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

៣-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើត

កូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍-ពិពាហ៍ក្រោយ ។

**មាត្រា ៩៨៩.-** ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

**មាត្រា ៩៩០.-** បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្ត ដោយបណ្តឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ក្នុងអំឡុងពេល ១ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៩៩១.-** បណ្តឹងបដិសេធបិតុភាព ពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្តឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្តាយដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ១ (ប្រាំមួយ)

ខែ បានគន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានគន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា *៩៩២*.-** អានុភាពប្រតិសកម្មនៃបណ្តឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

**ឧបសម្ព័ន្ធ ទី៥**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាល**

**លេខ** : ១០៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# អត្រានុកូលដ្ឋាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

  បានឃើញច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសដោយក្រមប្រឹក្សារដ្ឋលេខ ៩៦ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦ /០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

# សង្ខេប

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងគ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ។

**មាត្រា ៣.-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.-**

រាល់ការសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ និង/ឬ សាក្សី និង ឬសាមីខ្លួន ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និងសាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥.-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.-**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

## ជំពូកទី ៥
## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨.-**

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមានទៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់ នៃសាមីខ្លួននារី ០១ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់ នៃសាមីខ្លួនបុរស ០១ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ :

១- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅនៃអនាគត ប្ដី ប្រពន្ធ ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុក ម្ដាយ នៃអនាគតប្ដី ប្រពន្ធ បើឪពុក ឬម្ដាយស្លាប់ ត្រូវដាក់ថាស្លាប់

៣- រយៈពេលប្ដឹងជំទាស់ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិ-ពាហ៍នោះ ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្ដឹងជំទាស់ ។ បើមានបណ្ដឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្ដឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

**មាត្រា ៣០.-**

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្ដី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

**មាត្រា ៣១.-**

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៣២.-**

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍ នោះ ឬបើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជាត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រី អត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពី សៀវភៅនូវសំបុត្រពាហ៍ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់ ។

**មាត្រា ៣៣.-**

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍ដោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពី ទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឱ្យបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង រួមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៦

## អំពីសំបុត្រមរណភាព

**មាត្រា ៣៥.-**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានចម្ងល់សង្ស័យទាក់ទង ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះ សពតាមការសម្រេចនោះ ។

**មាត្រា ៣៦.-**

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាង ណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

**មាត្រា ៣៧.-**

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់

**មាត្រា ៣៨.-**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះដើម្បីឲ្យមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

**មាត្រា ៣៩.-**

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់ឲ្យអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៤០.-**

បើមានអ្នកស្លាប់ហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់នៅបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់ផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនពេលចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពដែលមួយជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឲ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង តមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៧

## អំពីសំបុត្របញ្ជាក់កំណើត

**មាត្រា ៤៣.-**

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជាមីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

**មាត្រា ៤៤.-**

ពេលមានអ្នកមកសុំចុះសៀវភៅកំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៨

## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

**មាត្រា ៤៥.-**

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬប្រពន្ធ ពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជាមីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮច្បាស់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នានាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៦.-**

ពេលមានសាមីខ្លួនប្តី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៩

## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧.-**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលអនុក្រឹត្យស្ដីពី អត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្ដីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ១០

## អំពីសេចក្ដីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩.-**

សេចក្ដីចម្លង ឬសម្រង់អត្រានុកូលដ្ឋានមាន សេចក្ដីចម្លង ឬសម្រង់សំបុត្រកំណើត សេចក្ដីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្ដីចម្លង ឬសម្រង់សំបុត្រមរណភាព សេចក្ដីចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត សេចក្ដីចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងសេចក្ដីចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្ដីចម្លង ត្រូវអនុវត្តដូចគ្នា នឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ៥០.-**

បើមានអ្នកមកសុំចម្លង ឬសុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬសម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និងកំពុងថែរក្សា ក្នុងឆ្នាំដែលមិនទាន់ផុត នៅសាលាឃុំ ឬសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្ដីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬសម្រង់ចេញពី សន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

**មាត្រា ៥១.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ផុត ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

**មាត្រា ៥២.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ឬខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬសម្រង់នៅសាលាស្រុក ឬសាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង ។

**មាត្រា ៥៣.-**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់នៅបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ផុត ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

**ឧបសម្ព័ន្ធ ទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ទំរង់ និងនីតិវិធីនៃការស្នើសុំអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញក្រឹត្យលេខ ៨៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥ នស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឯកពន្ធភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីគោលបំណង និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

**មាត្រា ២.-**

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ត្រូវហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារសេវាឯកជន ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម ។

**មាត្រា ៤.-**

ត្រូវហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ ដោយកេងបន្លំ ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ ។

# ជំពូកទី ២
## ទម្រង់ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍
## រវាងពលរដ្ឋខ្មែរនិងជនបរទេស

**មាត្រា ៥.-**

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញទម្រង់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ។

**មាត្រា ៦.-**

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវឯកសារដូចខាងក្រោម :

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃ លិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ។

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់និត្យានុកូលភាពពីស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃការងារ ។ ក្រោយពីបានពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនពត៌មានទៅស្ថានទូតពាក់ព័ន្ធ ។

មាត្រា ៨.-

បន្ទាប់ពីទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃមានភារកិច្ច ៖

- ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ។
- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។
- ពិនិត្យមើលត្រានុកូលភាពលើសំណុំឯកសារដែលបានបញ្ជូនដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

មាត្រា ៩.-

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

មាត្រា ១០.-

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានភារកិច្ច ពិនិត្យ និងសម្រេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់

សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ០៧ថ្ងៃការងារ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់ ។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍ និងសាលាឃុំ សង្កាត់ នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។ ផុតរយៈពេល១០ថ្ងៃ ប្រសិនគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារី អាចរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១១.-**

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលេញតាមផ្លូវច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយមានវត្តមានសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

**មាត្រា ១២.-**

ក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ អំពីតំរូវការឯកសារ បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំអំពីតំរូវការឯកសារ បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ ។

## ជំពូកទី ៣

## អវសានបញ្ញត្តិ

**មាត្រា ១៣.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

ហោ ណាំហុង

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ ទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី/ខេត្ត.................

ក្រុង/ស្រុក/ខណ្ឌ.............

ឃុំ/សង្កាត់....................

លេខ.............................

រូបថត

៤x៦

# លិខិតបញ្ជាក់

## ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ

## សូមបញ្ជាក់ថា

ឈ្មោះ........................... ភេទ....... មុខរបរ............ សញ្ជាតិ.......... កើតថ្ងៃទី....... ខែ....... ឆ្នាំ........... ទីកន្លែងកំណើត ភូមិ.......... ឃុំ/សង្កាត់............ ក្រុង/ស្រុក/ខណ្ឌ.......... ខេត្ត/រាជធានី............ ។

- ឪពុកឈ្មោះ...................... អាយុ.......ឆ្នាំ មុខរបរ........... ថ្ងៃខែឆ្នាំកំណើត......................
- ម្ដាយឈ្មោះ...................... អាយុ.......ឆ្នាំ មុខរបរ........... ថ្ងៃខែឆ្នាំកំណើត......................

ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.......... ផ្លូវ.......... ក្រុមទី....... ភូមិ.......... ឃុំ/សង្កាត់............ ក្រុង/ស្រុក/ខណ្ឌ............ ខេត្ត/រាជធានី.............. ។ មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន............ ពិតប្រាកដមែន ។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមុីជនដើម្បីយកទៅប្រើប្រាស់..............................។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ)

ថ្ងៃ.................. ខែ.......... ឆ្នាំ......... ត្រីស័ក ព.ស ២៥.....

............., ថ្ងៃទី....... ខែ.......... ឆ្នាំ...........

មេឃុំ/ចៅសង្កាត់

**ឧបសម្ព័ន្ធ ទី៨**

ខេត្ត/ក្រុង រាជធានី (១)..... ភ្នំពេញ .........
ស្រុក/ខណ្ឌ (២).... ឫស្សីកែវ ........
ឃុំ/សង្កាត់ (៣)...... ជាក់ខែង ........

លេខ (៤)............... ០៤ ..........................
សៀវភៅសំបុត្រអាពាហ៍ពិពាហ៍លេខ (៥)...០១/២០១២..
ឆ្នាំ (៦)......... ២០១២ ................................

## សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្ដី ប្រពន្ធ | | ប្ដី | | ប្រពន្ធ | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | សាយ | | អ៊ូ | |
| នាមខ្លួន (៨) | | សំអាន | | នួនស្រី | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | | OU | |
| | នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | | ខ្មែរ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | ថ្ងៃ[illegible] ទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | | ថ្ងៃ[illegible] ទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | | ភូមិក្ដីចាស់ ឃុំជាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | សាស្ត្រាចារ្យ | | គ្រូពេទ្យ | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ភូមិជាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្ដីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | | មួយ | | មួយ | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | | ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | | សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | | ០៤ ម.ន ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ | | | |
| **អំពីឪពុក ម្ដាយ** | | **ខាងប្ដី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | | សាយ សំអឿន (២១) | សញ្ជាតិ ខ្មែរ | អ៊ូ សែម | សញ្ជាតិ ខ្មែរ |
| ជាអក្សរឡាតាំង (២២) | | SAY SAM OEUN (២៣) | រស់ ឬ ស្លាប់ | OU SEM | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | | ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | |
| មុខរបរបច្ចុប្បន្ន (២៥) | | កសិករ | | ជាងសំណង់ | |
| ទីលំនៅបច្ចុប្បន្ន (២៦) | | ភូមិជាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្ដីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២៧) | | សែម បុប្ផា (២៨) | សញ្ជាតិ ខ្មែរ | នួន ផល្លា | សញ្ជាតិ ខ្មែរ |
| ជាអក្សរឡាតាំង (២៩) | | SEM BOPHA (៣០) | រស់ ឬ ស្លាប់ | NUON PHALLA | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | | ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | | ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ១៩[illegible] | |
| មុខរបរបច្ចុប្បន្ន (៣២) | | ជាងកាត់ដេរ | | លក់ដូរ | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | | ភូមិជាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្ដីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| **អំពីសាក្សី** | | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៤) | | សោម ចុយ (៣៥) | ភេទ ប្រុស | សេង ភក្តី | ភេទ ស្រី |
| សញ្ជាតិ (៣៦) | | ខ្មែរ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៥ | | ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨០ | |
| មុខរបរបច្ចុប្បន្ន (៣៨) | | កសិករ | | គ្រូបង្រៀន | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | | ភូមិក្ដីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្ដីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានមិនឲ្យបានត្រឹមត្រូវតាមសេចក្ដីប្រកាសរបស់អ្នក ដែលមកសុំ ជនទោះ និង មន្ត្រីអត្រានុកូលដ្ឋានទោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤២) ធ្វើនៅ.....ជាក់ខែង............ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

**ឧបសម្ព័ន្ធ ទី៩**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង ..................

ស្រុក ខណ្ឌ ..................

ឃុំ សង្កាត់ ..................

លេខ ..................

## បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលស្គាល់ជិតស្និទ្ធ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី............ ខែ...................... ឆ្នាំ............... ។

ធ្វើនៅ...................... ថ្ងៃទី.......... ខែ............... ឆ្នាំ..........

**មន្ត្រីអត្រានុកូលដ្ឋាន**

**ឧបសម្ព័ន្ធ ទី១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង (១) --- *កណ្ដាល* -----

ស្រុក ខណ្ឌ (២) --- *កណ្ដាលស្ទឹង* ---

ឃុំ សង្កាត់ (៣) --- *គោកត្រប់* ----

លេខ (៤)----- *២៥* ---------------

សៀវភៅកំណើតលេខ (៥)--០១/២០១២--

ឆ្នាំ (៦)------ *២០១២*---------------

## សំបុត្រកំណើត

| | | |
|---|---|---|
| នាមត្រកូល (៧) | *សម* | ភេទ (៩) |
| នាមខ្លួនទារក (៨) | *សិទ្ធី* | *ប្រុស* |
| ជាអក្សរឡាតាំង (១០) នាមត្រកូល | SAM | |
| ជាអក្សរឡាតាំង (១០) នាមខ្លួនទារក | SITHY | |
| សញ្ជាតិ (១១) | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | *ថ្ងៃ ច័ន្ទ ទី ០៩ ខែ មករា ឆ្នាំ ២០១២* | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ........................ | |

| ឪពុក ម្ដាយរបស់ទារក | ឪពុក | ម្ដាយ |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | *សម សោភ័ណ* | *គុណ រតនា* |
| ជាអក្សរឡាតាំង (១៥) | SAM SORPHORN | KUN RATANA |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៧) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៨៤* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៦* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ...*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា*... | ...*ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*... |
| ទីលំនៅពេលទារកកើត (១៩) | ......*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាល ស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |

(២០) ធ្វើនៅ... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(២១) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២២) *ហត្ថលេខា និងត្រា*

**ឧបសម្ព័ន្ធ ទី១១**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង (១) ---- *កណ្ដាល* ------

ស្រុក ខណ្ឌ (២) ---- *កណ្ដាលស្ទឹង* ---

ឃុំ សង្កាត់ (៣) ---- *គោកត្រប់* -----

## សេចក្ដីចម្លងសំបុត្រកំណើត

| | | | | |
|---|---|---|---|---|
| ចម្លងសំបុត្រកំណើតពេញលេញ | | (៤) សៀវភៅកំណើត<br>លេខ ៖ *០១/២០១២* | (៥) សំបុត្រកំណើត<br>លេខ *២៥* ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ | |
| នាមត្រកូល (៦) | | *សម* | | ភេទ (៨) |
| នាមខ្លួន (៧) | | *ស៊ីធី* | | *ប្រុស* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAM | | |
| | នាមខ្លួន | SITHY | | |
| សញ្ជាតិ (១០) | | *ខ្មែរ* | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកក្រើង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ................................ | | |
| **ឪពុក ម្ដាយ** | | **ឪពុក** | **ម្ដាយ** | |
| នាមត្រកូល និងនាមខ្លួន (១៣) | | *សម សោភ័ណ* | *គុណ រតនា* | |
| ជាអក្សរឡាតាំង (១៤) | | SAM SORPHORN | KUN RATANA | |
| សញ្ជាតិ (១៥) | | *ខ្មែរ* | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៦) | | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៨២* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* | |
| ទីកន្លែងកំណើត (១៧)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .....*ភូមិព្រែកកៅ ឃុំកោះខែល ស្រុក ស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា*...... | ......*ភូមិពោធិ៍ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*..... | |
| ទីលំនៅពេលទារកកើត (១៨) | | *ភូមិគោកក្រើង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិគោកក្រើង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |

(១៩) ធ្វើនៅ... *គោកត្រប់* ..... ថ្ងៃទី *០១* ខែ *មីនា* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន**-----

**មេឃុំ**

(២១) *ហត្ថលេខា និងត្រា*

*ស៊ី លៀង*

**ឧបសម្ព័ន្ធ ទី១២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង..........................................
ស្រុក ខណ្ឌ..........................................
ឃុំ សង្កាត់..........................................

លេខ..........................................
សៀវភៅអាពាហ៍ពិពាហ៍លេខ..........................................
ឆ្នាំ..........................................

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្ដាយ | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ..........................................ថ្ងៃទី..........ខែ..............ឆ្នាំ..............

**មន្ត្រីអត្រានុកូលដ្ឋាន**

**ឧបសម្ព័ន្ធ ទី១៣**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង (១) ..... កណ្ដាល ..... លេខ (៤) ..........០៥ ..................

ស្រុក ខណ្ឌ (២) ..... កោះធំ ..... សៀវភៅបញ្ជីមរណភាពលេខ (៥)..០១/២០០៨..

ឃុំ សង្កាត់ (៣) ..... ព្រែកស្ដី ..... ឆ្នាំ (៦)..........២០០៨ ..................

# សំបុត្របញ្ជាក់មរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | ម៉ែន | ភេទ (៩) |
| នាមខ្លួនសព (៨) | | សាម៉ន | ប្រុស |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | MEN | |
| | នាមខ្លួនសព | SAMAN | |
| សញ្ជាតិ (១១) | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | ថ្ងៃ សុក្រ ទី ០៨ ខែ មីនា ឆ្នាំ ១៩៣១ | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | .......... ភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា .................. | |
| ស្ថានភាពសព (១៤)<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | ពោះម៉ាយ | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥) | | ថ្ងៃ ច័ន្ទ ទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (១៦) | | ម៉ែន សាម៉ែន | សញ្ជាតិ (១៧) |
| ជាអក្សរឡាតាំង (១៨) | | MEN SAMEN | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩១០ | |
| នាមត្រកូល និង នាមខ្លួនម្ដាយសព (២០) | | សួន ប្រាថ្នា | សញ្ជាតិ (២១) |
| ជាអក្សរឡាតាំង (២២) | | SUON PRATHNA | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩១២ | |

(២៤) ធ្វើនៅ.....ព្រែកស្ដី..... ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

**ឧបសម្ព័ន្ធ ទី១៤**


KINGDOM OF CAMBODIA
NATION RELIGION KING
សៀវភៅគ្រួសារ
FAMILY RECORD BOOK
នាមត្រកូល-នាមខ្លួន
SURNAME AND NAME
№

ឧបសម្ព័ន្ធ ទី១៥


ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

សៀវភៅស្នាក់នៅ
CARNET DE RESIDENCE

NOM ET PRENOM
CHEZ N° VOIE GROUPE
VILLAGE
COMMUNE QUARTIER
VILLE DISTRICT
CAPITALE PROVINCE
LE
N°
REGISTRE N° PAGE

**ឧបសម្ព័ន្ធ ទី១៦**

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង**

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...............................................................។

**សូមគោរពជូនមក**

**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្ដាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..............................................................................................................

..............................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..............................................................................................................

..............................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ).......................................................................................

..............................................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ).......................................................................................

..............................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។

- ..............................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់........................... តាមលិខិតលេខ............ ចុះថ្ងៃទី..................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ.................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១......

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

..................

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

.....................

**ឧបសម្ព័ន្ធ ទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
គ្មានការព្រមព្រៀង

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន.........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន.........................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ.........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
..........................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
..........................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់......................។
- ..........................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ........................ ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) ........................
..........................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)